# INEE

# ស្តង់ដារអប្បបរមាសំរាប់
# ការអប់រំក្នុងគ្រាមានអាសន្ន
# វិបត្តិរ៉ាំរ៉ៃ និង ការស្តារគ្រាដំបូង



**បណ្តាញអន្តរភ្នាក់ងារសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន** (INEE) គឺជាបណ្តាញសាកលនៃជាង១០០អង្គការ និងបុគ្គលសមាជិកជាង៨០០នាក់ ដែលធ្វើការរួមគ្នាដើម្បីធានានូវសិទ្ធិអប់រំក្នុងគ្រាមានអាសន្ននិងការស្តារក្រោយវិបត្តិ។ បណ្តាញនេះទទួលខុសត្រូវប្រមូលនិងផ្សព្វផ្សាយពត៌មានអំពីការអប់រំក្នុងគ្រាមានអាសន្នដោយលើកកំពស់សិទ្ធិអប់រំសំរាប់ប្រជាជនដែលប៉ះពាល់ដោយគ្រោះអាសន្ន និងដោយធានានូវការផ្លាស់ប្តូរពត៌មានជាប្រចាំក្នុងចំណោមសមាជិកនិងដៃគូររបស់ខ្លួន។ INEE ដឹកនាំដោយគណៈកម្មាធិការនាយកមួយដែលបច្ចុប្បន្នមានតំណាងមកពីអង្គការ CARE USA គណៈកម្មាធិការសង្គ្រោះអន្តរជាតិ សម្ព័ន្ធភាពសង្គ្រោះកុមារអន្តរជាតិ ក្រុមប្រឹក្សាជនភៀសខ្លួនន័រវេ UNESCO UNHCR UNICEF និងធនាគារពិភពលោក។


សំរាប់ពត៌មានបន្ថែម សូមទាក់ទង INEE :

តាមរយៈ UNESCO

ED/EPS
7 Place de Fontenoy
75007 Paris France
coordinator@ineesite.org
www.ineesite.org



INEE © 2004



ISBN 1-58030-c34-0



រក្សាសិទ្ធិគ្រប់យ៉ាង។ ឯកសារនេះត្រូវបានរក្សាសិទ្ធិ ប៉ុន្តែអាចផលិតឡើងវិញបានដោយវិធីណាក៏ដោយសំរាប់គោលបំណងអប់រំ។ ការសុំអនុញ្ញាតផ្លូវការត្រូវទាមទារជាចាំបាច់សំរាប់គ្រប់ការប្រើប្រាស់បែបនេះ ប៉ុន្តែតាមធម្មតានឹងត្រូវផ្តល់ជូនភ្លាម។ សំរាប់ការថតចម្លងនៅក្នុងកាលៈទេសៈផ្សេងទៀត ឬសំរាប់ការប្រើប្រាស់ ឡើងវិញនៅក្នុងការបោះពុម្ពផ្សាយផ្សេងទៀត ឬសំរាប់ការបកប្រែឬកែសំរួល ត្រូវតែសុំសំបុត្រអនុញ្ញាតជាមុនពីម្ចាស់កម្មសិទ្ធិ។



រូបថតនៅក្របមុខៈ គណៈកម្មាធិការសង្គ្រោះអន្តរជាតិ

រចនា និងបោះពុម្ពដោយៈ DS Print/Redesing, London

# មាតិកា


## សេចក្តីផ្តើម

**ស្តង់ដារអប្បបរមាសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន** ..................... ៥

**១. ស្តង់ដារអប្បបរមាដែលទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់** ..................... ១២

ការចូលរួមរបស់សហគមន៍ (ការចូលរួម និងធនធាន) ..................... ១៦

ការវិភាគ (ការប៉ាន់ប្រមាណ ជំនួយ ការត្រួតពិនិត្យនិងវាយតម្លៃ) ..................... ២៣

ឧបសម្ព័ន្ធ១: ក្របខ័ណ្ឌវាយតម្លៃ ..................... ៣៥

ឧបសម្ព័ន្ធ២: ការរៀបចំផែនការក្នុងពេលមានគ្រាអាសន្ន: តារាងពិនិត្យសំរាប់វិភាគស្ថានការណ៍ ..................... ៣៧

ឧបសម្ព័ន្ធ៣: ការប្រមូលពតិមាន និងការប៉ាន់ប្រមាណតំរូវការ ..................... ៤១

**២. ការទទួលយក និងបរិស្ថានសិក្សា** ..................... ៤៩

ឧបសម្ព័ន្ធ១: តារាងពិនិត្យចិត្តសង្គម ..................... ៦៦

ឧបសម្ព័ន្ធ២: តារាងពិនិត្យកម្មវិធីផ្តល់អាហារតាមសាលារៀន ..................... ៦៨

**៣. ការបង្រៀន និងការសិក្សា** ..................... ៧៣

**៤. គ្រូបង្រៀន និង បុគ្គលិកអប់រំដទៃទៀត** ..................... ៨៩

ឧបសម្ព័ន្ធ១: ក្រមសីលធមិគ្រូបង្រៀន ..................... ៩៩

**៥. គោលនយោបាយអប់រំ និងការសំរួលសំរួល** ..................... ១០២

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១: វាក្យសព្ទ

ឧបសម្ព័ន្ធ២: ឯកសារយោង និងមគ្គុទេសន៍ធនធាន

ឧបសម្ព័ន្ធ៣: អំណរគុណ

## ទំរង់ការផ្តល់មតិ_យោបល់


សំរាប់ឯកសារបន្ថែមអំពីទំរង់ និងតារាងពិនិត្យការប៉ាន់ប្រមាណ និងសំរាប់ការភ្ជាប់ទៅនឹងស្វែរនៃធម្មនុញ្ញមនុស្សធមិនិង ឯកសារដែលភ្ជាប់ MSEE ទៅនឹងស្វែរស្តង់ដា និងការណែនាំអំពីការអប់រំរបស់ UNHCR សូមមើល http://www.ineesite.org/standads/msee.asp និង/ឬមើល MSEE CD-ROM ដែលមាននៅគេហទំព័រ INEE ។

# សេចក្តីផ្តើម:
# ស្តង់ដាអប្បបរមា
# សំរាប់ការអប់រំ
# ក្នុងគ្រាមានអាសន្ន

ស្តង់ដាអប្បបរមាសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន (MSEE) គឺជាសៀវភៅណែនាំព្រមទាំងជាការសម្តែងនូវការប្តេជ្ញាចិត្តដែលបង្កើតតាមរយៈដំណើរការសហការដ៏ទូលំទូលាយ ដែលចែងថាបុគ្គលគ្រប់រូប ក្មេង យុវវ័យ និងមនុស្សពេញវ័យ មានសិទ្ធិទទួលបានការអប់រំក្នុងគ្រាមានអាសន្ន។ សៀវភៅនេះគាំទ្រជំនឿ ស្នូលនៃគម្រោងស្វែរដែលចែងថាៈ គ្រប់ជំហានដែលអាចធ្វើបានទាំងអស់គួរតែប្រកាន់យកដើម្បីលុបបំបាត់ការឈឺចាប់របស់មនុស្សជាតិដែលកើតចេញពីគ្រោះមហន្តរាយ និងជម្លោះ ហើយប្រជាជនដែលប៉ះពាល់ដោយគ្រោះមហន្តរាយមានសិទ្ធិរស់នៅដោយសេចក្តីថ្លៃថ្នូរ។

## ទិដ្ឋភាពទូទៅ

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ។ សិទ្ធិនេះមានចែងនៅក្នុងអនុសញ្ញានិងឯកសារអន្តរជាតិនានា រួមមានការប្រកាសជាសាកលអំពីសិទ្ធិមនុស្ស (១៩៤៨) អនុសញ្ញាដែលទាក់ទងនឹងស្ថានភាពជនភៀសខ្លួន (១៩៥១) អនុសញ្ញាក្រុងហ្សឺណែវ (IV) ដែលទាក់ទងនឹងការការពារជនស៊ីវិលពេលសង្គ្រាម កតិការសញ្ញាស្តីអំពីសិទ្ធិវប្បធម៌ សង្គម និងសេដ្ឋកិច្ច (១៩៦៦) អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) និងក្របខណ្ឌសកម្មភាពនៃវេទិការអប់រំពិភពលោកដាកា (២០០០) ដែលជំរុញការអប់រំសំរាប់ទាំងអស់គ្នា។

ការអប់រំក្នុងពេលមានអាសន្ន និងក្នុងអំឡុងពេលមានវិបត្តិរ៉ាំរ៉ៃ និងការស្តារគ្រាដំបូង អាចជួយជីវិតព្រមទាំងពន្យារជីវិត។ វាអាចសង្គ្រោះជីវិតដោយការការពារប្រឆាំងនឹងការកេងប្រវ័ញ្ចនិងគ្រោះថ្នាក់ និងដោយផ្សព្វផ្សាយសារសង្គ្រោះជីវិតសំខាន់ៗអំពីបញ្ហាដូចជា សុវត្ថិភាពគ្រាប់មីន ឬការការពារហ៊ីវ/អេដស៍ជាដើម។ វាពន្យារជីវិត ដោយផ្តល់នូវរចនាសម្ព័ន្ធ ស្ថេរភាព និងក្តីសង្ឃឹមសំរាប់អនាគតក្នុងពេលកំពុងមានវិបត្តិ ជាពិសេសសំរាប់កុមារ និងក្មេង

ជំទង់។ ការអប់រំក្នុងគ្រាមានអាសន្នក៏ជួយព្យាបាលការឈឺចាប់នៃបទពិសោធន៍អាក្រក់ កសាងជំនាញ និងគាំទ្រការដោះស្រាយជម្លោះ និងការកសាងសន្តិភាពផងដែរ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានការកើនឡើងនូវការយល់ដឹងអំពីតំរូវការនៃកម្មវិធីអប់រំក្នុង និងក្រៅប្រព័ន្ធនៅក្នុងស្ថានភាពមានអាសន្ន។ កុមារ យុវវ័យ និងមនុស្សពេញវ័យរាប់លាននាក់បានទទួលផលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរអប់រំ និងទីភ្នាក់ងារមនុស្សធម៌ជាតិនិងអន្តរជាតិនានា។ នៅពេលដែលការអប់រំត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំង បញ្ហាសំខាន់ពីរបានលេចឡើងៈ

១. ការទទួលស្គាល់ថា បុគ្គលទាំងឡាយមិនបោះបង់ចោលសិទ្ធិទទួលបានការអប់រំក្នុងគ្រាមានអាសន្នទេ ហើយការអប់រំមិនអាចស្ថិត 'នៅក្រៅ' ការពិភាក្សាអំពីបញ្ហាមនុស្សធម៌សំខាន់ៗទេ ប៉ុន្តែត្រូវតែគិតថាជាជំនួយមនុស្សធម៌អាទិភាព និង

២. ការប៉ុនប៉ងនិងការប្តេជ្ញាចិត្តដ៏ទូលំទូលាយ ដើម្បីធានានូវកំរិតអប្បបរមានៃគុណភាព ការទទួលយក និងគណនេយ្យភាពសំរាប់ការអប់រំក្នុងស្ថានភាពមានវិបត្តិ។

ជាការឆ្លើយតប នៅឆ្នាំ២០០៣ក្រុមការងារមួយត្រូវបានបង្កើតដើម្បីសំរបសំរួលការបង្កើតស្តង់ដាអប្បបរមាសកលសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន។ គំនិតផ្តួចផ្តើមនេះត្រូវបានគាំទ្រនៅក្នុង**បណ្តាញអន្តរភ្នាក់ងារសំរាប់ការ អប់រំក្នុងគ្រាមានអាសន្ន** (INEE) ដែលជាបណ្តាញបើកចំហនៃទីភ្នាក់ងារអ.ស.ប NGOs អ្នកផ្តល់ជំនួយ អ្នកអនុវត្តអ្នកស្រាវជ្រាវ និងបុគ្គលមកពីក្រុមប្រជាជនរងគ្រោះ ដែលធ្វើការរួមគ្នាដើម្បីធានានូវសិទ្ធិអប់រំក្នុងគ្រាមានអាសន្ន និង ការស្តារក្រោយវិបត្តិ។ បណ្តាញនេះទទួលខុសត្រូវប្រមូលនិងផ្សព្វផ្សាយការអនុវត្តន៍ល្អ ឧបករណ៍និងការស្រាវជ្រាវជំរុញសិទ្ធិសំរាប់ប្រជាជនដែលប៉ះពាល់ដោយគ្រោះអាសន្ន តាមរយៈការតស៊ូមតិនិងធានាឱ្យមានការផ្លាស់ប្តូរពត៌មានជាប្រចាំក្នុងចំណោមសមាជិកនិងដៃគូររបស់ខ្លួន។ INEE ក៏ស្វែងរកចន្លោះប្រហោងផងដែរនៅក្នុងធនធាននិងជំរុញឱ្យមានការបង្កើតធនធានទាំងនេះតាមរយៈក្រុមការងារដែលរៀបចំដោយអង្គការសមាជិក INEE។

ស្តង់ដាអប្បបរមាសាកលទាំងនេះត្រូវបានបង្ហាញនៅក្នុងសៀវភៅណែនាំនេះ ដែលជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយដើម្បីបង្កើតស្តង់ដាអប្បបរមាសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន។ ចាប់តាំងពីឆ្នាំ ២០០៣ ដោយធ្វើការជាមួយទីភ្នាក់ងារពាក់ព័ន្ធដ៏ច្រើន ក្រុមការងារ INEE អំពីស្តង់ដាអប្បបរមាសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន (WGMSEE ) បានសំរបសំរួលការបង្កើតស្តង់ដា សូចនាករនិងកំណត់សំគាល់ណែនាំ ដែលចែងអំពីកំរិតអប្បបរមានៃការផ្តល់និងទទួលយកការអប់រំក្នុងគ្រាមានអាសន្នរហូតដល់ដំណាក់កាលដំបូងនៃការស្តារឡើងវិញ។ សមាសធាតុសំខាន់នៃដំណើរការនៃការបង្កើតនេះ គឺការពិគ្រោះយោបល់ថ្នាក់តំបន់ អនុតំបន់ និងថ្នាក់ជាតិ

ការផ្តល់យោបល់តាមរយៈបណ្តាញសារអេឡិចត្រូនិចរបស់ INEE និងដំណើរការជួយពិនិត្យដោយសហសេវិក។ ពតិមានដែលបានប្រមូលពីជំហាននិមួយៗ ត្រូវបានប្រើសំរាប់ជំហានបន្ទាប់នៃដំណើរការ។

មនុស្សជាង២២៥០នាក់មកពីជាង៥០ប្រទេស បានរួមចំណែកចំពោះដំណើការបង្កើតស្តង់ដាអប្បបរមាទាំងនេះ។ រវាងខែមករានិងមិនា ឆ្នាំ២០០៤ WGMSEE បានសំរបសំរួលការពិគ្រោះយោបល់ថ្នាក់តំបន់បួននៅអាហ្វ្រិក អាស៊ុី អាមេរិកឡាទីន និងមជ្ឈិមបូព៌ានិងអឺរ៉ុប។ ប្រតិភូ១៣៧នាក់ ដែលចូលរួមក្នុងការពិគ្រោះយោបល់ទាំងនេះ រួមមាន តំណាងមកពីក្រុមប្រជាជនរងគ្រោះ NGOs ជាតិ និងអន្តរជាតិ រដ្ឋាភិបាល និងទីភ្នាក់ងារអ.ស.បនៅ ៥១ ប្រទេស។ មុនការពិគ្រោះយោបល់ថ្នាក់តំបន់ទាំងនេះ ប្រតិភូនិងសមាជិក INEEបានសំរបសំរួលការពិគ្រោះយោបល់ថ្នាក់អនុតំបន់ និងថ្នាក់ជាតិ ជាង១១០លើកនៅ៤៧ប្រទេស ដោយប្រមូលមតិយោបល់និងពតិមានពីតំណាង អ.ស.ប រដ្ឋាភិបាល និង NGOs ទីភ្នាក់ងារផ្តល់ជំនួយ អ្នកសិក្សា និងតំណាងជាង១.៥០០នាក់មកពីសហគមន៍រងគ្រោះ រួមមានសិស្សនិងបុគ្គលិកអប់រំដទៃទៀត។ ប្រតិភូនៃកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ ពិភាក្សាស្តង់ដាសូចនាករ និងកំណត់សំគាល់ណែនាំដែលបានបង្កើតនៅក្នុងការពិគ្រោះយោបល់ថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ព្រមទាំងចម្លើយជាង ១០០ ដែលបានមកពីបណ្តាញសារអេឡិចត្រូនិច INEE ដើម្បីបង្កើតស្តង់ដាអប្បបរមាថ្នាក់តំបន់។ ដំណើរការជួយពិនិត្យដោយសហសេវិកដែលធ្វើឡើងនៅរដូវក្តៅឆ្នាំ២០០៤ មានការចូលរួមពីអ្នកជំនាញជាង៤០រូបដែលបានវិភាគ និងសំរួលស្តង់ដាថ្នាក់តំបន់ឱ្យទៅជាសំណុំស្តង់ដាសកល។

ស្តង់ដាអប្បបរមាដែលបានមកទាំងនេះគឺផ្អែកលើអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC ) ក្របខ័ណ្ឌការអប់រំទាំងអស់គ្នាដាកា (EFA) គោលដៅអភិវឌ្ឍន៏សហស្សវត្សនៃអ.ស.ប (MDG) និងធម្មនុញ្ញមនុស្សធម៌នៃគម្រោងស្វែរ។ CRC EFA និង MDG ចែងអំពីសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពសំរាប់ទាំងអស់គ្នា រួមទាំងជនដែលប៉ះពាល់ដោយគ្រោះអាសន្ន។ សៀវភៅណែនាំនេះគឺជាឧបករណ៍សំរាប់ប្រើដើម្បីសំរេចកំរិតអប្បបរមានៃការផ្តល់និងទទួលយកការអប់រំដើម្បីបំពេញសិទ្ធិនេះ។

ធម្មនុញ្ញមនុស្សធម៌នៃគម្រោងស្វែរ និងស្តង់ដាអប្បបរមាក្នុងជំនួយគ្រោះអាសន្នដែលបានបង្កើតនៅឆ្នាំ១៩៩៧ដោយ NGOs មនុស្សធម៌មួយក្រុមនិងចលនាកាកបាទក្រហមនិងអឌ្ឍច័ន្ទក្រហម ចែងអំពីអ្វីដែលប្រជាជនប៉ះពាល់ដោយគ្រោះអាសន្នមានសិទ្ធិចង់បានជំនួយមនុស្សធម៌។ សៀវភៅណែនាំស្វែរ រួមមានធម្មនុញ្ញមនុស្សធម៌ផ្អែកលើគោលការណ៍និងមាត្រានៃច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់ជនភៀសខ្លួន និងក្រមអនុវត្តសំរាប់ចលនា កាកបាទក្រហមនិងអឌ្ឍច័ន្ទក្រហម និងអង្គការក្រៅរដ្ឋាភិបាល (NGOs) នៅក្នុងជំនួយគ្រោះអាសន្ន។ ធម្មនុញ្ញនេះរៀបរាប់អំពីគោលការណ៍ស្នូលដែលគ្រប់គ្រងសកម្មភាពមនុស្សធម៌និងបញ្ជាក់ឡើងវិញអំពីសិទ្ធិរស់នៅដោយថ្លៃថ្នូររបស់ប្រជាជនដែលប៉ះពាល់ដោយគ្រោះអាសន្ន។ ធម្មនុញ្ញនេះបញ្ជាក់ពីការទទួលខុសត្រូវផ្លូវច្បាប់របស់រដ្ឋនិងភាគី សង្គ្រាម ដើម្បីធានានូវសិទ្ធិក្នុងការទទួលបានការការពារនិងជំនួយឧបត្ថម្ភ។ នៅពេលអាជ្ញាធរពាក់ព័ន្ធ

មិនអាច និង/ឬ មិនមានឆន្ទៈបំពេញការទទួលខុសត្រូវរបស់ពួកគេ ពួកគេត្រូវតែមានកាតព្វកិច្ចឱ្យអង្គការមនុស្សធម៌ផ្តល់ការការពារ និងជំនួយឧបត្ថម្ភផ្នែកមនុស្សធម៌។

## នៅពេលណាត្រូវប្រើស្តង់ដារអប្បបរមា

ស្តង់ដាអប្បបរមាសំរាប់ការអប់រំក្នុងគ្រាមានអាសន្ន (MSEE ) ត្រូវបានបង្កើតឡើងសំរាប់ប្រើក្នុងជំនួយគ្រោះអាសន្ន ហើយអាចមានផលប្រយោជន៍ផងដែរក្នុងការត្រៀមការពារគ្រោះអាសន្ន និងការតស៊ូមតិផ្នែកមនុស្សធម៌។ ស្តង់ដាទាំងនេះអាចប្រើបានក្នុងស្ថានភាពច្រើន រួមទាំងគ្រោះធម្មជាតិនិងជម្លោះប្រដាប់អាវុធ។ នៅក្នុងសៀវភៅណែនាំនេះ'គ្រោះអាសន្ន'ត្រូវបានប្រើជាពាក្យទូទៅជំនួសឱ្យគ្រោះអាសន្នពីរប្រភេទធំៗ: **'គ្រោះធម្មជាតិ'** **និង** **'គ្រោះអាសន្នស្មុគស្មាញ'** ដែលមានន័យដូចខាងក្រោម។[១]

- ***គ្រោះធម្មជាតិ*** រួមមានខ្យល់ព្យុះ ការរញ្ជួយផែនដី ការរាំងស្ងួត និងទឹកជំនន់។ល។ គ្រោះធម្មជាតិខ្លះ ដូចជាការរញ្ជួយផែនដីជាដើម អាចកើតឡើងដោយមិនមានការព្រមាន ហើយមានផលប៉ះពាល់ខ្លាំងដល់ប្រជាជនដែលរស់នៅតំបន់នោះ។ គ្រោះធម្មជាតិផ្សេងទៀត ដូចជាការរាំងស្ងួត អាចកើតឡើងយឺតជាង ប៉ុន្តែមានផលប៉ះពាល់បំផ្លាញស្មើគ្នា។
- ***គ្រោះអាសន្នស្មុគស្មាញ*** គឺជាស្ថានភាពដែលបង្កើតឡើងដោយមនុស្ស ហើយជារឿយៗបង្ករដោយជម្លោះ ឬការចលាចលស៊ីវិល ដែលអាចធ្វើឱ្យកាន់តែធ្ងន់ធ្ងរដោយគ្រោះធម្មជាតិ។ ក្នុងកាលៈទេសៈបែបនេះ ជីវិត សុវត្ថិភាព សុខមាលភាព និងសេចក្តីថ្លៃថ្នូរនៃប្រជាជនរងគ្រោះត្រូវបានបំផ្លាញដោយកត្តាវិបត្តិផ្សេងៗដូចជាគ្រោះធម្មជាតិ និងគ្រោះដែលបង្ករដោយមនុស្ស និងជម្លោះប្រដាប់អាវុធ។

ពត៌មានដែលមាននៅក្នុងសៀវភៅណែនាំនេះមិនមានលក្ខណៈបង្គាប់បញ្ជាទេ។ ស្តង់ដាអប្បបរមាទាំងនេះត្រូវបានបង្កើតដោយអ្នកពាក់ព័ន្ធមកពីកំរិតផ្សេងៗគ្នា (ឧទាហរណ៍ គ្រួសារ និងសហគមន៍ អាជ្ញាធរមូលដ្ឋាន មន្ត្រីក្រសួងទីភ្នាក់ងារផ្តល់ជំនួយ អ្នកអនុវត្ត។ល។) ហើយបានវិវត្តន៍ចេញពីបរិស្ថានគ្រោះអាសន្ននិងការស្តារគ្រាដំបូងពាសពេញពិភពលោក។ ស្តង់ដាទាំងនេះ ផ្តល់នូវការណែនាំអំពីវិធីដែលរដ្ឋាភិបាលថ្នាក់ជាតិ អាជ្ញាធរផ្សេងទៀត ទីភ្នាក់ងារជាតិ និងអន្តរជាតិ អាចឆ្លើយតបនិងបង្កើតកម្មវិធីអប់រំក្នុងស្ថានភាពមានអាសន្ន។ ស្តង់ដាទាំងនេះត្រូវបានបង្កើតសំរាប់ប្រើដោយសហគមន៍ រដ្ឋាភិបាល អាជ្ញាធរផ្សេងទៀត និងបុគ្គលិកមនុស្សធម៌ ដើម្បីបំពេញតំរូវការការអប់រំដូចដែលកំណត់ដោយប្រជាជនរងគ្រោះ។

[១] និយមន័យសំរួលពី សម្ព័ន្ធភាពសង្គ្រោះកុមារអន្តរជាតិ ឆ្នាំ២០០១។

## តារាងពេលវេលា

តារាងពេលវេលាដែលស្តង់ដាអប្បបរមាទាំងនេះត្រូវបានប្រើភាគច្រើនអាស្រ័យលើបរិបទ។ ស្តង់ដាទាំងនេះអាចប្រើក្នុងស្ថានភាពគ្រោះអាសន្នច្រើនប្រភេទ ពីដំណាក់កាលជំនួយបន្ទាន់ដំបូងទៅដំណាក់កាលដំបូងនៃការស្តារឡើងវិញហើយអាចប្រើបានដោយទីភ្នាក់ងារច្រើនប្រភេទ។ សូចនាករនៅក្នុងសៀវភៅណែនាំនេះមិនអាចប្រើបានទូទៅសំរាប់គ្រប់ស្ថានភាពឬដោយគ្រប់អ្នកប្រើប្រាស់នោះទេ។ វាអាចប្រើពេលរាប់សប្តាហ៍ រាប់ខែ ឬរាប់ឆ្នាំដើម្បី សំរេចស្តង់ដានិងសូចនាករខ្លះ។ ក្នុងករណីខ្លះ ស្តង់ដាអប្បបរមានិងសូចនាករអាចត្រូវបានសំរេចដោយមិនត្រូវការជំនួយពីខាងក្រៅ។ ក្នុងករណីខ្លះទៀតវាអាចចាំបាច់សំរាប់អាជ្ញាធរអប់រំនិងទីភ្នាក់ងារសហការគ្នាដើម្បីសំរេចស្តង់ដានិងសូចនាករទាំងនេះ។ នៅពេលអនុវត្តស្តង់ដានិងសូចនាករទាំងនេះ វាមានសារៈសំខាន់ដែលតួអង្គពាក់ព័ន្ធទាំងអស់យល់ព្រមលើតារាងពេលវេលាមួយសំរាប់អនុវត្តនិងសំរេចលទ្ធផល។

## វិធីប្រើស្តង់ដារអប្បបរមា

មានសៀវភៅណែនាំនិងឧបករណ៍ជាច្រើនដែលបង្កើតដោយទីភ្នាក់ងារអន្តរជាតិនានា និង NGOs ដែលផ្តល់ការណែនាំជាក់ស្តែងដល់បុគ្គលិកអប់រំក្នុងគ្រាមានអាសន្ននិងការស្តារគ្រាដំបូង ដែលទាក់ទងនឹងទិដ្ឋភាពផ្សេងៗនៃសកម្មភាពសិក្សានិងចិត្តសាស្ត្រ-សង្គម។ អង្គការទាំងនេះ ព្រមទាំងក្រសួងអប់រំនិងមន្ត្រីអប់រំដទៃទៀតបានបង្កើតមគ្គុទេសន៏ និងគោលនយោបាយស្តីអំពីការបង្កើតនិងរក្សាកម្មវិធីអប់រំប្រកបដោយគុណភាព។ សៀវភៅណែនាំនេះមិនផ្តល់ការបរិយាយពិស្តារអំពីយុទ្ធសាស្ត្រនិងកម្មវិធីសំរាប់បង្កើតនិងអនុវត្តនៅសហគមន៏ទេ។ ប៉ុន្តែវាផ្តល់សំណុំនៃស្តង់ដាអប្បបរមា សូចនាករសំខាន់ៗនិងកំណត់សំគាល់ណែនាំអំពីសកម្មភាពមនុស្សធម៌នៅក្នុងបរិបទអប់រំពីការបង្កើតកម្មវិធីអប់រំសំរាប់ការអនុវត្តន៏ និងបន្តកម្មវិធីព្រមទាំងការគាំទ្រពីសហគមន៏និងរដ្ឋាភិបាល។ ស្តង់ដាអប្បបរមាត្រូវបានបង្ហាញជាប្រាំចំណាត់ថ្នាក់ ដូចតទៅ:

- **ស្តង់ដាអប្បបរមាទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់:** ផ្នែកនេះផ្តោតទៅលើចំនុចសំខាន់ៗនៃការចូលរួមរបស់សហគមន៏និងការប្រើប្រាស់ធនធានក្នុងតំបន់នៅពេលអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅណែនាំនេះ ព្រមទាំងធានាថាជំនួយអប់រំក្នុងគ្រាមានអាសន្នគឺផ្អែកលើការប៉ាន់ប្រមាណដំបូងដែលមានជំនួយសមស្រប និងការត្រួតពិនិត្យនិងវាយតម្លៃជាបន្តបន្ទាប់។

- **ការទទួលយកនិងអគារ/បរិស្ថានសិក្សា:** ផ្តោតលើភាពជាដៃគូដើម្បីបង្កើនឱកាសសិក្សានិងទំនាក់ទំនងអន្តរវិស័យជាមួយ ឧទាហរណ៏ សុខភាព ទឹក និងអនាម័យ ជំនួយស្បៀង/អាហារូបត្ថម្ភ និងជម្រកដើម្បីពង្រឹងសន្តិសុខ និងសុខមាលភាពផ្នែកចិត្តសាស្ត្រ ផ្នែកបញ្ញា និងរាងកាយ។

- **ការបង្រៀននិងរៀន:** ផ្តោតលើសមាសធាតុសំខាន់ៗដែលជំរុញការបង្រៀន និងការរៀនមានប្រសិទ្ធិភាពៈ (១). កម្មវិធីសិក្សា (២). ការបណ្តុះបណ្តាល (៣). ការបង្រៀន (៤). ការវាយតម្លៃ ។
- **គ្រូនិងបុគ្គលិកអប់រំដទៃទៀត:** ផ្តោតលើរដ្ឋាភិបាលនិងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ រួមមានការជ្រើសរើសបុគ្គលិក លក្ខខណ្ឌសេវាកម្ម និងការត្រួតពិនិត្យនិងការគាំទ្រ។ និង
- **គោលនយោបាយអប់រំនិងការសំរបសំរួល:** ផ្តោតលើការបង្កើត និងអនុម័តគោលនយោបាយ ការធ្វើផែនការ និងការអនុវត្តន៏និងការសំរបសំរួល។

## ភាពខុសគ្នារវាងស្តង់ដា និងសូចនាករ

ស្តង់ដាអប្បបរមាគឺផ្អែកលើគោលការណ៏ដែលចែងថាប្រជាជនរងគ្រោះមានសិទ្ធិរស់នៅដោយថ្លៃថ្នូរ។ ស្តង់ដាទាំងនេះចែងអំពីកំរិតអប្បបរមានៃការផ្តល់និងទទួលយកការអប់រំដែលនឹងត្រូវសំរេចក្នុងស្ថានភាពជំនួយមនុស្សធម៌។ ស្តង់ដាទាំងនេះមានលក្ខណៈគុណវិស័យជាធម្មជាតិនិងអាចចាត់ទុកជាសកល និងអាចយកទៅប្រើប្រាស់បានគ្រប់កាលៈទេសៈ។ សូចនាករសំខាន់ៗសំរាប់ស្តង់ដានិមួយៗគឺជាសញ្ញាដែលបង្ហាញថាស្តង់ដាត្រូវបានសំរេចឬទេ។ សូចនាករដើរតួជាឧបករណ៏សំរាប់វាស់និងបង្ហាញផលប៉ះពាល់(ឬលទ្ធផល) នៃកម្មវិធីព្រមទាំងដំណើរការ (ឬវិធីសាស្ត្រ) ដែលប្រើទោះជាផ្អែកគុណភាពឬបរិមាណក្តី។ គ្មានសូចនាករសំខាន់ៗ ស្តង់ដាអប្បបរមានឹងក្លាយជាសេចក្តីប្រកាសក្នុងបំណងល្អតែពិបាកយកទៅអនុវត្ត។ កំណត់សំគាល់ណែនាំក្នុងជំពូកនិមួយៗទាក់ទងនឹងចំនុចជាក់លាក់ដែលគួរតែពិចារណា នៅពេលអនុវត្ត ស្តង់ដា នៅក្នុងស្ថានភាពផ្សេងៗគ្នា។ កំណត់សំគាល់ណែនាំផ្តល់យោបល់អំពីបញ្ហាអាទិភាពនិងការដោះស្រាយការលំបាកជាក់ស្តែងហើយអាចរៀបរាប់អំពីជំរើសពិបាក ភាពចំរូងចំរាស់ឬចន្លោះប្រហោងនៅក្នុងចំណេះដឹងបច្ចុប្បន្ន។ កំណត់សំគាល់ណែនាំទាក់ទងនឹងសូចនាករសំខាន់ៗ ជាក់លាក់ ហើយទំនាក់ទំនងទាំងនោះមានបង្ហាញនៅក្នុងអត្ថបទនេះ។ សូចនាករសំខាន់ៗគួរតែអាចអានជាមួយនឹងកំណត់សំគាល់ណែនាំដែលពាក់ព័ន្ធ។

វាមានសារៈសំខាន់ក្នុងការចងចាំថា គ្រប់ផ្នែកទាំងអស់សុទ្ធតែទាក់ទងគ្នាហើយជារឿយៗស្តង់ដាដែលរៀបរាប់ក្នុងផ្នែកមួយត្រូវតែអានជាមួយស្តង់ដាដែលរៀបរាប់ក្នុងផ្នែកដទៃទៀត។ នៅពេលសមស្របកំណត់សំគាល់ណែនាំបង្ហាញទំនាក់ទំនងទៅនឹងស្តង់ដា សូចនាករឬកំណត់សំគាល់ណែនាំពាក់ព័ន្ធផ្សេងទៀត។

## បញ្ហារួម

ក្នុងការបង្កើតស្តង់ដាអប្បបរមា យើងមានការប្រុងប្រយ័ត្នក្នុងការពិភាក្សាបញ្ហាសំខាន់ៗមួយចំនួន។ បញ្ហាទាំងនេះទាក់ទងនឹងសិទ្ធិមនុស្សនិងសិទ្ធិកុមារ យេនឌ័រ សិទ្ធិការចូលរួម ហ៊ីវ/អេដស៍ ពិការភាព និងភាពងាយរងគ្រោះ។ សមាសធាតុទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងស្តង់ដាដែលពាក់ព័ន្ធ ជាជាងរៀបរាប់នៅក្នុងផ្នែកដោយឡែកមួយ។

## វិសាលភាព និងព្រំដែន

ស្តង់ដាសំរាប់ផ្នែកផ្សេងៗគ្នាមិនស្ថិតនៅតែឯងទេៈ គឺវាទាក់ទងគ្នាទៅវិញទៅមក។ ទោះជាយ៉ាងនេះក្តីវាមានការប្រទាញប្រទង់ដោយជៀសមិនរួចរវាងការបង្កើតស្តង់ដាសាកលនិងលទ្ធភាពអនុវត្តស្តង់ដាទាំងនេះជាក់ស្តែង។ គ្រប់បរិបទទាំងអស់មានលក្ខណៈផ្សេងគ្នា។ សំរាប់ហេតុផលនេះ ដំណើរការអភិវឌ្ឍជាសាកលដែលប្រើដើម្បីបង្កើតស្តង់ដាទាំងនេះបានធានានូវការចូលរួមដ៏ទូលំទូលាយនៃបុគ្គលិកមនុស្សធម៌ អ្នកអប់រំ រដ្ឋាភិបាល អាជ្ញាធរអប់រំ តួអង្គសង្គមស៊ីវិល និងប្រជាជនរងគ្រោះមកពីប្រទេសនិងតំបន់ផ្សេងៗ។

ក្នុងករណីខ្លះ កត្តាតំបន់អាចធ្វើឱ្យការអនុវត្តន៍ស្តង់ដាអប្បបរមានិងសូចនាករសំខាន់ៗមិនអាចសំរេចបាន។ នៅពេលករណីនេះកើតឡើង ចន្លោះរវាងស្តង់ដានិងតារាងសូចនាករនៅក្នុងសៀវភៅណែនាំនេះ ដែលសំរេចបានក្នុងការអនុវត្តន៍ជាក់ស្តែងត្រូវតែបានបរិយាយហើយមូលហេតុសំរាប់ចន្លោះប្រហោងនេះនិងអ្វីដែលត្រូវកែប្រែដើម្បីធ្វើឱ្យសំរេចស្តង់ដាទាំងនេះត្រូវតែពន្យល់ឱ្យបានច្បាស់។

ស្តង់ដាអប្បបរមានិងស្វែរធម្មនុញ្ញមនុស្សធម៌នឹងមិនដោះស្រាយគ្រប់បញ្ហាដែលឆ្លើយតបទៅនឹងការអប់រំទេ។ ទោះយ៉ាងនេះក្តីស្តង់ដានិងធម្មនុញ្ញនេះផ្តល់នូវឧបករណ៍មួយសំរាប់ទីភ្នាក់ងារមនុស្សធម៌ រដ្ឋាភិបាល និង ប្រជាជនក្នុងតំបន់ បង្កើនប្រសិទ្ធិភាពនិងគុណភាពនៃជំនួយខាងផ្នែកអប់រំរបស់ពួកគេ ហើយដូច្នេះដើម្បីធ្វើការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងជីវភាពនៃប្រជាជនដែលប៉ះពាល់ដោយគ្រោះមហន្តរាយ។

# ១. ស្តង់ដាអប្បបរមា ដែលទូទៅសំរាប់ គ្រប់ចំណាត់ថ្នាក់

## សេចក្តីផ្តើម

ផ្នែកនេះបរិយាយពិស្តារដំណើរការស្នូល៦ដែលមានសារៈសំខាន់សំរាប់ស្តង់ដាដទៃទៀតក្នុងសៀវភៅណែនាំនេះ។ ស្តង់ដាទាំងនេះគឺៈ (១) ការចូលរួមរបស់សហគមន៏ (២)ធនធានក្នុងមូលដ្ឋាន (៣)ការប៉ាន់ប្រមាណដំបូង (៤)យុទ្ធសាស្រ្តជំនួយ (៥)ការត្រួតពិនិត្យ និង (៦)ការវាយតម្លៃ។ ស្តង់ដាទាំងនេះ ត្រូវបានបង្ហាញជាពីរក្រុមតូចៗ ក្រោមចំណងជើង ការចូលរួមរបស់សហគមន៏ (ការចូលរួម និងធនធាន) និងការវិភាគ (ការប៉ាន់ប្រមាណ ជំនួយ ការត្រួតពិនិត្យនិងវាយតម្លៃ)។ ដោយអនុវត្តស្តង់ដាដែលរៀបរាប់នៅទីនេះ តួអង្គមនុស្សធម៌ និងសមាជិកសហគមន៏នឹងគាំទ្រការសំរេចស្តង់ដាទាំងនេះនៅផ្នែកការទទួលយក និងបរិស្ថានសិក្សា ការបង្រៀននិងការសិក្សា គ្រូនិងបុគ្គលិកសិក្សាដទៃទៀត និងគោលនយោបាយអប់រំ និងការសំរបសំរួល។

### ទំនាក់ទំនងទៅនឹងឧបករណ៍ផ្លូវច្បាប់ជាអន្តរជាតិ

បុគ្គលម្នាក់ៗមានសិទ្ធិរស់នៅដោយថ្លៃថ្នូរ និងទទួលបានការគោរពសិទ្ធិមនុស្សរបស់ពួកគេ រួមទាំងសិទ្ធិអប់រំ។ ទីភ្នាក់ងារមនុស្សធម៌មានការទទួលខុសត្រូវផ្តល់ជំនួយក្នុងលក្ខណៈដែលសមស្របនឹងសិទ្ធិមនុស្សរួមទាំងសិទ្ធិចូលរួមការមិនរើសអើងនិងការទទួលពត៌មាន ដូចដែលឆ្លុះបញ្ចាំងនៅក្នុងអត្ថបទសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌ និង ជនភៀសខ្លួន។ នៅក្នុងធម្មនុញ្ញនៃគម្រោងស្វែរ និងក្រមអនុវត្តនៃចលនាកាកបាទក្រហមនិងអឌ្ឍច័ន្ទក្រហមអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលក្នុងជំនួយគ្រោះអាសន្ន ទីភ្នាក់ងារមនុស្សធម៌ត្រូវតែទទួលខុសត្រូវចំពោះអ្នកដែលពួកគេព្យាយាមជួយ។ ស្តង់ដាទូទៅបញ្ជាក់អំពីការទទួលខុសត្រូវរបស់អង្គការ និងបុគ្គលនានានៅពេលផ្តល់ជំនួយអប់រំ។

## សារៈសំខាន់នៃស្តង់ដាទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់

វាមានសារៈសំខាន់ដែលផ្នែកដែលទាក់ទងនឹងការចូលរួមរបស់សហគមន៍និងការវិភាគត្រូវអានទុកជាមុន មុនពេលអានផ្នែកបច្ចេកទេសពាក់ព័ន្ធពីព្រោះស្តង់ដាដែលបង្ហាញនៅទីនេះគឺជាប្រព័ន្ធរួមមួយដែលមានស្តង់ដាអប្បបរមាទាំងអស់។ ការប្រមូលនិងការវិភាគទិន្នន័យអប់រំមានសារៈសំខាន់គ្រប់ដំណាក់កាលទាំងអស់នៃគ្រោះអាសន្ន។ នៅដំណាក់កាលចាប់ផ្តើមនៃវិបត្តិ ធនធាន តំរូវការ និងចន្លោះប្រហោងត្រូវតែកំណត់ដើម្បីបង្កើតកម្មវិធីនិងប្រើប្រាស់ធនធានឱ្យសមស្រប។

កម្មវិធីអប់រំក្នុងគ្រាមានអាសន្នមានប្រសិទ្ធិភាពដែលបំពេញតំរូវការនៃប្រជាជនដែលប៉ះពាល់ដោយគ្រោះអាសន្នត្រូវតែផ្អែកលើការយល់បរិបទច្បាស់លាស់។ ការប៉ាន់ប្រមាណដំបូង វិភាគលក្ខណៈនៃគ្រោះអាសន្ន និងផលប៉ះពាល់របស់វាមកលើប្រជាជន។ សមត្ថភាពនៃប្រជាជនរងគ្រោះនិងធនធានក្នុងមូលដ្ឋានដែលមានត្រូវតែកំណត់នៅពេលជាមួយការប៉ាន់ប្រមាណតំរូវការ និងភាពងាយរងគ្រោះរបស់ពួកគេ និងចន្លោះប្រហោងណាមួយនៅក្នុងសេវាកម្មសំខាន់ៗ។ ដើម្បីធានានូវប្រសិទ្ធិភាពនៃកម្មវិធី ការប៉ាន់ប្រមាណការអប់រំក្នុងគ្រាមានអាសន្នត្រូវតែរួមបញ្ចូលការចូលរួមមិនត្រឹមតែពីសហគមន៍ដែលប៉ះពាល់ដោយគ្រោះអាសន្នទេ ប៉ុន្តែថែមទាំងរដ្ឋាភិបាលមូលដ្ឋាននិងទីភ្នាក់ងារមនុស្សធម៌ដែលធ្វើការលើបញ្ហាអប់រំ និងមិនមែនអប់រំទៀតផង។ ការប៉ាន់ប្រមាណត្រូវតែពិចារណាការអប់រំក្នុង និងក្រៅប្រព័ន្ធសំរាប់គ្រប់ផ្នែកទាំងអស់នៃប្រជាជនផងដែរ។ ការអប់រំមិនអាចពិចារណាដាច់ដោយឡែកពីវិស័យផ្សេងទៀត ឬពីសេដ្ឋកិច្ច ជំនឿសាសនានិងប្រពៃណី ការអនុវត្តន៍ក្នុងសង្គម កត្តានយោបាយ និងសន្តិសុខ យន្តការប្រឈមមុខ ឬការព្យាករណ៍ការអភិវឌ្ឍន៍អនាគតបានទេ។ ការវិភាគមូលហេតុនិងផលប៉ះពាល់នៃគ្រោះអាសន្នមានសារៈសំខាន់។ បើបញ្ហាមិនត្រូវបានកំណត់ និងយល់ត្រឹមត្រូវ វានឹងពិបាក(ប្រសិនជាមិនអាច) ឆ្លើយតបដោយសមស្រប។

ជំនួយអាស្រ័យទៅលើកត្តាមួយចំនួន រួមមានសមត្ថភាព ជំនាញ ឧបសគ្គថវិកា ការស្គាល់តំបន់ ឬស្ថានការណ៍ របស់ទីភ្នាក់ងារមនុស្សធម៌ និងហានិភ័យផ្នែកសន្តិសុខសំរាប់បុគ្គលិកនិងអ្នកសិក្សា។ ស្តង់ដាជំនួយដែលបរិយាយនៅទីនេះត្រូវបានបង្កើតដើម្បីបញ្ជាក់ "នរណាធ្វើអ្វីនៅពេលណា"។ នៅពេលជំនួយសមស្របត្រូវបានកំណត់យន្តការសំរាប់កំណត់គោលដៅ គួរតែបង្កើតដើម្បីឱ្យទីភ្នាក់ងារអាចផ្តល់ជំនួយដោយស្មើភាពនិងដោយគ្មានការរើសអើងដែលសមស្របតាមតំរូវការ។

ប្រព័ន្ធត្រួតពិនិត្យដើម្បីប្រមូលនិងវិភាគពត៌មាន គួរតែបង្កើតក្នុងដំណាក់កាលដំបូងនៃដំណើរការដើម្បីវាស់ជាប្រចាំនូវការវិវត្តន៍ជាមួយគោលបំណងនិងដើម្បីពិនិត្យមើលភាពទាក់ទងនៃកម្មវិធីនៅក្នុងបរិបទនៃការវិវត្តន៍។ ការវាយតម្លៃដែលអាចធ្វើក្នុងកំឡុងពេលឬពេលបញ្ចប់ជំនួយ គួរតែធ្វើជាប្រចាំទៀងទាត់អាស្រ័យលើរយៈពេលនៃកម្មវិធីនិងគួរតែកំណត់ប្រសិទ្ធិភាពទូទៅនៃកម្មវិធី ដោយស្វែងរកមេរៀន/បទពិសោធន៍ដែលអាចកែលំអកម្មវិធីស្រដៀងគ្នានៅ

ពេលអនាគត។ ទីភ្នាក់ងារពាក់ព័ន្ធនិងអ្នកសិក្សាគួរតែចូលរួមយ៉ាងសកម្មក្នុងដំណើរការវាយតម្លៃ។ ដំណើរការមាតិកា និងលទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃ គួរតែមានតម្លាភាព និងផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់អ្នកទទួលផល និងទីភ្នាក់ងារពាក់ព័ន្ធដទៃទៀត ដោយមិនធ្វើឱ្យប៉ះពាល់ដល់សន្តិសុខអ្នកដែលពាក់ព័ន្ធ។ ក្នុងស្ថានភាពខ្លះពត៌មានមាន លក្ខណៈរសើបផ្នែកនយោបាយ ឬវប្បធម៌ សង្គម ដូច្នេះពត៌មាននិងទិន្នន័យដែលប្រមូលបានត្រូវតែចាត់ចែងដោយ ប្រយ័ត្នប្រយែង។

កម្មវិធីអប់រំក្នុងគ្រាមានអាសន្នដែលមានប្រសិទ្ធិភាពគឺផ្អែកលើការយល់លម្អិតអំពីសហគមន៍ដែលប៉ះពាល់ដោយវិបត្តិ និងការចូលរួមដ៏សកម្មរបស់សហគមន៍នៅក្នុងការបង្កើតកម្មវិធី។ ពាក្យ "ការចូលរួមរបស់សហគមន៍" សំដៅលើទាំង ដំណើរការនិងសកម្មភាពដែលអនុញ្ញាតឱ្យសមាជិកនៃក្រុមជនរងគ្រោះបញ្ចេញមតិ ដោយផ្តល់សិទ្ធិអំណាចដល់ពួកគេ ចូលរួមក្នុងដំណើរការសំរេចចិត្តនិងធ្វើឱ្យពួកគេបញ្ចេញសកម្មភាពដោយផ្ទាល់លើបញ្ហាអប់រំ។ មានកំរិតនៃការ ចូលរួមផ្សេងគ្នា: ការចូលរួមបែបនិមិត្តរូប ការពិគ្រោះយោបល់ និងការចូលរួមពេញលេញ។ ទោះបីការចូលរួមពេញ លេញតែងតែពិបាកសំរេចនៅក្នុងកាលៈទេសៈគ្រាអាសន្នក៏ដោយ ក៏ការពិគ្រោះយោបល់គឺជាគោលដៅអប្បបរមា សំរាប់ការអប់រំក្នុងគ្រាមានអាសន្ន ហើយការចូលរួមពេញលេញពីជនរងគ្រោះទាំងអស់គឺជាគោលបំណង។

បទពិសោធន៍បានបង្ហាញថាការចូលរួមបែបនិមិត្តរូបគឺជាឱកាសខាតបង់មួយហើយគ្មានប្រសិទ្ធិភាពក្នុងការផ្តល់កម្មវិធី ដែលមានគុណភាពនិងស្ថិតស្ថេរ។ ការចូលរួមរបស់សមាជិកសហគមន៍ដែលប៉ះពាល់ដោយគ្រោះអាសន្ន រួមទាំងក្រុម ដែលងាយរងគ្រោះ នៅក្នុងការប៉ាន់ប្រមាណ ការធ្វើផែនការ ការអនុវត្តន៍ ការគ្រប់គ្រង និងការត្រួតពិនិត្យជំនួយ គួរ តែមានកំរិតអតិបរិមាដើម្បីធានានូវភាពសមស្រប ប្រសិទ្ធិភាព និងគុណភាពនៃជំនួយគ្រោះអាសន្ន។ ការចូលរួមដ៏ សកម្មរបស់សហគមន៍ធ្វើឱ្យងាយស្រួលដល់ការកំណត់បញ្ហាអប់រំតាមសហគមន៍និមួយៗ និងយុទ្ធសាស្ត្រដែលមាន ប្រសិទ្ធិភាពសំរាប់ដោះស្រាយបញ្ហាទាំងនេះ។ លើសពីនេះ ការចូលរួមរបស់សហគមន៍ដើរតួជាយុទ្ធសាស្ត្រមួយដើម្បី ស្វែងរកនិងប្រមូលធនធានមូលដ្ឋាននៅក្នុងសហគមន៍ ព្រមទាំងបង្កើតការយល់ស្របរួមនឹងការគាំទ្រសំរាប់កម្មវិធី អប់រំ។ ការចូលរួមរបស់សហគមន៍ត្រូវតែរួមបញ្ចូលការផ្តល់សិទ្ធិអំណាច និងការកសាងសមត្ថភាព ពិតប្រាកដ និងមាន ចិរភាព ហើយត្រូវតែធ្វើបន្តពីកិច្ចខិតខំប្រឹងប្រែងដែលកំពុងតែដំណើរការ។

ការចែករំលែកចំណេះដឹងនិងពត៌មានដែលមានលក្ខណៈជាប្រព័ន្ធក្នុងចំណោមភាគីដែលពាក់ព័ន្ធក្នុងជំនួយ គឺជាមូលដ្ឋាន សំរាប់ការយល់ដឹងរួមអំពីបញ្ហានិងការសំរបសំរួលមានប្រសិទ្ធិភាពក្នុងចំណោមទីភ្នាក់ងារពាក់ព័ន្ធ។ ប្រព័ន្ធនិង វិធីសាស្ត្រប្រមូលនិងវិភាគទិន្នន័យដែលមានលក្ខណៈស្តង់ដាត្រូវតែជំរុញឱ្យមាន។ ប្រព័ន្ធនិងវិធីសាស្ត្របែបនេះ នឹងធ្វើ ឱ្យការចងក្រងជាឯកសារចែករំលែកនិងផ្សព្វផ្សាយពត៌មានមានលក្ខណៈងាយស្រួល។

**ស្តង់ដាអប្បបរមា:** ស្តង់ដាទាំងនេះមានលក្ខណៈបែបគុណវិស័យ ហើយបញ្ជាក់កំរិតអប្បបរមាដែលនឹងសំរេចក្នុងការផ្តល់ជំនួយអប់រំ។

**សូចនាករសំខាន់ៗ:** គឺជា "សញ្ញា" ដែលបង្ហាញថា តើស្តង់ដាត្រូវបានសំរេច ឬទេ។ សូចនាករទាំងនេះ ផ្តល់នូវវិធីមួយសំរាប់វាស់ និងបង្ហាញផលប៉ះពាល់ឬលទ្ធផលនៃកម្មវិធីព្រមទាំងដំណើរការឬវិធីសាស្រ្តដែលប្រើ។ សូចនាករទាំងនេះ អាចមានលក្ខណៈបែបគុណវិស័យ ឬបរិវិស័យ។

**កំណត់សំគាល់ណែនាំ:** រួមមានចំណុចជាក់លាក់ដើម្បីពិចារណានៅពេលអនុវត្តស្តង់ដា និងសូចនាករក្នុងស្ថានភាពផ្សេងគ្នា ការណែនាំអំពីការដោះស្រាយការលំបាកជាក់ស្តែង និងដំបូន្មានអំពីបញ្ហាអាទិភាព។ កំណត់សំគាល់ណែនាំអាចរួមបញ្ចូលផងដែរនូវបញ្ហាសំខាន់ៗដែលទាក់ទងនឹងស្តង់ដា និងសូចនាករ និងរៀបរាប់អំពីជំរើស ដែលពិបាកសំរេច ភាពចំរូងចំរាស់ ឬចន្លោះប្រហោងនៅក្នុងចំណេះដឹងបច្ចុប្បន្ន។ ឧបសម្ព័ន្ធ២ រួមមាន តារាងជ្រើសរើសឯកសារយោង ដែលបង្ហាញប្រភពពតិមានអំពីបញ្ហាទូទៅ និង បញ្ហាបច្ចេកទេសជាក់លាក់ ដែលទាក់ទងនឹងផ្នែកនេះ។

## ការចូលរួមរបស់សហគមន៍

### ស្តង់ដា១
**ការចូលរួម**

សមាជិកសហគមន៍ដែលប៉ះពាល់ដោយគ្រោះអាសន្នចូលរួមយ៉ាងសកម្មនៅក្នុងការប៉ាន់ប្រមាណ ធ្វើផែនការ អនុវត្ត ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីអប់រំ

### ស្តង់ដា២
**ធនធាន**

ធនធានសហគមន៍ក្នុងមូលដ្ឋានត្រូវបានកំណត់ ប្រមូល និងប្រើ ដើម្បីអនុវត្តកម្មវិធីអប់រំ និងសកម្មភាពសិក្សាដទៃទៀត

ឧបសម្ព័ន្ធ២: ឯកសារយោង និងមគ្គុទេសន៍ធនធាន

*ផ្អែកការចូលរួមរបស់សហគមន៍*

## ស្តង់ដាការចូលរួមរបស់សហគមន៍ ១: ការចូលរួម

សមាជិកសហគមន៍ដែលប៉ះពាល់ដោយគ្រោះអាសន្នចូលរួមយ៉ាងសកម្មក្នុងការប៉ាន់ប្រមាណធ្វើផែនការ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីអប់រំ ។

**សូចនាករសំខាន់ៗ** (ត្រូវអានជាមួយកំណត់សំគាល់ណែនាំ)

- សហគមន៍ដែលប៉ះពាល់ដោយគ្រោះអាសន្ន តាមរយៈតំណាងជ្រើសរើសរបស់ខ្លួន ចូលរួមក្នុងការកំណត់អាទិភាព និងធ្វើផែនការសកម្មភាពអប់រំដើម្បីធានានូវការផ្តល់កម្មវិធីអប់រំដែលមានប្រសិទ្ធិភាព (សូមមើលកំណត់សំគាល់ណែនាំ ១-៥) ។
- កុមារ និងយុវវ័យចូលរួមនៅក្នុងការបង្កើត និងអនុវត្តសកម្មភាពអប់រំ (សូមមើលកំណត់សំគាល់ណែនាំ៦) ។
- គណៈកម្មាធិការអប់រំសហគមន៍ (CEC) រៀបចំការប្រជុំសាធារណៈដើម្បីធ្វើសវនកម្មសង្គមនៃសកម្មភាពអប់រំ និងថវិការបស់សកម្មភាព (សូមមើលកំណត់សំគាល់ណែនាំ៧) ។
- ឱកាសបណ្តុះបណ្តាល និងកសាងសមត្ថភាពមានសំរាប់សមាជិកសហគមន៍ រួមទាំងកុមារ និងយុវវ័យ ដើម្បីគ្រប់គ្រងសកម្មភាពអប់រំ (សូមមើលកំណត់សំគាល់ណែនាំ៨) ។

**កំណត់សំគាល់ណែនាំ**

១. ***ការតំណាងរបស់សហគមន៍នៅក្នុងកម្មវិធីអប់រំ:*** ទូទាំងស្តង់ដាអប្បរមា ពាក្យ"គណៈកម្មាធិការអប់រំសហគមន៍" សំដៅទៅលើគណៈកម្មាធិការដែលបង្កើតឡើងដើម្បីកំណត់ និងដោះស្រាយតំរូវការអប់រំរបស់សហគមន៍ ដែលមាន តំណាងមកពី ឪពុក-ម្តាយ និង/ឬសមាគមន៍គ្រូ-អាណាព្យាបាលសិស្ស ទីភ្នាក់ងារក្នុងមូលដ្ឋាន សមាគមន៍សង្គមស៊ីវិល អង្គការសហគមន៍ និង ក្រុមស្ត្រីនិងយុវវ័យ ក្នុងចំណោមស្ថាប័នផ្សេងៗទៀត ព្រមទាំង គ្រូ និងសិស្ស (នៅពេលចាំ បាច់) ។ គណៈកម្មាធិការអប់រំសហគមន៍មួយអាចមានអនុគណៈកម្មាធិការ ដែលមានសមាជិកនៅក្នុងគណៈកម្មា ធិការ ។ ក្នុងករណីខ្លះ គណៈកម្មាធិការអប់រំសហគមន៍នឹងទទួលខុសត្រូវ កម្មវិធីអប់រំមួយ និងក្នុងករណី ខ្លះទៀត កម្មវិធីច្រើននៅក្នុងតំបន់កំណត់ណាមួយ ។
ទំនាក់ទំនងរវាងសាលាសហគមន៍ និងឪពុកម្តាយសិស្សត្រូវបានពង្រឹងក្នុងស្ថានភាពមានអាសន្នតាមរយៈការចូលរួមពីឪពុកម្តាយឬអាណាព្យាបាល ក្នុងការបង្កើតនិងគ្រប់គ្រងបរិស្ថានសិក្សា ។ រចនាសម្ព័ន្ធសំរាប់ទំនាក់ទំនង

រវាងគ្រួសារ សហគមន៍ និងសាលា គួរតែបង្កើតឡើងក្នុងលក្ខណៈពិគ្រោះយោបល់ និងមានការចូលរួម ។ លក្ខណៈនេះ អនុវត្តសំរាប់ការបង្កើតគណៈកម្មាធិការអប់រំសហគមន៍ សមាគមន៍ ឪពុកម្តាយសិស្ស-គ្រូ ។ល។ ព្រម ទាំងសំរាប់វិធានការណ៍ផ្សេងៗដែលចាំបាច់ដើម្បីដោះស្រាយបញ្ហា និងកាលៈទេសៈ ក្នុងមូលដ្ឋាន (ឧទាហរណ៏ គ្រួសារដែលមានកុមារជាមេផ្ទះ) ។ វិធីសាស្រ្តដែលផ្អែកលើសហគមន៍នឹងជួយបង្កើតរចនាសម្ព័ន្ធ (បើមិនទាន់ មាន) និងពង្រឹងរចនាសម្ព័ន្ធមានស្រាប់ ដែលគោរពវប្បធម៌និងទំនៀមទម្លាប់អប់រំក្នុងតំបន់ ដោយពឹងផ្អែកលើយន្តការប្រឈមមុខក្នុងមូលដ្ឋាន ។

២. ***គណៈកម្មាធិការអប់រំសហគមន៍:*** ការតំណាងគួរតែរួមបញ្ចូលក្រុមគ្រប់ប្រភេទ ដោយមានការចូលរួមពីក្រុមផ្សេងៗគ្នា និងស្ថាប័ននានា ដូចជា NGOsក្នុងស្រុក ស្ថាប័នសាសនា ចាស់ព្រឹទ្ធាចារ្យទាំងឡាយ ក្រុមដែលមានតំរូវការអប់រំជាពិសេស ក្រុមដែលងាយរងគ្រោះទាំងឡាយ ស្រ្តីនិងកុមារី បក្សសម្ព័ន្ធ កុលសម្ព័ន្ធ ក្រុមអាយុ ។ល ។ តំណាងគួរតែជ្រើសរើស តាមដំណើរការប្រជាធិបតេយ្យ ។ ក្នុងកំឡុងដំណាក់កាលការ ស្តារឡើងវិញ គណៈកម្មាធិការអប់រំសហគមន៍ គួរ តែត្រូវបានទទួលស្គាល់ និងចុះបញ្ជីតាមផ្លូវច្បាប់ ដើម្បី ដើរតួជាស្ថាប័ន ឬអង្គការផ្លូវការមួយ ។ នៅពេលគណៈកម្មាធិការអប់រំសហគមន៍ដែលមានតួនាទី និងការទទួលខុសត្រូវស្រដៀងគ្នាមានរួចហើយ គណៈកម្មាធិការទាំងនេះគួរតែកែសំរួលដើម្បីជៀសវាង ការបង្កើត ស្ថាប័នដូចគ្នា ។ គណៈកម្មាធិការអប់រំសហគមន៍ គួរតែរួមបញ្ចូលក្រុមគ្រប់ប្រភេទ និងមានតុល្យភាពហើយគួរតែឆ្លុះបញ្ចាំងភាពចម្រុះនៃប្រជាជនរងគ្រោះដែលបានរាប់បញ្ចូល ដោយមិនគិតទៅលើ ភេទ អាយុ ជនជាតិ ក្រុមសាសនា និងចំណាត់ថ្នាក់សង្គមជាដើម ។ វាមានសារៈសំខាន់ក្នុងការគាំទ្រស្រ្តីនិងកុមារីឱ្យក្លាយជាដៃគូស្មើភាពក្នុងការអភិវឌ្ឍន៏ ដោយបង្កើននិងធានាឱ្យមានសមធម៌ទាក់ទងនឹងការចូលរួមរបស់ពួកគេក្នុងគណៈកម្មាធិការអប់រំសហគមន៍ ។

៣. ***តួនាទីនិងការទទួលខុសត្រូវ***របស់គណៈកម្មាធិការអប់រំសហគមន៍គួរតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងផ្សព្វផ្សាយ ដល់សហគមន៍ ។ តួនាទីនិងការទទួលខុសត្រូវទាំងនេះ អាចមានចំនុចដូចខាងក្រោម តែមិនគិតនោះទេ:

- ប្រជុំជាប្រចាំដើម្បីពិភាក្សាបញ្ហានៃក្តីកង្វល់ និងដើម្បីធ្វើការសំរេចចិត្ត ។
- រក្សាកំណត់ហេតុនៃកិច្ចប្រជុំ ការសំរេចចិត្ត និងការរួមចំណែកហិរញ្ញវត្ថុនិងវិភាគទានផ្សេងៗរបស់សហគមន៍ ។
- ផ្តល់វិធីសាស្រ្តដែលសមស្របនឹងវប្បធម៌ (ឧទាហរណ៏ កាលវិភាគសិក្សាដែលអាចបត់បែនបាន កម្មវិធីសិក្សាដែលឆ្លុះបញ្ចាំងបរិបទក្នុងសហគមន៍ និងមានការចូលរួមពីសមាជិកសហគមន៍ ។ល ។) ។ និង
- ទំនាក់ទំនងជាមួយសហគមន៍ កម្មវិធីអប់រំ និង/ឬអាជ្ញាធរក្នុងតំបន់និងថ្នាក់ជាតិដើម្បីជំរុញឱ្យមានទំនាក់ទំនងល្អ រវាងកម្មវិធីអប់រំ និងសមាជិក សហគមន៍ផ្សេងៗទៀត ។

៤. ***ការចូលរួមរបស់សហគមន៍ក្នុងការបង្កើតជំនួយអប់រំ:*** ទីភ្នាក់ងាររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលគួរតែព្រមព្រៀងនិងបង្កើតដំណើរការសំរាប់ធានាការចូលរួមរបស់សហគមន៍ក្នុងការបង្កើតជំនួយអប់រំ ។ ដំណើរការទាំងនេះគួរតែជាផ្នែកមួយដ៏សំខាន់នៃជំនួយបន្ទាន់ចាប់តាំងពីថ្ងៃទីមួយ ហើយគួរតែរួមបញ្ចូលការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមដើម្បីបង្កើតភ្លាម១ទូវៈ

- តំរូវការអប់រំបន្ទាន់នៃអនុក្រុមផ្សេង១ ( កុមារ យុវវ័យ និងមនុស្សចាស់) ។
- សមត្ថភាពធនធានមនុស្ស និងពេលវេលាដែលមាន ព្រមទាំងធនធានហិរញ្ញវត្ថុនិងសម្ភារៈ ។
- ថាមភាពនៃអំណាចរវាងអនុក្រុម រួមទាំងក្រុមភាសា ។
- ការកំណត់សន្តិសុខ ។
- ទីតាំងសុវត្ថិភាពសំរាប់ការផ្តល់ការអប់រំ ។ និង
- យុទ្ធសាស្ត្រសំរាប់រួមបញ្ចូលសារអប់រំសង្គ្រោះជីវិតដែលទាក់ទងទៅក្នុងគ្រប់ទិដ្ឋភាពនៃជំនួយគ្រោះអាសន្ន ។ (សូមមើលផងដែរស្តង់ដាការវិភាគ២ កំណត់សំគាល់ណែនាំទី៥នៅទំព័រ៣០ ស្តង់ដាការវិភាគ៣នៅ ទំព័រ៣០ និងស្តង់ដាទី២គោលនយោបាយអប់រំ និងការសំរបសំរួលនៅទំព័រ១០៨) ។

៥. ***ផែនការសកម្មភាពអប់រំមូលដ្ឋាន:*** សហគមន៍ និងគណៈកម្មាធិការអប់រំសហគមន៍អាចកំណត់អាទិភាព និងធ្វើផែនការសកម្មភាពអប់រំតាមរយៈដំណើរការធ្វើផែនការក្នុងមូលដ្ឋានដែលមានការចូលរួមដែលឆ្លុះបញ្ចាំងតំរូវ ការក្តីកង្វល់ និងតម្លៃនៃប្រជាជនដែលប៉ះពាល់ដោយគ្រោះអាសន្ន ជាពិសេសអ្នកដែលនៅក្នុងក្រុមជនងាយ រងគ្រោះ ។ លទ្ធផលនៃដំណើរការធ្វើផែនការនេះគឺជាផែនការសកម្មភាពអប់រំដែលផ្អែកលើសហគមន៍ ។ ផែនការនេះផ្តល់ក្របខ័ណ្ឌមួយសំរាប់ការកែលំអគុណភាពកម្មវិធីនិងសេវាកម្មអប់រំក្នុងនិង/ឬក្រៅប្រព័ន្ធ ។ ផែនការសកម្មភាពអប់រំអាចមានគោលបំណងច្រើន តែមិនកំណត់ទេ ដូចជាៈ

- បង្កើតចក្ខុវិស័យរួមក្នុងចំណោមទីភ្នាក់ងារ អំពីអ្វីដែលបរិស្ថានសិក្សាអាចក្លាយទៅជា ដោយបែងចែងតាមរយៈសកម្មភាព សូចនាករ និងគោលដៅ ។
- ទទួលបានការព្រមព្រៀងនិងការប្តេជ្ញាចិត្តរួមក្នុងចំណោមទីភ្នាក់ងារ អំពីអាទិភាពសំរាប់ការកែលំអលក្ខខណ្ឌជាក់លាក់នៅក្នុងបរិស្ថានសិក្សា ។ និង
- បង្កើតផែនការសកម្មភាពដែលមានភារៈកិច្ចនិងការទទួលខុសត្រូវជាក់លាក់ដែលអ្នកពាក់ព័ន្ធផ្សេង១នឹងបំពេញក្នុងរយៈពេលកំណត់ណាមួយ ដើម្បីសំរេចគោលដៅដែលចែងនៅក្នុងផែនការ ។

  ផែនការសកម្មភាពអប់រំមូលដ្ឋាន គួរតែកំណត់តួនាទីសហការនៃភាគីពាក់ព័ន្ធទាំងអស់រួមមានទីភ្នាក់ងារ គាំទ្រគណៈកម្មាធិការអប់រំសហគមន៍និងអ្នកពាក់ព័ន្ធកម្មវិធីអប់រំ ។ ផែនការសកម្មភាពគួរតែបញ្ចូលផងដែរនូវក្រុមអនុវត្តដើម្បីធានានូវការប៉ាន់ប្រមាណ និងត្រួតពិនិត្យរបស់សហគមន៍ជាប្រចាំ និងជួយបង្កើតវប្បធម៌នៃការចូលរួមដើម្បីឱ្យមានការចូលរួមពីសហគមន៍ទូលំទូលាយនិងមានចិរភាព ។ វប្បធម៌នេះអាចរួមមាន ការធ្វើផែនការ

ការការពារកុមារ ការជំរុញការចូលរួមរបស់ស្ត្រីនិងកុមារី និងជនងាយរងគ្រោះ ការអនុវត្តន៍សកម្មភាពបង្រៀន និង រៀន ការត្រួតពិនិត្យ ការប្រមូលធនធាន ការជ្រើសរើសនិងបណ្តុះបណ្តាលបុគ្គលិក ការកសាងនិងថែទាំហេដ្ឋារចនាសម្ព័ន្ធ ការសំរបសំរួលជាមួយទីភ្នាក់ងារពាក់ព័ន្ធនិងការរួមបញ្ចូលជាមួយផ្នែកសុខភាពអនាម័យ អាហារូបត្ថម្ភ ការផ្គត់ផ្គង់ទឹកនៅពេលចាំបាច់ ។

វាមានសារៈសំខាន់ដែលសមាជិកសហគមន៍ទាំងអស់ទទួលបានពត៌មានដើម្បីឱ្យពួកគេផ្តល់មតិយោបល់ដល់គណៈកម្មាធិការអប់រំសហគមន៍អំពីវិធីគ្រប់គ្រងកម្មវិធីអប់រំឱ្យមានប្រសិទ្ធិភាព (សូមមើលផងដែរស្តង់ដាទី២ នៃគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត នៅទំព័រ៩៥ និងស្តង់ដាទី៣នៃគោលនយោបាយអប់រំ និងការសំរបសំរួលនៅ ទំព័រ១១០) ។

៦. ***ការចូលរួមរបស់កុមារនៅក្នុងសកម្មភាពអប់រំ:*** មាត្រា១៣នៃអនុសញ្ញាអំពីសិទ្ធិកុមារ (CRC) របស់អ.ស.ប ផ្តល់កុមារនូវសិទ្ធិមានមតិយោបល់នៅក្នុងបញ្ហាដែលប៉ះពាល់ជីវិលផ្ទាល់របស់ពួកគេ ដើម្បីរៀបចំសំរាប់ការទទួលខុសត្រូវរបស់ពួកគេនៅពេលពេញវ័យ ។ មាត្រានេះអាចអនុវត្តបានចំពោះគ្រប់កុមារក្នុងគ្រប់ស្ថានភាពមានអាសន្ន រួមទាំងក្នុងគ្រាមានវិបត្តិរ៉ាំរ៉ៃនិងដំណាក់កាលដំបូងនៃការស្តារឡើងវិញ ។

អ្នកសិក្សា ជាពិសេសយុវវ័យនិងមនុស្សចាស់គួរតែចូលរួមក្នុងការបង្កើតនិងគ្រប់គ្រងប្រព័ន្ធដែលផ្តល់ការអប់រំដល់ពួកគេ ។ កុមារត្រូវតែបានបណ្តុះបណ្តាលអំពីការអនុវត្តន៍ដែលជួយការពារពួកគេនិងកុមារដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ ។ ការបណ្តុះបណ្តាលនេះគួរតែសង្កត់ធ្ងន់លើសមត្ថភាពរបស់ពួកគេក្នុងការចូលរួមដោយស្ថាបនានិងផ្តួចផ្តើមការផ្លាស់ប្តូរវិជ្ជមាន ឧទាហរណ៍ការស្នើឱ្យមានការកែលំអសកម្មភាពសាលា ឬការរាយការណ៍ ការការពារការរំលោភបំពានក្នុងបរិស្ថានសាលា (សូមមើលផងដែរស្តង់ដាទី២នៃការទទួលយក និងបរិស្ថានសិក្សា នៅទំព័រ៦០ និងស្តង់ដាទី៣នៃគ្រូបង្រៀននិងបុគ្គលិកអប់រំដទៃទៀតនៅទំព័រទី៩៧) ។

ភារៈកិច្ចដែលកើតមានក្នុងគ្រាមានអាសន្ន (ឧទាហរណ៍ ការផ្តល់សកម្មភាពកំសាន្តសំរាប់កុមារ និងយុវវ័យអាចប្រើបានដើម្បីឱ្យកុមារនិងយុវវ័យ (ជាពិសេសអ្នកដែលមិនរៀន) ចូលរួមក្នុងសកម្មភាពដែលមានសារៈសំខាន់សំរាប់សហគមន៍ ។ សកម្មភាពនេះផ្តល់ឱ្យពួកគេនូវជំរើសវិជ្ជមានជំនួសឱ្យឥទ្ធិពល អវិជ្ជមាន ដូចជាឧក្រិដ្ឋកម្ម ក្រុមប្រដាប់អាវុធ ។ល ។

៧. ***សវនកម្មសង្គម*** គឺជាការវាយតម្លៃអំពីកម្មវិធីអប់រំដោយផ្អែកលើសហគមន៍ ។ ការវាយតម្លៃនេះគួរតែធ្វើ ដើម្បីប៉ាន់ប្រមាណធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភារៈ កំណត់អ្វីដែលនៅតែត្រូវការ និងអ្វីដែលមានរួចហើយ និងត្រួតពិនិត្យប្រសិទ្ធិភាពនៃកម្មវិធីក្នុងចំណោមទិដ្ឋភាពផ្សេងៗទៀត ។ វាតែងតែមិនអាចធ្វើសវនកម្មសង្គមបានទេក្នុងដំណាក់កាលដំបូង ឬពាក់កណ្តាលនៃគ្រាមានអាសន្ន ។ ទោះយ៉ាងនេះក្តី នៅពេលគ្រាអាសន្នមានស្ថេរភាព (ឧទាហរណ៍ នៅដំណាក់កាលវិបត្តិរ៉ាំរ៉ៃយូរអង្វែង ឬដំណាក់កាលដំបូងនៃការស្តារឡើងវិញ) សវនកម្មសង្គមផ្តល់

សហគមន៍នូវឱកាសមួយដើម្បីកសាងសមត្ថភាពរបស់ពួកគេសំរាប់ត្រួតពិនិត្យកម្មវិធីអប់រំរបស់ពួកគេឱ្យកាន់តែមានប្រសិទ្ធិភាព (សូមមើលផងដែរ ស្តង់ដាការវិភាគទី៤ នៅទំព័រ៣៣)។

៨. ***ការកសាងសមត្ថភាព:*** វាមិនមានលក្ខណៈជាក់ស្តែងទេ ដែលរំពឹងថាសមាជិកសហគមន៍មានសមត្ថភាពបច្ចេកទេសគ្រប់គ្រង និងចាត់ចែងសកម្មភាពអប់រំដោយគ្មានការណែនាំនិងបណ្តុះបណ្តាលសមស្រប និងគ្រប់គ្រាន់។ កម្មវិធីបណ្តុះបណ្តាល គួរតែប៉ាន់ប្រមាណសមត្ថភាពរបស់សហគមន៍និងកំណត់តំរូវការបណ្តុះបណ្តាលនិងវិធីដើម្បីបំពេញតំរូវការទាំងនេះ។ បន្ថែមលើការកសាងសមត្ថភាពសំរាប់សមាជិកគណៈកម្មាធិការអប់រំសហគមន៍ កម្មវិធីអប់រំគួរតែឱ្យមានការចូលរួមពីសមាជិកសហគមន៍នៅក្នុងការងារនៃកម្មវិធីអប់រំនិងផ្តល់ការបណ្តុះបណ្តាលដើម្បីពង្រឹងគុណភាពនិងនិរន្តភាពនៃការគាំទ្ររបស់ពួកគេ។

## ការចូលរួមរបស់សហគមន៍ ស្តង់ដាទី២: ធនធាន

ធនធានសហគមន៍ក្នុងមូលដ្ឋានត្រូវបានកំណត់ ប្រមូល និងប្រើដើម្បីអនុវត្តកម្មវិធីអប់រំ និងឱកាសសិក្សាដទៃទៀត។

**សូចនាករសំខាន់ៗ** (ត្រូវអានជាមួយកំណត់សំគាល់ណែនាំ)

- សហគមន៍ បុគ្គលិកអប់រំនិងអ្នកសិក្សាកំណត់ធនធានអប់រំនៅក្នុងសហគមន៍ (សូមមើល កំណត់សំគាល់ណែនាំ១)។
- ធនធានសហគមន៍ត្រូវបានប្រមូលដើម្បីពង្រឹងការទទួលយកការអប់រំ ការការពារ និងគុណភាពនៃកម្មវិធីអប់រំ (សូមមើលកំណត់សំគាល់ណែនាំ២-៣)។
- អ្នកពាក់ព័ន្ធទទួលស្គាល់ និងគាំទ្រសមត្ថភាពរបស់សហគមន៍ ហើយកម្មវិធីអប់រំត្រូវបានបង្កើតដើម្បីប្រើសមត្ថភាព និងជំនាញក្នុងមូលដ្ឋានជាអតិបរមា (សូមមើលកំណត់សំគាល់ណែនាំ៤-៥)។

### កំណត់សំគាល់ណែនាំ

១. ***ធនធានសហគមន៍*** រួមមានធនធានមនុស្ស បញ្ញា ហិរញ្ញវត្ថុ ឬសម្ភារៈដែលមាននៅក្នុងសហគមន៍។ ការប្រមូលធនធានគួរតែផ្សារភ្ជាប់ទៅនឹងការកែលំអគុណភាពនៃបរិស្ថានសិក្សា។ បរិស្ថានសិក្សាអាចរួមបញ្ចូល បរិស្ថាន

រូបវ័ន្ត (ឧទាហរណ៍ វិភាគទានសម្ភារៈ និងកម្លាំងពលកម្មចំពោះការសាងសង់ ថែទាំ និងជួសជុលសាលា) និងបរិស្ថានផ្លូវចិត្តនិងផ្លូវអារម្មណ៍ (ឧទាហរណ៍ ការគាំទ្រផ្នែកចិត្តសាស្រ្ត-សង្គមសំរាប់សិស្ស និងគ្រូ /អ្នកសំរបសំរួលឬការដោះស្រាយបញ្ហាការការពារ)។ គួរតែរក្សាកំណត់ហេតុដើម្បីពង្រឹងតម្លាភាពនិងគណនេយ្យភាព (សូមមើលផងដែរស្តង់ដាទី២-៣នៃការទទួលយក និងបរិស្ថានសិក្សា នៅទំព័រ៦០-៦៣)។

២. ***ការពង្រឹងការទទួលយក និងសន្តិសុខៈ*** សមាជិកសហគមន៍គួរតែត្រូវបានគៀងគរឱ្យលះបង់ពេលវេលានិងធនធានដើម្បីជួយកុមារងាយរងគ្រោះចុះឈ្មោះចូលរៀននិងមករៀនទៀងទាត់ ឧទាហរណ៍ តាមរយៈគំនិតផ្តួចផ្តើមដោយក្រុមស្រ្តី និងយុវជន ដើម្បីផ្តល់សម្លៀកបំពាក់សមរម្យសំរាប់កុមារមកពីគ្រួសារក្រីក្របំផុត ឬដើម្បីផ្តល់អាហារដល់គ្រួសារដែលមានកុមារជាមេផ្ទះ។ ស្រ្តីអាចគាំទ្រការចូលរួមរបស់កុមារីនៅតាមសាលាដោយដើរតួជាជំនួយការក្នុងថ្នាក់ ផ្តល់ការការពារពីការរំលោភបំពាន ហើយសមាជិកសហគមន៍អាចចំណាយពេលវេលានាំកុមារទៅកាន់និងមកពីសាលានៅពេលចាំបាច់(សូមមើលផងដែរស្តង់ដាទី២-៣នៃការទទួលយក និងបរិស្ថានសិក្សា នៅទំព័រ៦០-៦៣)។

៣. ***ការបង្កើតនិរន្តភាពៈ*** សហគមន៍គួរតែត្រូវបានផ្តល់ការបណ្តុះបណ្តាលអំពីតួនាទីនិងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបរិស្ថានសិក្សា ការប្រមូលនិងការគ្រប់គ្រងធនធាន និងនិរន្តភាព (ឧទាហរណ៍ ការថែទាំសម្ភារៈ វិធានការណ៍ ពិសេសដើម្បីធានាឱ្យមានការចូលរួមពីសិស្សដែលងាយរងគ្រោះ ។ល។) ក្នុងរយៈពេលវែង។

៤. ***ការទទួលស្គាល់វិភាគទានរបស់សហគមន៍៖*** របាយការណ៍ទៅកាន់ទីភ្នាក់ងារផ្តល់ជំនួយគួរតែបញ្ចូលពតិមានទាំងផ្នែកបរិមាណ និង គុណភាពអំពីការរួមចំណែករបស់សហគមន៍។ ការរួមចំណែកដ៏ខ្លាំងក្លារបស់សហគមន៍អាចបញ្ជាក់អំពី ការប្តេជ្ញាចិត្ត និងនិរន្តភាពដែលអាចមានសំរាប់កម្មវិធី។

៥. ***សមត្ថភាពក្នុងមូលដ្ឋាន*** : ការចូលរួមនៅក្នុងជំនួយគួរតែពង្រឹងសេចក្តីថ្លៃថ្នូរ និងក្តីសង្ឃឹមរបស់ប្រជាជនក្នុងពេលមានវិបត្តិ។ កម្មវិធីគួរតែបង្កើតដោយផ្អែកលើសមត្ថភាពក្នុងមូលដ្ឋាននិងជៀសវាងមើលស្រាលយុទ្ធសាស្រ្តប្រឈមមុខរបស់ពួកគេ។

# ការវិភាគ

## ស្តង់ដា១ ការប៉ាន់ប្រមាណគ្រាដំបូង

ការប៉ាន់ប្រមាណទាន់ពេលវេលាអំពីការអប់រំនៃស្ថានភាពមានអាសន្ន ត្រូវបានធ្វើក្នុងលក្ខណៈរួម និងមានការចូលរួម។

## ស្តង់ដា២ យុទ្ធសាស្ត្រជំនួយ

ក្របខ័ណ្ឌសំរាប់ជំនួយអប់រំ ត្រូវបានបង្កើតឡើងដោយមានការបរិយាយច្បាស់លាស់អំពីបញ្ហា និងយុទ្ធសាស្ត្រដែលបានកត់ត្រាសំរាប់ធ្វើសកម្មភាព

## ស្តង់ដា៣ ការត្រួតពិនិត្យ

អ្នកពាក់ព័ន្ធទាំងអស់ត្រួតពិនិត្យជាប្រចាំពីសកម្មភាពជំនួយអប់រំ និងការប្រែប្រួលពីតំរូវការអប់រំរបស់ប្រជាជនដែលរងគ្រោះ។

## ស្តង់ដា៤ ការវាយតម្លៃ

មានការវាយតម្លៃដែលមានលក្ខណៈជាប្រព័ន្ធ និងដោយយុត្តិធម៌អំពីជំនួយអប់រំដើម្បីកែលំអការអនុវត្តន៍ និងពង្រឹងគណនេយ្យភាព។

បរិសិទ្ធ១ (Appendix 1)

*ក្របខ័ណ្ឌប៉ាន់ប្រមាណ*

បរិសិទ្ធ២

*ការធ្វើផែនការក្នុងគ្រាមានអាសន្នៈ តារាងពិនិត្យការវិភាគស្ថានភាព*

បរិសិទ្ធ៣

*ទំរង់ ការប្រមូលព័តិមាន និង ការប៉ាន់ប្រមាណតំរូវការ*

ឧបសម្ព័ន្ធ២ៈ ឯកសារយោង និងមគ្គុទេសន៍ធនធាន

*ផ្នែកការវិភាគ*

# ស្តង់ដាការវិភាគ ១: ការប៉ាន់ប្រមាណគ្រាដំបូង

ការប៉ាន់ប្រមាណទាន់ពេលវេលាអំពីការអប់រំនៃស្ថានភាពមានអាសន្នត្រូវបានធ្វើក្នុងលក្ខណៈរួម និងមានការចូលរួម ។

**សូចនាករសំខាន់ៗ** ( ត្រូវអានជាមួយកំណត់សំគាល់ណែនាំ)

- ការប៉ាន់ប្រមាណអំពីការអប់រំយ៉ាងរហ័សនាគ្រាដំបូង ត្រូវបានធ្វើភ្លាមៗតាមដែលអាចធ្វើទៅបាន ដោយពិចារណាអំពីសន្តិសុខ និងសុវត្ថិភាព( សូមមើលកំណត់សំគាល់ណែនាំ១-៣) ។

- អ្នកពាក់ព័ន្ធសំខាន់ៗចូលរួមនៅក្នុងការកំណត់ទិន្នន័យដែលត្រូវប្រមូល ការបង្កើត បកស្រាយ និងកែលំអសូចនាករ និងការគ្រប់គ្រង និងផ្សព្វផ្សាយពតិមាន( សូមមើលកំណត់សំគាល់ណែនាំ៤-៥) ។

- ការប៉ាន់ប្រមាណដ៏ទូលំទូលាយអំពីតំរូវការអប់រំ និងធនធានសំរាប់ក៏រិត និងប្រភេទនៃការអប់រំផ្សេងៗគ្នា និងសំរាប់តំបន់ដែលប៉ះពាល់ដោយគ្រោះអាសន្ន ត្រូវបានធ្វើដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មដោយទៀងទាត់ ( សូមមើលកំណត់សំគាល់ណែនាំ៤) ។

- ការអប់រំជាផ្នែកមួយនៃការប៉ាន់ប្រមាណអន្តរវិស័យដែលប្រមូលទិន្នន័យអំពី ស្ថានភាពនយោបាយ សង្គម សេដ្ឋកិច្ច និងបរិស្ថានសន្តិសុខ និង ប្រជាសាស្ត្រ ព្រមទាំងធនធានដែលមានដើម្បីកំណត់សេវាកម្ម ដែលចាំបាច់សំរាប់ប្រជាជនរងគ្រោះ ( សូមមើលកំណត់សំគាល់ណែនាំ៦) ។

- ការប៉ាន់ប្រមាណ វិភាគ ឧបសគ្គដែលមាន និងអាចមានចំពោះការការពារអ្នកសិក្សា ដោយប្រើការប៉ាន់ប្រមាណហានិភ័យ វិភាគអំពីការគំរាមកំហែង ភាពងាយរងគ្រោះ និងសមត្ថភាព( សូមមើលកំណត់សំគាល់ណែនាំ៧) ។

- សមត្ថភាព ធនធាន និងយុទ្ធសាស្ត្រក្នុងមូលដ្ឋានសំរាប់ការសិក្សានិងអប់រំត្រូវបានកំណត់ទាំងមុន និងកំឡុងពេលគ្រោះអាសន្ន ។

- ការប៉ាន់ប្រមាណកំណត់ការយល់ឃើញរបស់សហគមន៏ អំពីគោលបំណង និងភាពទាក់ទងនៃការអប់រំ និងអំពីតំរូវការការអប់រំអាទិភាព និង សកម្មភាព ។

- ប្រព័ន្ធមួយត្រូវបានបង្កើតឡើង ដើម្បីចែករំលែកការរកឃើញនៃការប៉ាន់ប្រមាណ និងដើម្បីរក្សាទិន្នន័យអប់រំ (សូមមើល កំណត់សំគាល់ណែនាំ៨) ។

**កំណត់សំគាល់ណែនាំ**

១. ***ពេលវេលានៃការប៉ាន់ប្រមាណ*** គួរតែគិតអំពីសន្តិសុខ និងសុវត្ថិភាពនៃក្រុមវាយតម្លៃ និងប្រជាជនរងគ្រោះ ។ នៅពេលមានបញ្ហាផ្នែកសន្តិសុខ យុទ្ធសាស្រ្តដទៃទៀតគួរតែស្វែងរក ដូចជាប្រភពពតិមានប្រយោល អ្នកដឹកនាំក្នុងមូលដ្ឋាន និងបណ្តាញក្នុងសហគមន៏ ។ នៅពេលគ្មានបញ្ហាផ្នែកសន្តិសុខ ការប៉ាន់ប្រមាណលើកទីមួយគួរតែកែលំអដោយផ្អែកលើទិន្នន័យនិងពតិមានទូលំទូលាយថែមទៀតដែលប្រមូលបាន ។ ការប៉ាន់ប្រមាណគួរតែធ្វើបច្ចុប្បន្នកម្មជាទៀងទាត់ (យ៉ាងហោចណាស់រៀងរាល់៣ខែ) ដោយផ្អែកលើទិន្នន័យត្រួតពិនិត្យនិងវាយតម្លៃ ការពិនិត្យឡើងវិញនៃសមិទ្ធិផលនិងឧបសគ្គរបស់កម្មវិធី និងពតិមានអំពីតំរូវការដែលមិនបានបំពេញ ។

២. ***ការប្រមូលពតិមាន និងទិន្នន័យប៉ាន់ប្រមាណ*** គួរតែរៀបចំ និងធ្វើដើម្បីស្វែងយល់តំរូវការអប់រំ សមត្ថភាព ធនធាន និងចន្លោះប្រហោង ។ ការប៉ាន់ប្រមាណទូទៅមួយដែលគ្របដណ្តប់គ្រប់ប្រភេទនៃការអប់រំ និងគ្រប់តំបន់គួរតែត្រូវបញ្ចប់ភ្លាមៗតាមដែលអាចធ្វើទៅបាន ។ ប៉ុន្តែការប៉ាន់ប្រមាណនេះមិនគួរពន្យារការរៀបចំដោយរហ័សនៃផ្នែកខ្លះក្នុងការប៉ាន់ប្រមាណ ដើម្បីធ្វើសកម្មភាពភ្លាមៗនោះទេ ។ ទស្សនៈកិច្ចនៃអ្នកផ្តល់ការអប់រំផ្សេងៗគួរតែសំរបសំរួលនៅពេលអាចធ្វើទៅបាន ដើម្បីជៀសវាងទស្សនៈកិច្ចជាបន្តបន្ទាប់ដែលរំខានបុគ្គលិកក្នុងការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ។

ឧបករណ៏ប៉ាន់ប្រមាណទាំងផ្នែកគុណភាពនិងបរិមាណគួរតែសមស្របទៅនឹងស្តង់ដាអន្តរជាតិ គោលដៅ EFA និង គោលការណ៏ណែនាំដែលផ្អែកលើសិទ្ធិ ។ ភាពសមស្របនេះជួយភ្ជាប់គំនិតផ្តួចផ្តើមសាកលជាមួយសហគមន៏ក្នុងមូលដ្ឋាននិងពង្រឹងទំនាក់ទំនងនៅកំរិតមូលដ្ឋានទៅនឹងក្របខ័ណ្ឌនិងសូចនាករសកល ។ ទំរង់សំរាប់ប្រមូលទិន្នន័យគួរតែមានលក្ខណៈស្តង់ដាក្នុងប្រទេស ដើម្បីសំរបសំរួលគំរោងនៅកំរិតអន្តរភ្នាក់ងារនិងបន្ថយជាអប្បរមានូវតំរូវការពីអ្នកផ្តល់ពតិមាន ។ ទំរង់ទាំងនេះ គួរតែផ្តល់កន្លែងសំរាប់ពតិមានបន្ថែមដែលអ្នកឆ្លើយគិតថាមាន សារៈសំខាន់ ។

ការគិតអំពីក្រមសីលធមិគឺមានសារៈសំខាន់សំរាប់ទំរង់ប្រមូលទិន្នន័យទាំងអស់នៅក្នុងជំនួយមនុស្សធម៌ ។ ការប្រមូលពតិមានសំរាប់គោលបំណងណាក៏ដោយ រួមទាំងការត្រួតពិនិត្យ ការប៉ាន់ប្រមាណឬការស្ទង់មតិ

អាចធ្វើឱ្យអ្នកឆ្លើយមានគ្រោះថ្នាក់ និងមិនត្រឹមតែដោយតែលក្ខណៈរសើបនៃពតិមាន ដែលប្រមូលនោះទេថែមទាំងដោយសារគ្រាន់តែចូលរួមក្នុងដំណើរការនេះទៀតផង។ គោលការណ៍មូលដ្ឋាននៃការគោរព មិនធ្វើឱ្យមានគ្រោះថ្នាក់ និងមិនរើសអើង ត្រូវតែអនុវត្ត ហើយអ្នកដែលប្រមូលពតិមានមានការទទួលខុសត្រូវ ការពារ និងប្រាប់អ្នកឆ្លើយអំពីសិទ្ធិរបស់ពួកគេ។ សូមមើលឯកសារយោងអំពីការវិភាគនៅឧបសម្ព័ន្ធ២ សំរាប់ភ្ជាប់ទៅនឹងឯកសារ "ការការពារគឺជាអាទិភាព" សៀវភៅមគ្គុទេសន៍ សំរាប់បញ្ចូលការការពារទៅក្នុងការ ប្រមូលទិន្នន័យក្នុងជំនួយមនុស្សធម៌"។

៣. ***វិធីសាស្ត្រវិភាគ*** ដើម្បីកាត់បន្ថយជាអប្បបរមានូវភាពលំអៀង ទិន្នន័យគួរតែពិនិត្យមើលពីប្រភពច្រើនផ្សេងៗគ្នាពេលធ្វើការវិភាគ និងមុនពេលធ្វើសេចក្តីសន្និដ្ឋាន។ ការពិនិត្យមើលពីប្រភពច្រើនផ្សេងៗគ្នា គឺជាវិធីសាស្ត្រចំរុះសំរាប់ប្រមូល និងវិភាគទិន្នន័យដើម្បីវាស់ចំនុចដូច និងខុសគ្នានៃបាតុភូតមួយ ដែលនាំឱ្យមានការយល់ដឹងល្អិតល្អន់ ដើម្បីធានានូវភាពត្រឹមត្រូវនៃទិន្នន័យជាគុណភាព។ ការយល់ឃើញរបស់សហគមន៍ ក៏ត្រូវបញ្ចូលទៅក្នុងការវិភាគផងដែរ ដើម្បីជៀសវាងជំនួយមនុស្សធម៌ដែលផ្អែកលើតែការយល់ឃើញ នៃអ្នកខាងក្រៅ និងអាទិភាព។

៤. ***អ្នកពាក់ព័ន្ធគួរតែរួមបញ្ចូល*** បុគ្គលមកពីក្រុមជនរងគ្រោះច្រើនតាមតែអាចធ្វើទៅបាន។ ការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការប្រមូលទិន្នន័យ និងការវិភាគ និងការគ្រប់គ្រង ពតិមាន និងផ្សព្វផ្សាយពតិមានអាចត្រូវបានកំហិតដោយកាលៈទេសៈក្នុងកំឡុងពេលធ្វើការប៉ាន់ប្រមាណដំបូង ប៉ុន្តែគួរតែបង្កើនក្នុងកំឡុងពេលធ្វើការ ប៉ាន់ប្រមាណលើកក្រោយ និងការត្រួតពិនិត្យ និងវាយតម្លៃ។

៥. ***របកគំហើញនៃការប៉ាន់ប្រមាណ*** គួរតែផ្សព្វផ្សាយភ្លាមៗតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើផែនការសកម្មភាព។ ទិន្នន័យមុនវិបត្តិ និងការប៉ាន់ប្រមាណក្រោយវិបត្តិ ដែលកំណត់តំរូវការ និងធនធានអប់រំ (ឧទាហរណ៍ ដោយអាជ្ញាធរ NGOs ទីភ្នាក់ងារជំនាញនៅក្នុងសហគមន៍មនុស្សធម៌ និងសហគមន៍ក្នុងមូលដ្ឋាន) គួរផ្សព្វផ្សាយភ្លាមៗ ដល់ទីភ្នាក់ងារទាំងអស់។ ការផ្សព្វផ្សាយនេះមានសារៈសំខាន់ពិសេស បើទីភ្នាក់ងារមិនអាចចូលដល់តំបន់គោលដៅក្នុងកំឡុងពេលមានគ្រោះអាសន្ន។

៦. ***ការប៉ាន់ប្រមាណគ្រោះអាសន្នទូទៅ*** គួរតែរួមបញ្ចូលអ្នកជំនាញអប់រំ ឬអ្នកការពារកុមារម្នាក់នៅក្នុងក្រុមសង្គ្រោះបន្ទាន់ ដើម្បីប្រមូលទិន្នន័យអំពីការអប់រំ តំរូវការការពារកុមារ និងធនធាន។ ទីភ្នាក់ងារ គួរតែកំណត់ធនធាន និងបង្កើនសមត្ថភាពអង្គការ និងបុគ្គលិកដើម្បីអនុវត្តសកម្មភាពទាំងនេះ។

៧. ***ការវិភាគពីគ្រោះថ្នាក់*** : វាមានសារៈសំខាន់ក្នុងការពិចារណាគ្រប់ទិដ្ឋភាពនៃស្ថានភាពដែលអាចប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់កុមារ និងយុវវ័យ ពីព្រោះការអប់រំអាចមានការការពារ និង/ឬ កត្តាគ្រោះថ្នាក់។ ការប៉ាន់ប្រមាណ គួរតែបញ្ចូលបញ្ជីឬតារាងគ្រោះថ្នាក់("តារាងគ្រោះថ្នាក់") ដែលគួរតែកត់ត្រាសំរាប់ក្រុមអាយុផ្សេងៗ និងក្រុមងាយរងគ្រោះ នូវគ្រោះថ្នាក់ទាក់ទងនឹងកត្តា ដូចជា គ្រោះថ្នាក់ធម្មជាតិ និងគ្រោះបរិស្ថាន គ្រាប់មីន និងគ្រាប់ មីនមិនទាន់ផ្ទុះ សុវត្ថិភាពនៃអាគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ការការពារកុមារ និងសន្តិសុខ ភាពតំរាម កំហែងចំពោះសុខភាព ផ្លូវចិត្ត និង ផ្លូវកាយ បញ្ហាទាក់ទងនឹងលក្ខណៈសម្បត្តិរបស់គ្រូ ការចុះឈ្មោះចូលរៀននិងកម្មវិធីសិក្សា និងពត៌មានពាក់ព័ន្ធដទៃទៀត (សំរាប់តារាងគ្រោះថ្នាក់គំរូ សូមមើល CD-ROM MSEE)។

ការប៉ាន់ប្រមាណគួរតែបញ្ជាក់ពីយុទ្ធសាស្រ្តគ្រប់គ្រងគ្រោះថ្នាក់ សំរាប់ធ្វើការការពារ ការកាត់បន្ថយ និងសកម្មភាពដែលទាក់ទងនឹងគ្រោះអាសន្ន (ការត្រៀមជំនួយ ការកសាង និងស្តារឡើងវិញ) ក្នុងកំឡុងពេលព្រឹត្តិការណ៍ គ្រោះធម្មជាតិ ឬគ្រោះអាសន្នធ្ងន់ធ្ងរ។ ក្នុងកាលៈទេសៈខ្លះ យុទ្ធសាស្រ្តនេះ អាចតំរូវឱ្យមជ្ឈមណ្ឌលអប់រំនិមួយៗ គួរតែត្រៀមរៀបចំផែនទីមួយបង្ហាញពីភាពតំរាមកំហែងដែលអាចមាននិងរំលេចកត្តាដែលប៉ះពាល់ដល់ភាពងាយរងគ្រោះរបស់ខ្លួន។

៨. ***ការចែករំលែករបកគំហើញនៃការប៉ាន់ប្រមាណ*** គួរតែសំរបសំរួលដោយអាជ្ញាធរ ដែលពាក់ព័ន្ធនៅកំរិតមូលដ្ឋាន ឬថ្នាក់ជាតិ។ បើគ្មានអាជ្ញាធរមានសមត្ថកិច្ច ឬអង្គការណាធ្វើការនេះទេ ទីភ្នាក់ងារអន្តរជាតិនាំមុខមួយ ដូចជា ការិយាល័យសំរបសំរួលកិច្ចការមនុស្សធម៌នៃអ.ស.ប (OCHA) គួរតែតែងតាំងដើម្បីដឹកនាំយន្ត សំរបសំរួល និងចែករំលែកពត៌មាន។ ការចែករំលែករបកគំហើញនៃការប៉ាន់ប្រមាណគួរតែនាំឱ្យមានការ បង្កើតភ្លាមៗ នៃក្របខ័ណ្ឌស្ថិតិមួយ និងលទ្ធផលនៃទិន្នន័យដែលអ្នកពាក់ព័ន្ធទាំងអស់អាចប្រើបាន (សូមមើលផងដែរស្តង់ដាទី៣នៃគោលនយោបាយអប់រំ និងការសំរបសំរួល នៅទំព័រ១១០)។

## ស្តង់ដាការវិភាគ ២: យុទ្ធសាស្ត្រជំនួយ

ក្របខ័ណ្ឌសំរាប់ជំនួយត្រូវបានបង្កើត ដោយមានការបរិយាយដ៏ច្បាស់លាស់អំពីបញ្ហា និងយុទ្ធសាស្ត្រ ដែលបានកត់ត្រា សំរាប់ធ្វើសកម្មភាព ។

**សូចនាករសំខាន់ៗ** ( ត្រូវអានជាមួយកំណត់សំគាល់ណែនាំ)

- ទិន្នន័យមូលដ្ឋានត្រូវបានប្រមូលជាលក្ខណៈប្រព័ន្ធនៅពេលចាប់ផ្តើមកម្មវិធី ។
- យុទ្ធសាស្ត្រជំនួយអប់រំក្នុងគ្រាមានអាសន្នឆ្លុះបញ្ចាំងការយល់ដឹងដ៏ច្បាស់លាស់អំពីទិន្នន័យទូទៅ ( សូមមើលកំណត់សំគាល់ណែនាំ១-២) ។
- គោលដៅ និងសូចនាករសមស្របត្រូវបានកំណត់ដើម្បីត្រួតពិនិត្យផលប៉ះពាល់នៃជំនួយអប់រំទៅលើកុមារ យុវវ័យ និងសហគមន៍ទាំងមូល ។
- ពត៌មានដែលទទួលបានពីការប៉ាន់ប្រមាណត្រូវបានធ្វើបច្ចុប្បន្នកម្មជាមួយទិន្នន័យថ្មី ដែលបានមកពីការវិវត្តន៍របស់កម្មវិធីដែលកំពុងដំណើរការ ។
- យុទ្ធសាស្ត្រជំនួយអប់រំ ផ្តល់អាទិភាពទៅលើសុវត្ថិភាព និងសុខមាលភាពនៃកុមារនិងយុវវ័យទាំងអស់ រួមទាំងកុមារ និងយុវវ័យដែលងាយរងគ្រោះ ឬមានតំរូវការពិសេស ។
- យុទ្ធសាស្ត្រជំនួយអប់រំឆ្លើយតបជាប្រចាំនូវតំរូវការនៃប្រជាជនដែលប៉ះពាល់ដោយគ្រោះអាសន្ន សំរាប់ការអប់រំ ដែលមានគុណភាព និងរួមបញ្ចូលគ្រប់ក្រុម និងជួយពង្រឹងកម្មវិធីអប់រំថ្នាក់ជាតិ( សូមមើលកំណត់សំគាល់ណែនាំ ៤-៦) ។

**កំណត់សំគាល់ណែនាំ**

១. ***សំណើសុំសំរាប់ជំនួយ*** គួរតែធានាថាសកម្មភាពសំខាន់ៗត្រូវតែមានថវិកា ដោយមានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបំពេញស្តង់ដាអប្បបរមាដែលរៀបរាប់នៅទីនេះ ។ សំណើគួរតែបញ្ជាក់ថាតើសកម្មភាពអប់រំណាមួយធ្វើនៅតំបន់ណាដោយប៉ាន់ស្មានក៏រិតគ្របដណ្តប់សំរាប់តំរូវការនៃការប៉ាន់ប្រមាណសំរាប់ក៏រិត និងប្រភេទផ្សេងៗនៃការ អប់រំ

ព្រមទាំងបញ្ជាក់ថាតើមានអង្គការផ្សេងទៀតនឹងជួយបំពេញតំរូវការដែលនៅសល់ឬទេ ។ គួរតែមានភាពបត់បែនឱ្យបានច្រើនតាមតែអាចធ្វើទៅបានដើម្បីឆ្លើយតបតំរូវការអប់រំជាក់ស្តែង បើតំរូវការនោះច្រើនជាងការប៉ាន់ប្រមាណ ។ គួរតែខិតខំបង្កើននិរន្តភាពនិងសុខដុមនីយកម្មរវាងអង្គការនានានៅពេល កំណត់កំរិត និងប្រភេទ នៃការចំណាយលើការអប់រំក្នុងគ្រាមានអាសន្ន( ឧទាហរណ៍ លើប្រាក់ខែបរិក្ខារ ។ល ។)

២. ***ការកសាងសមត្ថភាពសំរាប់ប្រមូល និងវិភាគទិន្នន័យ*** : សំណើសុំគួរតែរួមបញ្ចូលការកសាងសមត្ថភាពបុគ្គលិកជាពិសេសបុគ្គលិកក្នុងប្រទេស សំរាប់ការប្រមូល និងវិភាគទិន្នន័យមូលដ្ឋាន និងដើម្បីអនុវត្តការងារត្រួតពិនិត្យ និងវាយតម្លៃ ។ បញ្ហាទាំងនេះតែងតែមិនត្រូវបានគិតគូរពេញលេញក្នុងដំណើរការរៀបចំសំណើសុំ ។

៣. ***ការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្រ្ត:*** សំណើសុំជួយគួរតែពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មយ៉ាងហោចណាស់រៀងរាល់៣ខែក្នុងកំឡុងពេលមានអាសន្ននិងដំណាក់កាលដំបូងនៃការស្តារឡើងវិញ ។ សំណើសុំគួរតែគិតអំពីសមិទ្ធិផល បច្ចុប្បន្ន ការប្រែប្រួលនៃស្ថានភាពគ្រោះអាសន្ន និងការប៉ាន់ស្មានបច្ចុប្បន្ននៃតំរូវការដែលមិនទាន់បានបំពេញ ។ គោលបំណងគួរតែដើម្បីកែលំអជាប្រចាំនូវគុណភាពនិងវិសាលភាព ព្រមទាំងនិរន្តភាពរយៈពេលវែងនៅពេលដែលអាចអនុវត្តបាន ។

៤. ***ជំនួយនៃភ្នាក់ងារផ្តល់ជំនួយ:*** ភ្នាក់ងារផ្តល់ជំនួយគួរតែពិនិត្យឡើងវិញជាប្រចាំនូវគុណភាព និងវិសាលភាពនៃជំនួយអប់រំក្នុងគ្រាមានអាសន្ន រួមទាំងការចុះឈ្មោះចូលរៀន និងការសិក្សាជាប់លាប់នៃសិស្សមកពីក្រុមងាយ រងគ្រោះ ។ ភ្នាក់ងារផ្តល់ជំនួយគួរតែធានានូវឱកាសទទួលយកការអប់រំនៅក្នុងតំបន់ទាំងឡាយដែលប៉ះពាល់ ដោយគ្រោះអាសន្នផ្សេងៗគ្នា ។ ថវិកាគួរតែផ្តល់ដើម្បីឱ្យការអប់រំសំរាប់ប្រជាជនមូលដ្ឋាននៅក្នុងតំបន់ដែល ទទួលយកជនភៀសខ្លួន ឬជនផ្លាស់ទីលំនៅក្នុងស្រុកដើម្បីបំពេញស្តង់ដាអប្បបរមា (សូមមើលផងដែរការ ទទួលយក និងបរិស្ថាន សិក្សា ស្តង់ដាទី១ កំណត់សំគាល់ណែនាំ៨ នៅទំព័រ៥៩) ។

៥. ***ការពង្រឹងកម្មវិធីថ្នាក់ជាតិ*** : ជំនួយអប់រំក្នុងគ្រាមានអាសន្នជាពិសេសសំរាប់ប្រជាជនដែលមិនផ្លាស់ទីលំនៅ និងក្នុងកំឡុងពេលស្តារឡើងវិញ គួរតែធ្វើផែនការដើម្បីឱ្យសមស្របជាមួយនឹងការពង្រឹងកម្មវិធីអប់រំថ្នាក់ជាតិ រួមទាំងការធ្វើផែនការអប់រំក្នុងតំបន់និងថ្នាក់ជាតិ រដ្ឋាភិបាល ការគ្រប់គ្រង និងការគាំទ្រ និងបណ្តុះបណ្តាលវិក្រិត្យការ ។

៦. ***ការជំនះលើឧបសគ្គនៃអាណត្តិអង្គការ:*** អង្គការជំនួយដែលមានអាណត្តិមានកំរិត (ឧទាហរណ៍អាណត្តិកំរិតទៅនឹងកុមារឬជនភៀសខ្លួន និងមាតុភូមិនិវត្តន៍ដែលជោគជ័យ) គួរតែធានាថាជំនួយអប់រំរបស់ពួកគេសមស្របទៅនឹង ជំនួយរបស់រដ្ឋាភិបាល និងអង្គការដែលមានអាណត្តិទូលំទូលាយ ដើម្បីអាចបំពេញគ្រប់តំរូវការអប់រំ ។ យុទ្ធសាស្រ្ត អប់រំសំរាប់តំបន់រងគ្រោះនិមួយៗគួរតែតំរូវតាមតំរូវការអភិវឌ្ឍន៍កុមារតូច ព្រមទាំងតំរូវ ការនៃយុវវ័យ រួមទាំងការអប់រំមធ្យមសិក្សា ឧត្តមសិក្សា និងវិជ្ជាជីវៈ ការបណ្តុះបណ្តាលវិក្រិត្យការនិងការអប់រំផ្សេងទៀតដែលសមស្រប ។ យុទ្ធសាស្រ្តសំរាប់ការអភិវឌ្ឍន៍ការអប់រំនៅក្នុងតំបន់ដែលទទួល ជនមាតុភូមិនិវត្តន៍

គួរតែរួមបញ្ចូលការផ្តល់ការគាំទ្ររយៈពេលវែងចំពោះកម្មវិធីដែលបង្កើតដោយមានជំនួយពីអង្គការមនុស្សធម៌ដែលមានឧបសគ្គពេលវេលានៅក្នុងជំនួយរបស់ពួកគេ (ឧទាហរណ៍ ក្នុងការគាំទ្រមាតុភូមិនិវត្តន៍និងសមាហរណកម្មដំបូងនៃជនភៀសខ្លួន) ។

## ស្តង់ដាវិភាគទី៣: ការពិនិត្យតាមដាន (Monitoring)

អ្នកពាក់ព័ន្ធទាំងអស់ ត្រួតពិនិត្យជាប្រចាំពីសកម្មភាពជំនួយអប់រំ និងការប្រែប្រួល តំរូវការអប់រំរបស់ប្រជាជនរងគ្រោះ ។

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- ប្រព័ន្ធសំរាប់ពិនិត្យតាមដានជាប្រចាំ ទៅលើស្ថានភាពគ្រោះអាសន្នព្រមទាំងអន្តរាគមន៍នានានោះ គឺមានវត្តមាននៅទីកន្លែងនោះ ហើយក៏កំពុងតែដំណើរការដែរ (សូមអាន កំណត់សំគាល់ណែនាំ ១-២) ។
- ស្ត្រី បុរស កុមារ និង យុវវ័យ ដែលមកពីក្រុមរងគ្រោះទាំងអស់ត្រូវបានពិភាក្សាជាប្រចាំ ហើយពួកគេក៏កំពុងរួមចំនែកក្នុងសកម្មភាពត្រួតពិនិត្យតាមដានទាំងនោះដែរ (សូមអាន កំណត់សំគាល់ណែនាំទី ២) ។
- ទិន្នន័យអប់រំត្រូវបានប្រមែប្រមូលជាលក្ខណៈប្រព័ន្ធ ហើយយ៉ាងទៀងទាត់ដោយចាប់ផ្តើមប្រមែប្រមូលចាប់តាំងពីពតិមានមូលដ្ឋាន រហូតដល់ការតាមដានដល់ការផ្លាស់ប្តូរ និង និន្នាការបន្តបន្ទាប់មកទៀត (សូមអាន កំណត់សំគាល់ណែនាំទី 3-4)
- បុគ្គលិកសង្គ្រោះត្រូវបានទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រប្រមែប្រមូលទិន្នន័យ ព្រមទាំងការវិភាគទិន្នន័យទាំងនោះដើម្បីធានាឱ្យមានទំនុកចិត្តទៅលើទិន្នន័យ ហើយការវិភាគទិន្នន័យនោះទៀតសោតក៏ទទួលបានការផ្ទៀងផ្ទាត់ និងគួរឱ្យជឿជាក់បាន (សូមអាន កំណត់សំគាល់ណែនាំទី 5)
- ទិន្នន័យអប់រំត្រូវបានធ្វើការវិភាគ និងចែករំលែកជាមួយភ្នាក់ងារពាក់ព័ន្ធផ្សេងៗក្នុងកំឡុងវគ្គវិភាគនិមួយៗ ដែលបានកំណត់ទុកតាំងពីមុន (សូមអានកំណត់សំគាល់ណែនាំទី 3)
- ប្រព័ន្ធពិនិត្យតាមដាន និង តារាងទិន្នន័យត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ ដោយផ្អែកទៅលើមតិយោបល់ផ្សេងៗ ដើម្បីឆ្លុះបញ្ចាំងពីនិន្នាការថ្មីៗព្រមទាំងដើម្បីឱ្យមានការសំរេចចិត្តតាមរយៈការពិគ្រោះ ។

- ទិន្នន័យដែលកត់សំគាល់ពីបំលាស់ប្តូរពីនិន្នាការថ្មីៗពីតំរូវការ និងធនធានផ្សេងៗត្រូវបានផ្តល់ជាប្រចាំទៅដល់អ្នកគ្រប់គ្រងកម្មវិធីអប់រំ ។

- ប្រសិនបើចាំបាច់ការកែប្រែកម្មវិធីនឹងត្រូវបានធ្វើឡើងដោយអនុលោមទៅតាមលទ្ធផលនៃការពិនិត្យតាមដាន ។

**កំណត់សំគាល់ណែនាំ**

១. **ការពិនិត្យតាមដាន** គួរតែឆ្លុះបញ្ចាំងពីតំរូវការផ្នែកអប់រំបន្តបន្ទាប់របស់ក្រុមមនុស្សរងគ្រោះ ហើយវាក៏គួរតែឆ្លុះបញ្ចាំងពីវិសាលភាពដែលកម្មវិធីនានាបានឆ្លើយតបទៅលើតំរូវការទាំងនោះដែរ ។ ការឆ្លុះបញ្ចាំងនេះគឺដើម្បីធានាឱ្យដឹងថាតើកម្មវិធីនោះមានសកម្មភាពសង្គ្រោះទាក់ទងនិងឆ្លើយតបទៅនឹងតំរូវការដែរឬទេ ហើយវាក៏អាចផ្តល់លទ្ធភាពក្នុងការកែលំអរដល់កម្មវិធីសង្គ្រោះនោះដែរ ។ វាពុំមែនជាការចាំបាច់ទេ ដែលទិន្នន័យទាំងអស់ត្រូវតែប្រមែប្រមូលដោយចំនួនដង (frequency) ដូចៗ គ្នា ។ ដូចនេះការតាក់តែងសកម្មភាពពិនិត្យតាមដានត្រូវធ្វើឡើងផ្អែកលើការសំរេចចិត្តថា តើប្រភេទពត៌មាននិមួយៗត្រូវប្រមែប្រមូលជាប្រចាំបែបណា យោលទៅលើតំរូវការបែបណា ហើយត្រូវប្រើប្រាស់ធនធានក៏វិតណាដែរក្នុងការប្រមែប្រមូលទិន្នន័យនោះ ។ ពត៌មានច្រើនប្រភេទអាចប្រមែប្រមូលបានពីសាលានិងកម្មវិធីសិក្សាផ្សេងៗទៀត ហើយពត៌មានទាំងនេះអាចចង្អុរបង្ហាញបានភ្លាមៗពីតំរូវការនិងបញ្ហានានា (ឧទាហរណ៍: ទិន្នន័យនៃការចូលរៀន ការលះបង់ការសិក្សា តើកូនសិស្សញ៉ាំអាហារមុនពេលចូលរៀនឬអត់ ពីចំនួនសៀវភៅ ឬអំពីសម្ភារៈដែលមានសំរាប់រៀន និងបង្រៀន ។ល ។) ការពិនិត្យតាមដានសិស្សដែលមិនបានចូលរៀន ព្រមទាំងអំពីហេតុផលដែលគេមិនចូលរៀនឬគេចវេះពីសាលានោះគឺអាចធ្វើទៅបានតាមរយៈការចុះសាកសួរដល់ផ្ទះសិស្សមួយចំនួនដែលយើងបានជ្រើសរើសពីតំបន់ណាមួយ ឬក៏អាចធ្វើ បានតាមរយៈការជួបប្រជុំជាមួយក្រុមសហគមន៍ ។

២. **បុគ្គលដែលចូលរួមការពិនិត្យតាមដាន:** បុគ្គលដែលមានលទ្ធភាពប្រមែប្រមូលពត៌មានពីក្រុមមនុស្សទាំងអស់ក្នុងតំបន់រងគ្រោះ (ក្នុងតរិយាបទវប្បធម៌ដែលគួរអាចទទួលយកបាន) គួរត្រូវបានបញ្ចូលឱ្យចូលរួមជាពិសេសដោយសំអាងទៅលើយេនឌ័រ និង ជំនាញភាសា ។ ការប្រព្រឹត្តផ្នែកវប្បធម៌ក្នុងតំបន់មួយ អាចទាមទារឱ្យមានការពិភាក្សាដោយឡែកៗរវាងបុគ្គលដែលគេទុកចិត្ត ជាមួយស្ត្រី ឬ ក្រុមមនុស្សភាគតិចទាំងឡាយ ។

៣. **ប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំ (EMIS)** អាចទទួលការរំខានឬរាំងស្ទះដោយសារគ្រោះអាសន្ន ។ ការប្រមូលពត៌មាន ការវិភាគពត៌មានជាមូលដ្ឋាន គួរត្រូវបានបង្កើតឡើងវិញ (ដោយផ្អែកលើគោល ការណ៍អាទិភាព) តាមរយៈកិច្ចសហប្រតិបត្តិការអន្តរភ្នាក់ងារ និង ការជួយគាំទ្រ ដល់អជ្ញាធរជាតិ ។ ការបង្កើត ឡើងឬធ្វើឱ្យល្អឡើងវិញ នូវប្រព័ន្ធពត៌មាន (EMIS) ថ្នាក់ជាតិមួយអាចទាមទារឱ្យមានការពង្រឹងសមត្ថភាព និង ធនធានក្នុង

ក៏រិតជាតិ តំបន់ និង មូលដ្ឋាន ដើម្បីបង្កើត ប្រមែប្រមូល គ្រប់គ្រង បកស្រាយ ប្រើប្រាស់និងចែកចាយពត៌មានដែលទទួលបាន។ សកម្មភាពនេះគួរត្រូវបានផ្តួងផ្តើមជាបន្ទាន់តាមការដែលអាចធ្វើបានក្នុងពេលមានគ្រោះអាសន្នដោយធ្វើយ៉ាងណាបង្កើតឱ្យមានប្រព័ន្ធពិនិត្យតាមដានមួយដែលកំពុងមានដំណើរការក្នុងជំនាក់កាលដំបូងនៃការស្ថាបនាឡើងវិញ។

សមសភាគសំខាន់ៗនៃ EMIS នោះគឺ កម្មវិធីផ្នែកទន់ (Software) ដែលស្របគ្នា។ ការិយាល័យអប់រំថ្នាក់ជាតិ និង ថ្នាក់ស្រុក ព្រមទាំងអនុវិស័យអប់រំផ្សេងៗ (ឧទាហរណ៍ វិទ្យាស្ថានបណ្តុះបណ្តាលជាតិ) គួរមាន Software បន្ថែមដើម្បី បង្កើតនូវតារាងទិន្នន័យ Software ស្របគ្នាសំរាប់ជួយសំរួលដល់ការផ្លាស់ប្តូរពត៌មាន។

៤. **ការពិនិត្យតាមដានសិស្ស** គួរតែធ្វើឡើងនៅពេលណាដែលពួកគេបញ្ចប់ការសិក្សា។ ការពិនិត្យតាមដានអាចធ្វើឡើងទៅលើការទទួលបាននូវជំនាញអក្ខរកម្ម និងការគិតលេខ ព្រមទាំងការមានលទ្ធភាពអានឯកសារក្នុងថ្នាក់ក្រោយអក្ខរកម្ម (post- literacy)។ ចំពោះការអប់រំវិជ្ជាជីវៈវិញ គេគួរពិនិត្យតាមដានទៅលើឱកាសមានការងារធ្វើ ព្រមទាំងការប្រើប្រាស់ជំនាញដែលគេបានរៀន ហើយដែលការតាមដាននោះអាចធ្វើជាប្រចាំដោយបុគ្គលិកបន្ទុក និង ការសិក្សាតាមដានផ្សេងៗ។ ការពិនិត្យតាមដានក្រោយកម្មវិធីសិក្សាផ្តល់នូវពត៌មានសំខាន់ៗដល់ការតាក់តែងកម្មវិធីសិក្សាបន្តបន្ទាប់មកទៀត (សូមអានផងដែរនូវស្តង់ដាទី៤ នៃការបង្រៀននិងសិក្សា នៅទំព័រទី៨៧)។

៥. ***ភាពជាក់លាក់នៃទិន្នន័យ:*** ការវិភាគទាំងឡាយគួរតែមានការតំកល់ឯកសារដោយពន្យល់អំពី 1.និយមន័យសូចនាករ 2.ប្រភពទិន្នន័យ 3.វិធីសាស្ត្រនៃការប្រមូលទិន្នន័យ ៤.ប្រមូលទិន្នន័យ និង ៥.ដំណើការនៃការវិភាគពត៌មាន។ ភាពមិនប្រក្រតីផ្សេងៗដែលកើតឡើងក្នុងពេលរៀបចំប្រមែប្រមូលឬវិភាគទិន្នន័យគួរត្រូវបានធ្វើការកត់ចំណាំទុកផងដែរ។ ទិន្នន័យ អាចត្រូវបានពន្លើសដោយអ្នកផ្តល់ពត៌មានផងដែរ (ឧ. ការបំប៉ោងចំនួនសិស្សចុះឈ្មោះឬចំនួនវត្តមាន) ដើម្បីស្វែងរកការផ្តល់ធនធានឱ្យបានច្រើនឬដើម្បីជៀសវាងការស្តីបន្ទោសផ្សេងៗ។ បុគ្គលិកគួរត្រូវបានបណ្តុះបណ្តាលបន្ថែមនូវវិធីសាស្ត្រចុះសាកសួរដោយមិនប្រាប់ដំណឹងជាមុនដើម្បីបង្កើនភាពជាក់លាក់នៃទិន្នន័យ។

## ស្តង់ដារទិភាគទី៤: ការវាយតម្លៃ

មានការវាយតម្លៃដោយយុត្តិធម៌ និង មានលក្ខណៈជាប្រព័ន្ធអំពីជំនួយអប់រំដើម្បីកែលំអការអនុវត្តន៍ និង ពង្រឹងគណនេយ្យភាព។

**សូចនាករសំខាន់ៗ:** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- ការវាយតម្លៃទៅលើគោលនយោបាយ កម្មវិធី និង លទ្ធផលនៃអន្តរាគមន៍នានាត្រូវបានធ្វើឡើងក្នុងចន្លោះវគ្គអន្តរាគមន៍ដ៏សមស្របមួយ ដើម្បីវាយតម្លៃទៅលើយុទ្ធសាស្ត្រឆ្លើយតបទូទៅ គោលបំណងអប់រំលំអិត និងគោលបំនងនៃការការពារកុមារ ព្រមទាំងទៅលើស្តង់ដាអប្បបរមា (សូមអាន កំណត់សំគាល់ណែនាំទី១)។

- ពត៌មានត្រូវបានស្វែងរក ស្តីអំពីឥទ្ធិពលដែលមិនបានរំពឹងទុកនៃការធ្វើអន្តរាគមន៍។

- ពត៌មានត្រូវបានប្រមែប្រមូលក្នុងលក្ខណៈមានតម្លាភាព និងអព្យាក្រឹត្យពីភាគីដែលពាក់ព័ន្ធទាំងអស់ រួមទាំងក្រុមមនុស្សរងគ្រោះ និងដៃគូសង្គ្រោះមកពីផ្នែកផ្សេងៗផងដែរ។

- ភាគីពាក់ព័ន្ធទាំងអស់ដោយរួមទាំងក្រុមដែលបាត់បង់ផលប្រយោជន៍, គណកម្មការអប់រំក្នុងសហគមន៍ មន្ត្រីអប់រំថ្នាក់ជាតិ និង ថ្នាក់ស្រុក គ្រូបង្រៀន និងកូនសិស្ស ត្រូវបានបញ្ចូលក្នុងសកម្មភាពវាយតម្លៃ (សូមអានកំណត់សំគាល់ណែនាំទី២)

- មេរៀន និង ការអនុវត្តន៍ល្អៗត្រូវបានចែករំលែកយ៉ាងទូលំទូលាយ ជាមួយនឹងសហគមន៍ជាតិ និងក្នុងស្រុកផ្សេងៗ ព្រមទាំងជាមួយសហគមន៍មនុស្សធម៌ផងដែរ។ ហើយមេរៀន និង ការអនុវត្តន៍នេះនឹងច្របាច់បញ្ចូលទៅក្នុងការតស៊ូមតិកម្មវិធី និងគោលនយោបាយក្រោយពេលមានគ្រាអាសន្ន ដើម្បីរួមចំនែកក្នុងការកំណត់នូវគោលដៅអប់រំជាតិ និងគោលដៅអប់រំជាសាកល (សូមអាន កំណត់សំគាល់ណែនាំទី៣)។

### កំណត់សំគាល់ណែនាំ

១. **ការវាយតម្លៃ** គួរតែប្រមែប្រមូលទាំងទិន្នន័យមានលក្ខណៈជា គុណភាព និងទិន្នន័យមានលក្ខណៈជាបរិមាណ ដើម្បីឱ្យគេអាចបង្កើតនូវរូបភាពទូទៅមួយ។ ទិន្នន័យដែលមានលក្ខណៈគុណភាពផ្តល់នូវពត៌មានក្នុងបរិបទ ហើយជួយពន្យល់ពីទិន្នន័យស្ថិតិដែលប្រមែប្រមូលបាន។ ទិន្នន័យគុណវិស័យនេះអាចប្រមូលបានតាមរយៈ ការសម្ភាសន៍ ការសង្កេត និងឯកសារដែលមានស្រាប់ផ្សេងៗចំណែកឯទិន្នន័យជាបរិមាណអាចប្រមែប្រមូល

បានតាមរយៈការស្ទង់មតិនិងកំរងសំណួរ។

ការវាយតម្លៃគួរតែធ្វើការប៉ាន់ស្មានយ៉ាងទូលំទូលាយទៅលើជំនួយជាមនុស្ស សម្ភារៈ និង ហិរញ្ញវត្ថុ ទៅលើលទ្ធភាពចូលរៀនរបស់សិស្ស ការមករៀន ការបញ្ចូលពួកគេក្នុងសាលានិងការការពារ បែបបទនៃការបង្រៀននិងការរៀន ការចេះចាំ និងការបញ្ជាក់ការសិក្សា ការបណ្តុះបណ្តាលគ្រូដែលកំពុងបង្រៀន ឥទ្ធិពលទៅលើការរៀនសូត្រនៃសិស្សម្នាក់ៗ ដោយរួមទាំងឱកាសនៃការសិក្សាបន្តនិងការទទួលបានការងារធ្វើនិងទៅលើផលប៉ះពាល់ចំពោះសហគមន៍ទាំងមូល។

២. **ការពង្រឹងសមត្ថភាពតាមរយៈការវាយតំលៃ:** ឳកាសសំរាប់ការវាយតម្លៃគួរតែបែងចែកទៅលើចំណាយសំរាប់ធ្វើសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធនានាដើម្បីណែនាំឱ្យមានអត្ថន័យនៃការវាយតម្លៃ បង្កើតក្របខ័ណ្ឌ និងដំណើរការវាយតម្លៃដោយយកការចូលរួមចំណែកធ្វើជាមូលដ្ឋាន ព្រមទាំងដើម្បីពិនិត្យឡើងវិញនិងបកស្រាយរួមគ្នាអំពីលទ្ធផលទទួលបាន។ វាជាអត្ថប្រយោជន៍ដ៏ពិសេសមួយ ក្នុងការបញ្ចូលបុគ្គលិក កម្មវិធីអប់រំឱ្យរួមចំនែកក្នុងដំណើរការវាយតម្លៃ។ ប្រការនេះអាចជួយឱ្យពួកគេ បង្កើតនូវគំនិតជាមូលដ្ឋាន ក្នុងភាពជាម្ចាស់និងសំរាប់ការអនុវត្ត អនុសាសន៍នាពេលក្រោយៗទៀត។ អ្នកទទួលផលប្រយោជន៍ពី គំរោងកម្មវិធី (ឧ: គ្រូបង្រៀននិងបុគ្គលិកអប់រំជាដើម) ក៏អាចលើកឡើងនូវការលំបាកជាក់ស្តែងមួយចំនួនដែលពួកគេបានជួបប្រទះ ព្រមទាំងអំពីការលំបាកទាំងឡាយដែលគេនឹងអាចជួបប្រទះក្នុងការអនុវត្តអនុសាសន៍ណាមួយ។

៣. **ការចែករំលែកលទ្ធផល និង មេរៀន ដែលទទួលបាន:** អ្នកវាយតម្លៃគួរត្រូវបានប្រាប់ឱ្យសរសេររបាយការណ៍មួយដោយបញ្ចូលក្នុងជំពូកដំបូងនូវអ្វីដែលគេអាចចែករំលែកជាសាធារណៈ និងក្នុងជំពូកបន្ទាប់មកទៀតនូវលទ្ធផលដែលជាការសំងាត់ ឬ ការរកឃើញដែលជា ពតិមានផ្ទៃក្នុង ដែលគេមិនអាចចែករំលែកជាសាធារណៈបាន។

# ស្តង់ដារអប្បបរមាទូទៅ សំរាប់គ្រប់ចំណាត់ថ្នាក់៖ ឧបសម្ព័ន្ធនានាទាំងឡាយ

## ឧបសម្ព័ន្ធទី ១៖ ក្របខ័ណ្ឌនៃការវាយតម្លៃ

**ការការពារ** ( ផ្នែករាងកាយ ច្បាប់ និង សម្ភារៈ) **សិទ្ធិមនុស្ស, នីតិរដ្ឋ**

**ការវិភាគទៅលើសមត្ថភាព និងក្រុមដែលងាយទទួលការគ្រោះ៖** ( ឧទាហរណ៍៖ យេនឌ័រ ដោយយោងទៅលើការបែងចែកតាមអាយុ និង ភេទ ) **ការរួមចំណែក**

| មរណប្បមាណ (mortality) | | | | | |
|---|---|---|---|---|---|
| ភាពមានជំងឺ (morbidity) | | | ស្ថានភាពអាហារបំប៉ន | | |
| ការមានលទ្ធភាពទទួលបាននូវទឹកដែលអាចរែក ដង មកប្រើប្រាស់បាន | ការមានលទ្ធភាពទទួលបាននូវសេវាកម្មសុខភាពមូលដ្ឋាន អាហារបំប៉ន និងចិត្តសាស្ត្រសង្គម | ការញុំាអាហារ | ការមាន និងភាពគ្រប់គ្រាន់នៃជំរក | អកប្បកិរិយាដែលនាំឱ្យមានសុខភាពល្អ | កិរិតនៃការធ្វើអនាម័យ |
| សន្តិសុខស្បៀង | | | ការអនុវត្តន៍សេវាកម្មសុខភាព អាហារបំប៉ន និងចិត្តសាស្ត្រសង្គម | | |
| បរិបទសេដ្ឋកិច្ច និងទីផ្សាររបស់គ្រួសារ | ការអប់រំ | | បរិបទសង្គម និង វប្បធម៌ | | វិសមភាព |

**ការគាំពារ** ( ដូចជាសេវាសុខភាព, ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ, ទំនាក់ទំនងសង្គមនិងវប្បធម៌, អ្នកផ្តល់សេវាផ្សេងៗ អ្នកផ្តល់ជំនួយ ទីផ្សារ និង ភេទ... ។ល។)

**បរិបទជាតិ**

នយោបាយ សេដ្ឋកិច្ច ប្រវត្តិសាស្ត្រ សង្គម សមត្ថភាពរដ្ឋាភិបាល ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ ភូមិសាស្ត្រ អាកាសធាតុ គ្រោះមហន្តរាយធម្មជាតិ អង្គការអន្តរជាតិ.......... ។ល ។

**ទីផ្សារជាតិ**

កំពុងដំណើរការ ( ហើយដូចនេះវាកាត់បន្ថយតំរូវការនូវការជួយឧបត្ថម្ភពីខាងក្រៅ) ឬមិនដំណើរការ?

ក្របខ័ណ្ឌវាយតម្លៃ ត្រូវបានប្រើជាមូលដ្ឋាននៃការពិភាក្សានិងការវិភាគដើម្បីឱ្យបានយល់រួមគ្នានូវតំរូវការរបស់ក្រុមមនុស្សណាមួយ។ ការវិភាគនេះច្របាច់បញ្ចូលគ្នានូវភស្តុតាងនិងការវិនិច្ឆ័យ។ ក្របខ័ណ្ឌវាយតម្លៃមានការចែកចេញជាផ្នែកផ្សេងៗសំរាប់ធ្វើការវាយតម្លៃ (ដែលជារឿងរ៉ាវដែលគួរឱ្យពិចារណា) តែពុំមែនជាតំរូវការនោះទេ។ ក្របខ័ណ្ឌវាយតម្លៃ គ្រាន់តែស្នើរឡើងនូវផ្នែកផ្សេងៗសំរាប់ធ្វើការវាយតម្លៃប៉ុន្តែវាពុំទាន់មានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយនៅឡើយទេ ដូចនេះ វាទាមទារឱ្យមានការបំពេញបន្ថែមទៀតពីគ្រប់ចំណាត់ថ្នាក់ទាំងអស់ដើម្បីជួយដល់ក្រុមដែលធ្វើការវាយតម្លៃ ឱ្យឧបករណ៍ធ្វើវិភាគកាន់តែសុក្រិតថែមទៀត។ ទំរាំតែវិធីសាស្ត្រវាយតម្លៃទាំងនេះត្រូវបានបង្កើតឡើង ក្រុមវាយតម្លៃអាចធ្វើការជ្រើសរើស ថាគួរធ្វើយ៉ាងណាដើម្បីពន្យល់អំពីទំនាក់ទំនងរវាងហេតុនិងផលនៃផ្នែកសំរាប់ធ្វើការវាយតម្លៃផ្សេងៗបាន។ ក្របខ័ណ្ឌនេះបានផ្តល់នូវវេទិកាស៊ីសង្វាក់គ្នានិងមានតម្លាភាពមួយសំរាប់ចែករំលែកពតិមានជាមួយគ្នាដើម្បីរៀបចំផែនការផ្តល់ការជួយសង្គ្រោះមនុស្សធម៌ (ជាអាទិភាព) ទៅលើតំបន់ដែលមានគ្រោះវិបត្តិ។ ក្របខ័ណ្ឌនេះ វាមានចំណុចគួរវាយតម្លៃជាលំដាប់លំដោយតាមជាន់ថ្នាក់ ប៉ុន្តែវាពុំបានបញ្ជាក់ពីជំនួយសង្គ្រោះជាអាទិភាពណាមួយទេ។ ក្របខ័ណ្ឌនេះបានបង្ហាញថាផ្នែកផ្សេងៗមានការពាក់ព័ន្ធនឹងគ្នា

ទៅវិញទៅមក។ ផ្នែកនិមួយៗនេះគួរតែត្រូវបានវាយតម្លៃដោយឡែកពីគ្នា (ដូចជា ផ្នែកអប់រំ) និងបញ្ចូលគ្នា (ដូចជាឥទ្ធិពលនៃស្ថានភាពអប់រំទៅលើផ្នែកផ្សេងៗទៀតក្នុងក្របខ័ណ្ឌនេះ)។ ការការពារ, សិទ្ធិមនុស្ស, នីតិរដ្ឋ សុទ្ធតែជាបញ្ហារួម ដែលទាមទារឱ្យវាយតម្លៃដោយឡែកពីគ្នា និងឱ្យស៊ីជម្រៅ។ ចំណុចចាប់ផ្តើមសំរាប់ធ្វើការវាយតម្លៃ គឺអាចពីភូមិសាស្ត្រ ឬពីក្រុមមនុស្ស។

**ប្រភព: ក្របខ័ណ្ឌវាយតម្លៃ** ត្រូវបានបង្កើតឡើងដោយគណកម្មការនាយកអន្តរក្រសួង (IASC), អនុក្រុមការងារ CAP ហើយទទួលការកែសំរួលក្នុងសិក្ខាសាលា ដែលចូលរួមដោយភាគីម្ចាស់ជំនួយ, ភ្នាក់ងារ UN, កាកបាទក្រហម និង NGOs នៅថ្ងៃទី ២៥ មករា ២០០៤។

# ឧបសម្ព័ន្ធទី ២: ការរៀបចំផែនការក្នុងពេលមានគ្រោះអាសន្ន: តារាងពិនិត្យសំរាប់វិភាគស្ថានការណ៍

អ្នកត្រូវស្គាល់ និង យល់ដឹងពី កត្តាទាំងឡាយ បញ្ហាផ្សេងៗ មនុស្ស និង ស្ថាប័ននានា ដើម្បីរៀបចំផែនការ និងអនុវត្តកម្មវិធី ។

## ១. ការវាយតម្លៃមូលដ្ឋាន

- តើគេត្រូវការទិន្នន័យអ្វីខ្លះសំរាប់ការសិក្សាមូលដ្ឋាន?
- តើអ្នកត្រូវការទិន្នន័យអ្វីខ្លះដើម្បីរៀបចំផែនការអនុវត្ត ។ តើអ្វីខ្លះដែលមាន? ឧទាហរណ៍ ទីតាំងសាលារៀន (ចំនួន និង ទីតាំង) ចំនួនសិស្សដែលបានរំពឹងទុក ចំនួនគ្រូបង្រៀន... ។ល ។
- តើមានឱកាសណា ឬអត់ ក្នុងការប្រមូលទិន្នន័យមូលដ្ឋាន មុននឹងអ្នកចាប់ផ្តើមកម្មវិធី?

## ២. លក្ខណៈនៃស្ថានការណ៍

- តើអ្វីទៅជាលក្ខណៈនៃស្ថានការណ៍ (ចាប់ផ្តើមយឺតៗ ឬ កើតឡើងភ្លាមៗ)?
- តើមានក្រុម (វប្បធម៌ អាយុ យេនឌ័រ... ។ល ។) ណាមួយទេដែលងាយនឹងរងគ្រោះ ឬកំពុងទទួលឥទ្ធិពលពីគ្រោះអាសន្ន?

## ៣. ស្ថិរភាពនៃស្ថានការណ៍

- តើស្ថានការណ៍មានស្ថិរភាព (រយៈខ្លី, រយៈមធ្យម) ឬក៏កំពុងតែប្រែប្រួល?
- តើមានហេតុការណ៍ដែលអាចព្យាករណ៍បានដែរ ឬទេ? (ដូចជាការកើតឡើងនូវគ្រោះអាសន្នមួយថ្មី ឬក៏មានការផ្លាស់ប្តូរទ្រង់ទ្រាយធំចំពោះគ្រោះអាសន្ន ដែលកំពុងតែកើតឡើង)
- តើមានកត្តាគួរឱ្យកត់សំគាល់អ្វីខ្លះ ដែលនាំឱ្យមានការផ្លាស់ប្តូរភ្លាមៗ និងជាពិសេសនោះ?

## ៤. ប្រព័ន្ធអប់រំនាពេលបច្ចុប្បន្ន

### ប្រព័ន្ធអប់រំ

- តើមានប្រព័ន្ធអប់រំដែលកំពុងដំណើរការ ឬ អត់?
- តើមានបព័ន្ធអប់រំដែលកំពុងដំណើរការលើសពីមួយ ឬអត់ នៅក្នុងចំណោមក្រុមមនុស្សដែលជាគោល ដៅ?
- តើគ្រោះអាសន្ននេះ ជះឥទ្ធិពលបែបណាខ្លះចំពោះប្រព័ន្ធអប់រំនាពេលបច្ចុប្បន្ននេះ?
- តើមានភាពខ្វះខាត ឬមហន្តរាយដល់អាគារ និងហេដ្ឋារចនាសម្ព័ន្ធសិក្សាដែរឬទេ? (ផ្ទះបាយ បរិក្ខាអនាម័យ ឃ្លាំង... ។ល ។)

- តើស្ថានភាពសិក្សានៅពេលបច្ចុប្បន្នមានសភាពយ៉ាងណាដែរ? (ទីធ្លា សំភារៈ ថ្នាក់រៀង និង បុគ្គលិក ។ល។)
- តើស្ថានការណ៏មានភាពដូចគ្នាទេចំពោះកុមារានិងកុមារី រឺ ចំពោះកុមារដែលមកពីតំបន់ ឬក្រុមជាតិសាសន៏ផ្សេងៗគ្នា... ។ល។?
- តើកុមារបានចុះឈ្មោះចូលរៀនដែរឬទេ? តើកុមារបានចូលរៀនជាប្រចាំឬទេ? បើពុំមានទេ ហេតុអ្វី?
- តើកុមារដែលកំពុងរៀន ត្រូវទទួលឥទ្ធិពលពីការស្រេកឃ្លាន ឬទេ? (ឧទាហរណ៏ ពុំមានអាហារពេលព្រឹក, ចំងាយផ្លូវឆ្ងាយពីសាលា កង្វះជីវជាតិទូទៅ)?
- តើកុមារកំពុងតែទទួលឥទ្ធិពលពីការកង្វះមីក្រូ សារជាតិជាមូលដ្ឋានណាមួយដែរ ឬទេ? តើខ្វះអ្វី?

**កម្មវិធីសិក្សា និង ការបង្រៀន**

- តើមានកម្មវិធីសិក្សារួម ឬទេ?
- តើការបង្រៀន ប្រើភាសារួមណាមួយដែរឬទេ?
- តើគ្រូបង្រៀន មានប្រើសម្ភារៈជំនួយក្នុងការបង្រៀននិងរៀន ដែរឬទេ?
- តើត្រូវការឱ្យមានការបណ្តុះបណ្តាលគ្រូ ឬ បណ្តុះបណ្តាលគ្រូឡើងវិញដែរឬទេ?
- តើត្រូវការឱ្យមានការអប់រំក្រៅប្រពន្ធ័ ព្រមទាំងកម្មវិធីបណ្តុះបណ្តាលជំនាញផ្សេងៗដែរ ឬទេ? (ឧ. សំរាប់ (កុមារ) ទាហានដែលរំសាយ, ក្មេងដែលពុំទាន់បានចូលរៀន និង,ឬក្រុមរងគ្រោះជាពិសេសណាមួយ)

## ៥. ភាគីពាក់ព័ន្ធសំខាន់ៗ

**កត់សំគាល់ភាគីពាក់ព័ន្ធសំខាន់ៗ**

- តើនរណាម្នាក់កំពុងធ្វើអ្វី?
- តើនរណាម្នាក់កំពុងទទួលខុសត្រូវលើអ្វី?
- តើនរណាម្នាក់កំពុងរៀបចំផែនការអ្វី?
- តើនរណាម្នាក់កំពុងទទួលខុសត្រូវលើធនធានអ្វី?
- តើនរណាម្នាក់កំពុងទទួលខុសត្រូវលើការសំរេចចិត្តអ្វី?
- អង្គការអន្តរជាតិផ្សេងៗ
- អង្គការក្រៅរដ្ឋាភិបាល (អន្តរជាតិ និង ក្នុងស្រុក)
- រដ្ឋាភិបាលៈ
  - តើស្ថានភាពបច្ចុប្បន្ន របស់រដ្ឋាភិបាលជាតិ និង ក្នុងស្រុក (ស្របច្បាប់ ឬ ស្តីទី) យ៉ាងណាដែរ?
  - តើអ្នកណាកំពុងចាត់ចែងគ្រប់គ្រងវិស័យអប់រំ?
- សាលារៀន (គ្រូបង្រៀន នាយកសាលា, សមាគមគ្រូ និង អាណាព្យាបាល)

- សហគមន៍ ( អ្នកដឹកនាំ ចាស់ទុំ ក្រុមសាសនា សមាគមស្រ្តី បុគ្គលិកសុខភាព ឬ ក្រុមសហគមន៍ផ្សេងៗទៀត)
- គ្រួសារ
  - តើអ្វីទៅជារចនាសម្ព័ន្ធគ្រួសារដែលមានឥទ្ធិពលជាងគេ?
  - តើគ្រោះអាសន្នបានជះឥទ្ធិពលទៅលើរចនាសម្ព័ន្ធគ្រួសារ ឬទេ?
  - តើអ្នកណាជាអ្នកសំរេចចិត្តអំពីការទទួលការអប់រំរបស់កុមារ ( ជាពិសេសកុមារី)

## ៦. ធនធានដែលមាន

សំរាប់ការអប់រំ ( សូមអានផងដែរនូវ "ប្រព័ន្ធអប់រំបច្ចុប្បន្ន" ខាងលើ)

- តើមានទីធ្លាសុវត្ថិភាពសំរាប់រៀនសូត្រឬទេ?
- តើអគារសិក្សាដែលមានកំពុងប្រើការទាំងស្រុងឬទេ?
- តើមានចំនួនគ្រូ និង បុគ្គលិកសិក្សាគ្រប់ចំនួនឬទេ សំរាប់ដំណើរការប្រចាំថ្ងៃរបស់សាលា?

### សំរាប់ជំនួយស្បៀងអាហារ

- តើមានភាពបន្ទាន់ ឬទេ ក្នុងការចែកចាយស្បៀងអាហារ?
- តើមានបុគ្គលិកណាខ្លះ សំរាប់រៀបចំស្បៀងអាហារ?
- តើមានអគារ ឬ សម្ភារៈអ្វីខ្លះសំរាប់ប្រើក្នុងការរៀបចំស្បៀងអាហារ ( ផ្ទះបាយសាលា ឃ្លាំង ឧបករណ៍ចំអិន និង ញ៉ាំអាហារ អុស ឬ អុសសំរាប់ចំអិន ប្រភពទឹក) ?
- តេអាចធ្វើទៅរួចដែរ ឬទេ ក្នុងការបង្កើតឱ្យមានបរិក្ខាទាំងនោះ?
- តើមាន ដឹកជញ្ជូន, ចែកចាយ, ឬឃ្លាំងស្តុកទុកឬទេ?
- តើស្បៀងអាហារណាខ្លះ ដែលនឹងមាន? តើវាអាចយកមកពីណា ហើយដោយរប៉ស់បែបណាដែល វាអាចបញ្ជូនទៅទីតាំងចែកចាយស្បៀង?
- តើមានកម្មវិធីសុខភាពសិក្សា ដែលបន្ថែមទៅលើកម្មវិធីនេះ ឬទើបរៀបចំដែរឬទេ?
- តើមានការប្តេជ្ញាចិត្តពីម្ចាស់ជំនួយដែរឬទេ នាពេលបច្ចុប្បន្ននេះ?
- តើមានដៃគូរការងារដែលមានសក្តានុពល ដែលអាចអនុវត្តកម្មវិធីនេះបាន ដែរឬទេ?

## ៧. ឧបសគ្គដែលកើតមានបច្ចុប្បន្ន និង ដែលអាចមាននាពេលអនាគត

### សន្តិសុខ

- តើមានទីកន្លែងសុវត្ថិភាពសំរាប់ការសិក្សាដែរ ឬទេ?
- តើកុមារ គ្រូបង្រៀននិងបុគ្គលិកសង្គ្រោះអាចមានលទ្ធភាពមកកាន់បរិស្ថានសិក្សាដោយសុវត្ថិភាពដែរ ឬទេ?

- តើមានកន្លែងសុវត្ថិភាពសំរាប់រៀបចំ និង ចែកចាយស្បៀងអាហារដែរ ឬទេ?
- តើមានសុវត្ថិភាពទេចំពោះការដឹកជញ្ជូន និង ចែកចាយស្បៀងអាហារ?
- តើកន្លែងស្តុកទុកស្បៀងអាហារមានសុវត្ថិភាព ឬទេ?

### ឧបសគ្គផ្នែកយេនឌ័រ និង ក្រុមពូជសាសន៍

- តើមានឧបសគ្គ, បញ្ហាជាពិសេសណាមួយចំពោះក្រុមយេនឌ័រណាមួយ ឬ ផ្សេងៗទៀតឬទេ?
- តើមានឧបសគ្គ, បញ្ហាជាពិសេសណាមួយចំពោះក្រុម (ជាតិសាសន៍នៅក្នុងតំបន់) ផ្សេងៗគ្នាដែរ ឬទេ?

### ភាពស្របច្បាប់

- តើមានដៃគូច្បាស់លាស់ណាមួយក្នុងរដ្ឋាភិបាលសំរាប់ជួយរៀបចំផែនការ និង អនុវត្តសកម្មភាពដែរ ឬទេ?
- តើការបង្កើត និងការគាំទ្រដល់សកម្មភាពអប់រំ ទទួលបានការជ្រោមជ្រែងពីសំណាក់ថ្នាក់ដឹកនាំ នយោបាយ ឬ ថ្នាក់ដឹកនាំមូលដ្ឋានដែរ ឬទេ? បើពុំមានទេ តើហេតុអ្វី?
- តើមានហានិភ័យក្នុងការអនុវត្តកម្មវិធីដោយគ្មានការជ្រោមជ្រែងទាំងនេះដែរ ឬទេ?
- តើការផលលំបាកអ្វីខ្លះ ក្នុងការអនុវត្តកម្មវិធីដោយគ្មានការជ្រោមជ្រែងទាំងនេះ?
- តើការអនុវត្តកម្មវិធីដោយគ្មានការជ្រោមជ្រែងទាំងនេះ អាចកែតំរូវដែរ ឬទេ?
- តើគេអាចបង្កើតភាពជាដៃគូរបានដែរ ឬទេ?
- តើគេអាចតាក់តែងកម្មវិធីឡើងដើម្បីបង្កើត និង/ឬទាក់ទាញការជួយជ្រោមជ្រែងបានដែរ ឬទេ?

**កែសំរួលចេញពី:** កម្មវិធីស្បៀងអាហារពិភពលោក, ការរៀបចំឱ្យមានការផ្តល់អាហារតាមសាលារៀនក្នុងគ្រាអាសន្ន-ការវិភាគស្ថានការណ៍, ការតាក់តែងកម្មវិធី, ការអនុវត្តន៍ ២០០៤. http://www.wfp.org

## ឧបសម្ព័ន្ធទី៣: ការប្រមូលពត៌មាន និងគំរូការនៃការប៉ាន់ប្រមាណ

## តារាងសំនួរ

ទីតាំង: ____________________

ប្រភេទនៃគ្រោះអាសន្ន: ____________________

បញ្ហាចំបង: ____________________

**តើមានសាលារៀនណាខ្លះ ដែលកំពុងដំណើរការបង្រៀន?**

| បាទ, ចាស់ ឬ ទេ | ទីតាំង | ចំនួនកុមារដែលកំពុងរៀនសូត្រ | |
|---|---|---|---|
| | | កុមារី | កុមារា |
| ______ | ______ | ______ | ______ |
| ______ | ______ | ______ | ______ |
| ______ | ______ | ______ | ______ |

**១. មូលហេតុចំបង និង/ឬ បាតុភាពនៃបញ្ហា ☑**

- អាគារសិក្សាត្រូវបានបំផ្លាញ ☐
- ទឹកនៅក្នុងសាលាពុំមានសុវត្ថិភាព/មិនមានទឹក ☐
- កុមារពុំបានចូលរៀន/នៅក្រៅសាលា ☐
- ឧបករណ៏/សម្ភារះសិក្សាមិនគ្រប់គ្រាន់ ☐
- គ្រួសារពុំមានលទ្ធភាពទិញសម្ភារះសិក្សា ☐
- គ្រូបានចាកចេញបាត់ ឬមានការភ័យខ្លាច ☐
- ពុំមានមនុស្សចាស់ចេះដឹងដើម្បីជំនួសគ្រូៗ ☐
- គ្រូ ពុំបង្រៀនទេបើពុំមានប្រាក់កំរៃ ☐
- ការធ្វើដំណើរមានគ្រោះថ្នាក់ ☐
- គ្រូបង្រៀនបានចូលបំរើកងទ័ព ☐
- កុមារខ្លះនៅមានអារម្មណ៏ភ័យខ្លាច, ស្លុត ☐
- កុមារខ្លះពិការ ☐
- កុមារខ្លះបានចូលបំរើកងទ័ព ☐

**២. ការកត់សំគាល់ពីចំនួនកុមារ**

| | សរុប | កុមារី | កុមារា |
|---|---|---|---|
| ចំនួនកុមារ | ______ | ______ | ______ |
| 0-5 ឆ្នាំ | ______% | ______% | ______% |
| ៦-១៣ ឆ្នាំ | ______% | ______% | ______% |
| ១៤-១៨ ឆ្នាំ | ______% | ______% | ______% |
| កុមារដែលជាប្រជាជនចាស់ | ______% | ______% | ______% |
| កុមារដែលជាអ្នកចំណូលថ្មី | ______% | ______% | ______% |

**៣. ការប្រៀបធៀបជាមួយពេលមុនមានគ្រោះអាសន្ន**

| | សរុប | | | កុមារី | | | កុមារា | | |
|---|---|---|---|---|---|---|---|---|---|
| ចំនួនកុមារ | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង |
| 0-5 ឆ្នាំ | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង |
| ៦-១៣ ឆ្នាំ | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង |
| ១៤-១៨ ឆ្នាំ | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង |
| កុមារដែលជាប្រជាជនចាស់ | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង |
| កុមារដែលជាអ្នកចំណូលថ្មី | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង | តិចជាង | ស្មើគ្នា | ច្រើនជាង |

**សូមពន្យល់ចំណុចខុសគ្នាធំៗទាំងឡាយនៃយេនឌ័រ**

**តើមានចំណុចសំខាន់ៗណាទៀតទេដែលត្រូវផ្តោតការដោះស្រាយ ដូចជា វត្តមាននៃក្រុមជាតិសាសន៍ណាមួយ? សូមពន្យល់**

**៤. តើកុមារមានកំរិតអប់រំយ៉ាងណាដែរ?**

| | ការអប់រំថ្នាក់មត្តេយ្យ | ការអប់រំថ្នាក់បឋមសិក្សា | ការអប់រំថ្នាក់មធ្យមសិក្សា |
|---|---|---|---|
| ចំនួន% នៃក្រុមអាយុ ដែលបានបញ្ចប់ | ______ | ______ | ______ |

**៥. តើភាសាណាខ្លះដែលកុមារបានប្រើ?**

| | ភាសាកំនើត | និយាយ ☑ | សរសេរ ☑ |
|---|---|---|---|
| ភាសាក្នុងស្រុក (បញ្ជាក់) | ______ | ☐ | ☐ |
| | ______ | ☐ | ☐ |
| | ______ | ☐ | ☐ |
| ភាសាផ្សេងៗ (បញ្ជាក់) | ______ | ☐ | ☐ |
| | ______ | ☐ | ☐ |
| | ______ | ☐ | ☐ |

**៦ក. តើអ្នកមានផែនទីក្នុងតំបន់ដែលមានការបង្ហាញអំពីអាគារទាំងឡាយរបស់សហគមន៍** (ឧទាហរណ៍ សាលារៀន, មណ្ឌល សុខភាព, ព្រះវិហារកាតូលិក) **ដែរឬទេ?**

**៦ខ. បើចំលើយទៅនឹងសំនួរ ៦ក គឺ "អត់មានទេ" តើអ្នកអាចរកផែនទីមួយបានដែរ ឬទេ?**

**៦គ. បើចំលើយទៅនឹងសំនួរ ៦ខ គឺ "ទេ" ចូរប្រាប់ពីវិធីដើម្បីស្វែងរកពតិមាននេះ**

**៧. តើមានទីតាំងណា ដែលអាចប្រើសំរាប់ជាថ្នាក់រៀនបាន?**

| | ☑ | ចំនួនកុមារដែលអាចផ្ទុកបាន |
|---|---|---|
| សាលារៀន ឬ ថ្នាក់រៀន | ☐ | ________ |
| មណ្ឌលស្តារនីតិសម្បទា | ☐ | ________ |
| ជំរក | ☐ | ________ |
| នៅខាងក្រៅ (ក្រោមម្លប់ , ដើមឈើ) | ☐ | ________ |
| ផ្ទះ ☐ | | |
| អាគារសាសនា | ☐ | ________ |
| គ្លីនិក | ☐ | ________ |
| ផ្សេងៗ (សូមបញ្ជាក់) | ☐ | ________ |

**៨. តើគេអាចទៅកាន់កន្លែងខាងក្រោមនេះបានងាយស្រួលឬទេ?**

| | នៅនឹងកន្លែង ☑ | នៅចំងាយ (.....ម៉ែត្រ) ☑ | ពុំមាន ☑ |
|---|---|---|---|
| ប្រភពទឹក (សូមបញ្ជាក់) | ☐ | ☐ | ☐ |
| កន្លែងលុបមុខ | ☐ | ☐ | ☐ |
| កន្លែងងូតទឹក (Showers) | ☐ | ☐ | ☐ |
| បង្គន់ | ☐ | ☐ | ☐ |
| អគារពេទ្យ | ☐ | ☐ | ☐ |
| អគារសំរាប់ជនពិការ | ☐ | ☐ | ☐ |

| | | | |
|---|---|---|---|
| ភ្លើងអគ្គិសនី | ☐ | ☐ | ☐ |

**៩. តើក្នុងចំងាយប៉ុណ្ណាដែរ ដែលកុមារត្រូវធ្វើដំណើរទៅរៀន?**

| | 0-25% | 26-50% | 51-75% | 76-100% |
|---|---|---|---|---|
| **(ជាម៉ែត្រ)** | | (%នៃក្រុមកុមារ) | | |
| 500ម៉ែត្រ ឬ តិចជាង | ________ | ________ | ________ | ________ |
| 500 ទៅ ១000ម៉ែត្រ | ________ | ________ | ________ | ________ |
| លើសពី ១000ម៉ែត្រ | ________ | ________ | ________ | ________ |
| **(ជាម៉ៃយ៍)** | | (%នៃក្រុមកុមារ) | | |
| កន្លះម៉ៃយ៍ ឬ តិចជាង | ________ | ________ | ________ | ________ |
| កន្លះ ទៅ មួយម៉ៃយ | ________ | ________ | ________ | ________ |
| លើសពីមួយម៉ៃយ៍ | ________ | ________ | ________ | ________ |

**១០. តើកុមារត្រូវមានបានជួយធ្វើការផ្ទះ ឬ ការងារផ្សេងៗទៀត ឬទេ?**

| | កុមារី | កុមារា |
|---|---|---|
| % | ________ | ________ |
| ម៉ោងក្នុង១ថ្ងៃ | ________ | ________ |
| ច្រើនតែពេលព្រឹក ឬ ថ្ងៃ | ________ | ________ |

**១១. តើសម្ភារៈសិក្សាដែលមាន មានចំនួនប៉ុន្មាន (ចំនួនប្រហែល) ហើយត្រូវការប៉ុន្មាន?**

| (សំរាប់កុមារម្នាក់) | ដែលមាន | ដែលត្រូវការ |
|---|---|---|
| សៀវភៅពុម្ព | ________ | ________ |
| មុខវិជ្ជាទី១ | ________ | ________ |
| មុខវិជ្ជាទី២ | ________ | ________ |
| មុខវិជ្ជាទី៣ | ________ | ________ |
| ក្តារឈ្នួន | ________ | ________ |
| ដីស | ________ | ________ |
| ប្រដាប់លុប | ________ | ________ |
| សៀវភៅលំហាត់ | ________ | ________ |
| ប៊ិច, ខ្មៅដៃ | ________ | ________ |

| | | |
|---|---|---|
| ប្រដាប់លុបខ្មៅដៃ | | |
| ខ្មៅដៃពណ៌ | | |
| ផ្សេងៗ (សូមបញ្ជាក់) | | |

**១២. តើសម្ភារៈបង្រៀនដែលមាន មានចំនួនប៉ុន្មាន (ចំនួនប្រហែល) ហើយតើត្រូវការប៉ុន្មាន?**

| (ក្នុង១ថ្នាក់) | ដែលមាន | ដែលត្រូវការ |
|---|---|---|
| សៀវភៅណែនាំការបង្រៀន | | |
| សៀវភៅកំណត់ហេតុ | | |
| ក្តារខៀន | | |
| ប្រអប់ដីស | | |
| តារាងបិតតាមជញ្ជាំង, ផែនទី | | |
| ប៊ិច, ខ្មៅដៃ | | |
| សម្ភារៈការិយាល័យ | | |
| ផ្សេងៗ (សូមបញ្ជាក់) | | |
| សម្ភារៈកំសាន្ត | | |

**១៣. តើអ្នកណាដែលមានពេល ឬអាចមានពេលដើម្បីបង្រៀនកុមារ?**

| | ចំនួន | ស្ត្រី (%) | បុរស(%) |
|---|---|---|---|
| គ្រូបង្រៀនដែលបានបណ្តុះបណ្តាល | | | |
| អ្នកមានអាជីពពិសេស(វិជ្ជាជីវៈប្រហែលគ្រូបង្រៀន) | | | |
| អ្នកមានអាជីពផ្សេងៗទៀត(វេជ្ជសាស្ត្រ,វេជ្ជសាស្ត្រពិសេស) | | | |
| ក្មេងធំៗ | | | |
| សមាជិកសហគមន៍ | | | |
| សមាជិក NGO | | | |
| អ្នកស្ម័គ្រចិត្ត | | | |
| ផ្សេងៗ (សូមបញ្ជាក់) | | | |

**១៤. តើមានធនធានមនុស្សពេញវ័យណាខ្លះ ដែលអាចជួយដល់គ្រូបង្រៀនបាន?**

| | ចំនួន | ស្ត្រី (%) | បុរស(%) | កំរិតអប់រំ |
|---|---|---|---|---|
| អ្នកមានអាជីពពិសេស | ________ | ________ | ________ | ________ |
| អ្នកមានអាជីពផ្សេងទៀត (ឧ. ពេទ្យ) | ________ | ________ | ________ | ________ |
| ក្មេងធំៗ | ________ | ________ | ________ | ________ |
| សមាជិកសហគមន៍ | ________ | ________ | ________ | ________ |
| សមាជិក NGO | ________ | ________ | ________ | ________ |
| អ្នកស្ម័គ្រចិត្ត | ________ | ________ | ________ | ________ |
| ផ្សេងៗ (សូមបញ្ជាក់) | ________ | ________ | ________ | ________ |

**១៥. តើកុមារត្រូវបានគេជូនទៅរៀន ឬទេ?**

| | %នៃក្រុមកុមារ |
|---|---|
| ដោយគ្រួសារគេទាំងមូល | ________________ |
| ដោយឪពុកឬម្តាយ (យ៉ាងហោចណាស់) | ________________ |
| ដោយបងៗ | ________________ |
| ដោយសមាជិកគ្រួសារដ៏ទៃទៀត | ________________ |
| ដោយអ្នកស្ម័គ្រចិត្ត | ________________ |
| ទៅតែម្នាក់ឯង | ________________ |

**១៦. តើអ្នកណាជាមេគ្រួសារ?**

| | %នៃក្រុមកុមារ |
|---|---|
| ម្តាយ | ________________ |
| ឪពុក | ________________ |
| មនុស្សពេញវ័យផ្សេងទៀត (បញ្ជាក់) | ________________ |
| កុមារផ្សេងទៀត (បងស្រី) | ________________ |
| កុមារផ្សេងទៀត (បងប្រុស) | ________________ |
| ផ្សេងៗ (សូមបញ្ជាក់) | ________________ |

**១៧. ប្រវត្តិសេដ្ឋកិច្ចរបស់គ្រួសារកុមារ?**

| | % |
|---|---|
| កសិករ | ____________ |
| សិប្បករ | ____________ |
| ក្រុមពនេចរ | ____________ |
| អ្នកចិញ្ចឹមសត្វ | ____________ |
| ផ្សេងៗ (សូមបញ្ជាក់) | ____________ |

**១៨. តើមានសារពិសេសៗណាខ្លះដែលត្រូវផ្តល់ដល់កុមារ?**

សារស្តីអំពីអនាម័យ____________________

____________________

សារសុខភាព____________________

____________________

សារស្តីពីគ្រោះថ្នាក់ ដែលអាចកើតមានដូចជា គ្រាប់មីនជាដើម____________________

____________________

បំណិនជីវិត (សូមបញ្ជាក់)____________________

____________________

ផ្សេងៗ (សូមបញ្ជាក់)____________________

____________________

**១៩. វត្តមាននៃស្ថាប័នសំខាន់ៗ ដែលកំពុងដំណើរការក្នុងតំបន់រងគ្រោះ** (សូមបញ្ជាក់បង្ហាញនូវឈ្មោះមួយចំនួនរបស់ស្ថាប័ននោះ)

| គណកម្មការសហគមន៍ | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.____________ | ☐ | ☐ | ☐ | ☐ |
| 2.____________ | ☐ | ☐ | ☐ | ☐ |

| ធនធានក្រសួងអប់រំ | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.____________ | ☐ | ☐ | ☐ | ☐ |
| 2.____________ | ☐ | ☐ | ☐ | ☐ |

| វិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.____________ | ☐ | ☐ | ☐ | ☐ |
| 2.____________ | ☐ | ☐ | ☐ | ☐ |

| NGOs ក្នុងស្រុកដែលសកម្មផ្នែកអប់រំ | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.________________________ | ☐ | ☐ | ☐ | ☐ |
| 2.________________________ | ☐ | ☐ | ☐ | ☐ |

| NGO អន្តរជាតិដែលសកម្មផ្នែកអប់រំ | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.________________________ | ☐ | ☐ | ☐ | ☐ |
| 2.________________________ | ☐ | ☐ | ☐ | ☐ |

| ភ្នាក់ងារអង្គការសហប្រជាជាតិ | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.________________________ | ☐ | ☐ | ☐ | ☐ |
| 2.________________________ | ☐ | ☐ | ☐ | ☐ |

| ផ្សេងៗ (សូមបញ្ជាក់) | មានច្រើន | មានល្មម | មានតិចតួច | ពុំមាន |
|---|---|---|---|---|
| 1.________________________ | ☐ | ☐ | ☐ | ☐ |
| 2.________________________ | ☐ | ☐ | ☐ | ☐ |

**ប្រភព:** UNICEF

# ២. ការទទួលយក និង បរិស្ថានសិក្សា

## សេចក្តីផ្តើម

ក្នុងកំឡុងពេលមានគ្រោះអាសន្ន សិទ្ធិចំបង និងធនធាន សំរាប់ទទួលបាននូវការអប់រំ មានកំរិតកំណត់។ ក៏ប៉ុន្តែ ការអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការជួយឱ្យក្រុមជនរងគ្រោះ មានលទ្ធភាពតទល់ទៅនឹងស្ថានការណ៍ដែលកើតមានព្រោះការអប់រំធ្វើឱ្យពួកគេទទួលនូវចំនេះដឹង និងជំនាញបន្ថែមទៀតសំរាប់ការរស់រាន និងសំរាប់នាំមកវិញនូវភាពធម្មតាក្នុងជីវិតរបស់គេ។ ជាមួយគ្នានេះដែរ វាច្រើនតែមានភាពស្មុគស្មាញក្នុងការចាត់ចែងសកម្មភាពអប់រំក្នុងគ្រាមានអាសន្ន ហើយវាជាគ្រោះថ្នាក់មួយ ដែលក្រុមងាយនឹងរងគ្រោះណាមួយនោះពុំមានលទ្ធភាពទទួលការអប់រំដែលបានផ្តល់ឱ្យ។ រដ្ឋាភិបាល សហគមន៍ និង អង្គការមនុស្សធម៌មានភារកិច្ច ដើម្បីធានាឱ្យបានថាបុគ្គលគ្រប់ៗរូបមានឱកាសដើម្បីទទួលការអប់រំដែលពាក់ពន្ធ័ គុណភាពណៃការអប់រំ ហើយបរិស្ថានសិក្សាត្រូវមានសុវត្ថិភាព និង ផ្តល់ទាំងការការពារ និង សុខមាលភាពផ្លូវចិត្ត អារម្មណ៏ និង រាងកាយដល់អ្នកសិក្សា។

កម្មវិធីអប់រំក្នុងគ្រាអាសន្ន អាចផ្តល់ការការពារផ្នែករាងកាយ សង្គម និង បញ្ញាដល់អ្នកសិក្សា ជាពិសេស ចំពោះកុមារ និង យុវវ័យ និងបុគ្គលិកអប់រំ។ ក៏ប៉ុន្តែ ជារឿយៗ អ្នកសិក្សាច្រើនជួបប្រទះនូវគ្រោះថ្នាក់ផ្នែករាងកាយ និងផ្លូវចិត្ត នៅពេលដែលគេធ្វើដំណើរទៅ និងមកពីសាលា ព្រមទាំងនៅក្នុងបរិស្ថានសិក្សាខ្លួនឯងផងដែរ។ បញ្ហាទាំងនេះ ជះឥទ្ធិពលដល់កុមារី និងគ្រូបង្រៀនជាស្ត្រីភេទ ដែលជាភាគតិច។ ក្នុងការផ្តល់នូវសេវាកម្មអប់រំ វាជាកតព្វកិច្ចក្នុងការធានាឱ្យបានថា សិស្សទាំងអស់មានសុវត្ថិភាពទាំងការធ្វើដំណើរទៅ និងមកពីសាលា ព្រមទាំងនៅក្នុងបរិស្ថានសិក្សាផងដែរ។

គេគួរតែផ្តល់ឱ្យសិស្សនូវឱកាសទទួលការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ទៅតាមលំដាប់ថ្នាក់បន្តបន្ទាប់គ្នាមួយ។ ប្រសិនបើ ការអប់រំក្នុងប្រព័ន្ធ ពុំមានលទ្ធភាពផ្តល់បានដោយភ្លាមៗទេបន្ទាប់ពីការកើតមាននូវគ្រោះអាសន្ននោះ កម្មវិធីអប់រំគួរតែរៀបចំឱ្យមានសកម្មភាពកំសាន្តសប្បាយ (កីឡា, ល្បែង) សកម្មភាពអប់រំក្រៅប្រព័ន្ធ កម្មវិធីរៀនបំប៉នបន្ថែមដល់ក្មេងធំៗ (ប្រសិនបើចាំបាច់) ឱកាសសំរាប់ឱ្យយុវវ័យ រក្សានិងបង្កើតជំនាញសិក្សា សំខាន់ៗ

ព្រមទាំងការអប់រំក្រៅប្រព័ន្ធ ឬការបណ្តុះបណ្តាលជំនាញដល់កុមារ យុវវ័យ និងមនុស្សពេញវ័យ ដែលមិនទាន់បានចាប់ផ្តើម ឬមិនទាន់បានបញ្ចប់ការអប់រំជាមូលដ្ឋាននៅឡើយទេ។

ក្រុម ឬបុគ្គលមួយចំនួនមានការលំបាករៀងៗខ្លួន ដើម្បីទទួលបានការអប់រំក្នុងស្ថានការណ៍មានគ្រោះអាសន្ន។ ទោះជាយ៉ាងណាក៏ដោយគ្មានបុគ្គលណាម្នាក់គួរត្រូវបានបដិសេធមិនឱ្យទទួលការអប់រំឬឱកាសរៀនសូត្រព្រោះតែភាពរើសអើងនោះទេ។ អ្នកផ្តល់ការអប់រំត្រូវតែប៉ាន់ស្មានពីតំរូវការចាំបាច់ណាមួយរបស់ក្រុមជនដែលងាយរងគ្រោះ ដូចជាជនពិការ ក្មេងស្រីជំទង់ កុមារដែលពាក់ព័ន្ធនឹងកងប្រដាប់អាវុធ កុមារដែលគេត្រូវគេបោះបង់ ម្តាយដែលស្ថិតនៅវ័យជំទង់...។ល។ ដើម្បីធានាឱ្យបានថាពួកគេទាំងនោះទទួលបាប្រយោជន៏ពីឱកាស នៃការអប់រំ។ អន្តរាគមន៏ផ្នែកអប់រំមិនគួរតែផ្តោតតែទៅលើការផ្តល់នូវសេវាកម្មអប់រំក្នុងនិងក្រៅប្រព័ន្ធតែប៉ុណ្ណោះទេ តែគេគួរតែផ្តោតផងដែរទៅលើការដោះស្រាយឧបសគ្គនានា ដូចជាការ រើសអើង ថ្លៃឈ្នួលសាលា និងឧបសគ្គភាសាដែលប្រការទាំងនេះកាត់ផ្តាច់ក្រុមខ្លះចេញពីការសិក្សា។ ជាពិសេសរទៅទៀតគេត្រូវការឱ្យមានការផ្តល់ឱកាសបន្ថែមទៀតទោះជាក្នុងឬក្រៅប្រព័ន្ធឬជាការបណ្តុះបណ្តាលវិជ្ជាជីវៈក៏ដោយដើម្បីដោះស្រាយតំរូវការរបស់កុមារីនិងស្ត្រីដែលពុំបានទទួលការអប់រំ ឬអ្នកដែលជួបប្រទះឧបសគ្គក្នុងការបន្តការអប់រំ របស់ពួកគេ។

## ទំនាក់ទំនងជាមួយនឹងស្តង់ដាទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់

ដំណើរការនៃការបង្កើតនិងអនុវត្តកម្មវិធីអប់រំគឺជាកត្តាសំខាន់មួយដើម្បីកំណត់នូវប្រសិទ្ធភាពនៃជំនួយផ្នែកអប់រំនោះ។ ជំពូកនេះ គួរត្រូវបានប្រើប្រាស់ស្របជាមួយនឹងស្តង់ដាទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់ដោយរួមបញ្ចូលនូវការចូលរួមចំនែករបស់សហគមន៏ ធនធានមូលដ្ឋាន ការប៉ាន់ស្មានដំបូង ការឆ្លើយតប ការពិនិត្យតាមដាន និង ការវាយតម្លៃ។ ជាពិសេស គេគួរតែជំរុញឱ្យមានការចូលរួមជាអតិបរមាពីសំណាក់ក្រុមជនរងគ្រោះដោយគ្រោះមហន្តរាយ ដោយរាប់បញ្ចូលតាំងពី ក្រុមជនងាយទទួលការរងគ្រោះផ្សេងៗទៀតផង ដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវនិងគុណភាពនៃការជួយ។

**ស្តង់ដាអប្បបរមា:** ស្តង់ដាទាំងនេះមានលក្ខណៈបែបគុណភាព ហើយបញ្ជាក់កំរិតអប្បបរមាដែលនឹងសំរេចបានក្នុងការផ្តល់ជំនួយអប់រំ។

**សូចនាករសំខាន់ៗ:** គឺជា "សញ្ញា" ដែលបង្ហាញថា តើស្តង់ដាត្រូវបានសំរេច ឬទេ។ សូចនាករទាំងនេះ ផ្តល់នូវវិធីមួយសំរាប់វាស់ និងបង្ហាញផលប៉ះពាល់ឬលទ្ធផលនៃកម្មវិធីព្រមទាំងដំណើរការឬវិធីសាស្ត្រដែលប្រើ។ សូចនាករទាំងនេះ អាចមានលក្ខណៈបែបគុណភាព ឬបរិមាណ។

**កំណត់សំគាល់ណែនាំ:** រួមមានចំណុចជាក់លាក់ដើម្បីពិចារណានៅពេលអនុវត្តស្តង់ដា និងសូចនាករក្នុងស្ថានភាពផ្សេងៗគ្នា ការណែនាំអំពីការដោះស្រាយការលំបាកជាក់ស្តែង និងដំបូន្មានអំពីបញ្ហាអាទិភាព។ កំណត់សំគាល់ណែនាំអាចរួមបញ្ចូលផងដែរនូវបញ្ហាសំខាន់ៗដែលទាក់ទងនឹងស្តង់ដា ឬសូចនាករ និងរៀបរាប់អំពីជំរើស ដែលពិបាកសំរេចភាពចំរូងចំរាស់ ឬចន្លោះប្រហោងនៅក្នុងចំណេះដឹងបច្ចុប្បន្ន។ ឧបសម្ព័ន្ធ២ រួមមាន តារាងជ្រើសរើសឯកសារយោង ដែលបង្ហាញប្រភពពត៌មានអំពីបញ្ហាទូទៅ និង បញ្ហាបច្ចេកទេសជាក់លាក់ ដែលទាក់ទងនឹងផ្នែកនេះ។

## ការទទួលយក និង បរិស្ថានសិក្សា

| ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ |
|---|---|---|
| ភាពស្មើគ្នាក្នុងការទទួល | ការការពារ និង សុខមាលភាព | អគារ/បរិស្ថានសិក្សា |
| បុគ្គលគ្រប់រូបមានឱកាសទទួលយកការអប់រំប្រកបដោយគុណភាព និងការអប់រំពាក់ព័ន្ធ | បរិស្ថានសិក្សាត្រូវបានធានា និងលើកកំពស់ការការពារ និងសុខមាលភាពផ្លូវចិត្ត និងអារម្មណ៍របស់អ្នកសិក្សា | អគារ/បរិស្ថានសិក្សាសុទ្ធតែមានប្រយោជន៍ដល់សុខមាលភាពរាងកាយរបស់អ្នកសិក្សា |

**ឧបសម្ព័ន្ធទី១**
**តារាងពិនិត្យចិត្តសាស្ត្រសង្គម**

**ឧបសម្ព័ន្ធទី២**
**តារាងពិនិត្យនៃកម្មវិធីផ្តល់អាហារតាមសាលារៀន**

**ឧបសម្ព័ន្ធទី៣: ឯកសារយោង និង សេចក្តីណែនាំពីធនធាន**
**ជំពូក ការទទួលយក និង បរិស្ថានសិក្សា**

## ស្តង់ដារទី១ នៃ ការទទួលយក និង បរិស្ថានសិក្សា: ភាពស្មើគ្នាក្នុងការទទួល

បុគ្គលគ្រប់រូបមានឱកាសទទួលយកការអប់រំប្រកបដោយគុណភាព និង ការអប់រំពាក់ពន្ធ័

**សូចនាករសំខាន់ៗ:** (សំរាប់អានជាមួយនឹង កំណត់សំគាល់ណែនាំ)

- គ្មានបុគ្គលណាម្នាក់ ដែលត្រូវបានគេបដិសេធមិនឱ្យមានលទ្ធភាពទទួលការអប់រំ និងឱកាសរៀនសូត្រដោយសារការរើសអើងនោះទេ (សូមអានកំណត់សំគាល់ណែនាំ ទី ១-២ ) ។
- ឯកសារ ឬតំរូវការផ្សេងៗពុំមែនជាឧបសគ្គនៃការចុះឈ្មោះចូលរៀនទេ(សូមអានកំណត់សំគាល់ណែនាំទី៣)
- ឱកាសទទួលការអប់រំក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធត្រូវបានផ្តល់ជាបន្តបន្ទាប់ដល់ជនរងគ្រោះ ដើម្បីបំពេញតំរូវការអប់រំរបស់គេ (សូមអាន កំណត់សំគាល់ណែនាំ ទី៤-៥)
- តាមរយៈការបណ្តុះបណ្តាល និងការឱ្យយល់ដឹង សហគមន៍កាន់តែចូលរួម ក្នុងការធានាដល់សិទ្ធិសមាជិកគ្រប់រូបក្នុងការទទួលបាននូវការអប់រំប្រកបដោយគុណភាព និង ការអប់រំពាក់ព័ន្ធ (សូមអាន កំណត់សំគាល់ណែនាំ ទី៦-៧) ។
- ធនធានគ្រប់គ្រាន់ត្រូវបានផ្តល់ឱ្យដោយអជ្ញាធរ ម្ចាស់ជំនួយ NGO ដៃគូរអភិវឌ្ឍន៍ផ្សេងៗទៀត និង ដោយសហគមន៍ ដើម្បីធានាឱ្យមាននិរន្តភាព និងគុណភាពនៃសកម្មភាពអប់រំក្នុងគ្រប់ដំណាក់កាលនៃគ្រោះអាសន្ន ព្រមទាំងក្នុងការកសាងឡើងវិញក្នុងជំហានដំបូង (សូមអាន កំណត់សំគាល់ណែនាំ ទី៨ ) ។
- អ្នកសិក្សាមានឱកាសចូលរៀន ឬចូលរៀនសារឡើងវិញ ភ្លាមៗ តាមបណ្តាស្ថាប័នអប់រំក្នុងប្រព័ន្ធទាំងឡាយក្រោយពីមានការរំខានដោយគ្រោះអាសន្នរួចមក ។
- កម្មវិធីអប់រំ ត្រូវបានទទួលស្គាល់ដោយអជ្ញាធរអប់រំនៃប្រទេសដែលផ្តល់ការអប់រំ និង ប្រទេសកំនើតរបស់ជនរងគ្រោះ ។

**កំណត់សំគាល់ណែនាំ**

**១. ការរើសអើង** សំដៅ (ប៉ុន្តែមិនកំណត់ទាំងស្រុង) ទៅលើឧបសគ្គទាំងឡាយណាដែលកើតឡើងព្រោះតែភាពក្រខ្សត់ យេនឌ័រ អាយុ សញ្ជាតិ ពូជសាស សាសនា ភាសា វប្បធមិ ទំនាក់ទំនងនយោបាយ និន្នាការផ្លូវភេទ ប្រវត្តិសង្គមសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ ឬតំរូវការអប់រំជាពិសេសណាមួយ។

កត្តិការសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធមិ បានគូសបញ្ជាក់នូវចំណុចខាងក្រោមនេះ:

- មាត្រាទី 2 បានទទួលស្គាល់ "សិទ្ធិទទួលការអប់រំដោយគ្មានការប្រកាន់រើសអើងគ្រប់ប្រភេទ ដូចជា ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិយោបល់ផ្នែកនយោបាយ ឬផ្នែកផ្សេងៗ ដើមកំនើតជាតិ ឬសង្គម ទ្រព្យ សម្បត្តិ កំនើត ឬឋានៈផ្សេងៗ។
- មាត្រាទី 13 បានទទួលស្គាល់សិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការទទួលការអប់រំ ក្នុងគោលដៅអភិវឌ្ឍន៍ដ៏ពេញលេញដល់អត្តចរិកជាមនុស្ស និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ហើយការអប់រំនេះត្រូវធ្វើឡើងដើម្បីពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ការអប់រំ ត្រូវធ្វើឱ្យបុគ្គលគ្រប់រូបមានលទ្ធភាពចូលរួមយ៉ាងសកម្មក្នុងសង្គមសេរី បង្កើតការយល់ដឹង ភាពអត់ធ្មត់ និងបង្កើតមិត្តភាពជាមួយគ្រប់ប្រទេសជាតិ ពូជសាសន៍ ជនជាតិ និងក្រុមសាសនានានា ព្រមទាំងពង្រីកបន្ថែមទៀតនូវ សកម្មភាពអង្គការសហប្រជាជាតិក្នុងការរក្សាសន្តិភាព។ ដើម្បីអាចទទួលបានពេញលេញ នូវសិទ្ធិខាងលើនេះ មាត្រាទី 13ក៏ទាមទារផងដែរឱ្យរដ្ឋទាំងអស់ទទួលស្គាល់ថា:១) ការអប់រំថ្នាក់បឋមសិក្សាគឺជាកាតព្វកិច្ច ហើយត្រូវផ្តល់ឱ្យដល់បុគ្គលគ្រប់រូបដោយគ្មានបង់ថ្លៃ,២) គ្រប់ប្រភេទនៃការអប់រំថ្នាក់មធ្យមសិក្សាដោយរាប់បញ្ចូលតាំងពីការអប់រំមធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈផងដែរ គួរតែបង្កើតឱ្យមានជាទូទៅ ហើយបុគ្គលគ្រប់រូបអាចទទួលការអប់រំនេះតាមរយៈគ្រប់មធ្យោបាយ ហើយជាពិសេស គឺតាមរយៈការដាក់ចូលជាបន្តបន្ទាប់នូវការអប់រំដោយមិនបាច់បង់ថ្លៃ, ៣) ការអប់រំជាមូលដ្ឋាន គួរត្រូវបានជំរុញ ឬពង្រឹងតាមលទ្ធភាពដែលអាចធ្វើទៅបានចំពោះបុគ្គលដែលមិនបានទទួលឬមិនបានបញ្ចប់គ្រប់កំរិតថ្នាក់នៃការអប់រំសំរាប់កំរិតបឋមសិក្សា។

**២. ក្របខ័ណ្ឌផ្លូវច្បាប់អន្តរជាតិ** បានប្រកាសថា សិទ្ធិទទួលការអប់រំ គួរត្រូវបានពង្រឹងក្នុងគ្រាមានអាសន្ន។ វារួមបញ្ចូល (ប៉ុន្តែមិនកំណត់ទាំងស្រុង)នូវ:

- ក្របខ័ណ្ឌសកម្មភាពនៃវេទិកាអប់រំពិភពលោកនៅទីក្រុងដាការ (Dakar) ដើម្បីលើកកំពស់ការអប់រំសំរាប់ទាំងអស់គ្នាដែលប្រកាសក្នុងចំណោមគោលបំនងទាំងឡាយរបស់ខ្លួនថា រដ្ឋាភិបាលទាំងអស់ត្រូវតែ"ទទួលបានរាល់តំរូវការប្រព័ន្ធអប់រំដែលទទួលឥទ្ធិពលពីជម្លោះ គ្រោះមហន្តរាយធម្មជាតិ និងអស្ថិរភាពនានា ហើយត្រូវតែអនុវត្តកម្មវិធីអប់រំតាមវិធីសាស្ត្រមួយដែលលើកកំពស់ការយល់ពីគ្នាទៅវិញទៅមក បង្កើតសន្តិភាព និងភាពយោគយល់គ្នា ដែលសំរាប់ជួយបង្ការភាពហឹង្សា និង ជម្លោះ"។

- អនុសញ្ញាហ្សឺណែវ (IV) ដែលទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ( មាត្រា ទី50): "អ្នកកាន់កាប់អំណាចគួរ រួមសហការជាមួយអជ្ញាធរជាតិ និង មូលដ្ឋានត្រូវជួយសំរួលដល់គ្រប់ស្ថាប័ន ដែលកំពុងអនុវត្តការងាររបស់គេក្នុងការថែរក្សា និងអប់រំកុមារ ។
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់កុមារ ដែលផ្តល់នូវក្របខ័ណ្ឌជាបទដ្ឋាន សំរាប់ការពារ ផ្នែករាងកាយ ចិត្តសង្គម និង បញ្ញារបស់អ្នកសិក្សាក្នុងកន្លែងមានគ្រោះអាសន្ន ។

៣. **ការទទួលឱ្យចូលរៀន និង ការចុះឈ្មោះចូលរៀន:** តំរូវការផ្នែកឯកសារត្រូវមានភាពបត់បែន ហើយមិនគួរទាមទារឱ្យមានលិខិតបញ្ជាក់ថា ជាពលរដ្ឋ លិខិតបញ្ជាក់កំនើត និង អាយុ ឯកសាកំនើត អត្តសញ្ញាណ របាយការណ៍ពីសាលារៀន...។ល។ ព្រោះជនដែលរងគ្រោះអាសន្នទាំងនោះអាចនឹងគ្មានឯកសារទាំងនេះ ។ គេមិនគួរកំណត់អាយុចូលរៀនដល់កុមារ និងយុវជនដែលរងគ្រោះអាសន្ននោះទេ ។ គេគួរតែអនុញ្ញាតិឱ្យអ្នកដែលបានបោះបង់ការសិក្សាមានឱកាសនឹងចុះឈ្មោះចូលរៀនឡើងវិញ ។ គួរតែមានការប្រឹងប្រែងជាពិសេសដើម្បីផ្តោតទៅលើក្រុមដែលបាត់បង់ផលប្រយោជន៍និងក្រុមដែលងាយទទួលការរងគ្រោះខ្លាំងបំផុត និងដើម្បីបញ្ចូលពួកគេក្នុងកម្មវិធីអប់រំវិញ ។ នៅកន្លែងណាដែលមានការបារម្ភពីសុវត្ថិភាព គេគួរតែរក្សាទុកជាសម្ងាត់នូវឯកសារនិងពតិមានចុះឈ្មោះចូលរៀនទាំងឡាយ ។

៤. **វិសាលភាពនៃឱកាសទទួលការអប់រំ:** ឱកាសទាំងនេះគួរតែរាប់បញ្ចូលតាំងពីការអប់រំថ្នាក់មត្តេយ្យ ថ្នាក់បឋមសិក្សានិងមធ្យមសិក្សា ថ្នាក់ឧត្តមសិក្សា បំណិនជីវិត ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំក្រៅប្រព័ន្ធ (រួមទាំងអក្ខរកម្ម និងលេខនពន្ធផងដែរ) និងឱកាសរៀនបំប៉នបន្ថែមផងដែរ ។ ភាពភ័យតក់ស្លុតដែលអ្នកសិក្សាអាចជួបប្រទះក្នុងគ្រាមានអាសន្ននោះមិនគួរត្រូវបានបន្ថែមពីលើទៀត ដោយការបាត់បង់ឱកាសទទួលបានការអប់រំនោះទេ ។

កាលវិភាគសិក្សាដែលមានលក្ខណៈបត់បែនដោយរួមបញ្ចូលតាំងពីម៉ោងសិក្សា ការដូរវេន កម្មវិធីផ្តល់ការអប់រំដល់ទីលំនៅ សេវាកម្មថែទាំកុមារផ្តល់ដល់ម្តាយដែលជាក្មេងស្រីជំទង់ ការគាំទ្រពីក្រុមមិត្តភ័ក្តសំរាប់សិស្សដែលជួបប្រទះការលំបាកក្នុងការបញ្ចូលខ្លួនទៅក្នុងថ្នាក់រៀន និងកម្មវិធីបំប៉ន ព្រមទាំងការសិក្សានាពេលវិស្សមកាល អាចផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់អ្នកសិក្សាសំរាប់ទទួលការអប់រំ ។ ការបញ្ចូលដោយបង្ខំនូវសិស្សធំៗទៅក្នុងថ្នាក់សំរាប់សិស្សតូចៗ ឬអនុញ្ញាតិឱ្យគេចូលរៀនដោយស្ម័គ្រចិត្តនៅក្នុងថ្នាក់របស់សិស្សតូចៗ អាចបណ្តាលឱ្យមានលទ្ធផលអវិជ្ជមានដល់ទាំងសិស្សធំ និង សិស្សតូច ហើយធ្វើឱ្យពួកគេទទួលលទ្ធផលមិនល្អពីការសិក្សា ។ គេគួរប្រើប្រាស់ជំរើសផ្សេងពីនេះ ដូចជាបែងចែកថ្នាក់សំរាប់សិស្សធំៗ និងឱ្យគេរៀនផ្លោះថ្នាក់ជាដើម ។ តំណាងយុវជន ក្រុមស្ត្រី សមាជិកផ្សេងៗទៀតរបស់សហគមន៍ និងអ្នកដឹកនាំសហគមន៍ជាដើមគួរតែត្រូវបានពិភាក្សាយោបល់មុននឹងដាក់បញ្ចូលនូវកម្មវិធីសិក្សាផ្សេងដោយឡែកពីកម្មវិធីធម្មតា ។

តិកនិកដូចជា "ការធ្វើផែនទីសាលា" គួរត្រូវបានប្រើប្រាស់ក្នុង និង ក្រោយពេលគ្រាអាសន្ន ដើម្បីរៀបចំផែនការដែលអស់សោហ៊ុយតិចឱ្យអ្នកសិក្សាក្នុងតំបន់ខុសៗគ្នា អាចទទួលបានសកម្មភាពអប់រំ ដែលជាការឆ្លើយតបទៅនឹងគ្រាអាសន្ន។

៥. **ក្រុមអាយុ:** ឱកាសទទួលការអប់រំ គួរតែផ្តល់អាទិភាពទៅតាមក្រុមអាយុ (ឧ. កុមារ និង យុវជន) និង ខ្លឹមសារមេរៀន (ឧទាហរណ៍ ពត៌មានសង្គ្រោះជីវិតសំរាប់បុគ្គលទាំងអស់ក្នុងដំណាក់កាលដំបូងនៃគ្រោះអាសន្ន)។ នៅពេលគ្រោះអាសន្នមានស្ថិរភាពល្អឡើងវិញហើយ គេគួរពង្រីកឱកាសទទួលការអប់រំដល់ក្រុមមនុស្សទាំងអស់ ដើម្បីធ្វើឱ្យជីវិតរបស់ពួកគេមានភាពប្រសើរឡើងវិញ។

៦. **ការអប់រំដែលមាន "គុណភាព" និងមាន "ការទាក់ទង":** សូមមើលឧបសម្ព័ន្ធទី១: ស្តង់ដាអប្បបរមាសំរាប់ផ្តល់ការអប់រំក្នុងគ្រាមានអាសន្ន វាក្យស័ព្ទ ដើម្បីស្វែងយល់ពីអត្ថន័យរបស់ពាក្យនិមួយៗ។

៧. **ការចូលរួមរបស់សហគមន៍:** សហគមន៍គួរចូលរួមយ៉ាងសកម្មក្នុងដំណើរការអប់រំ។ ទង្វើនេះ អាចជួយឱ្យមានការគិតគូពីចន្លោះប្រហោងនៃការទាក់ទងគ្នា ការប្រមែប្រមូលធនធានបន្ថែម ដោះស្រាយ បញ្ហាទាក់ទងទៅនឹងសន្តិសុខ និង ជំរុញឱ្យមានការចូលរួមពីក្រុមដែលបាត់បង់ផលប្រយោជន៍ (សូមអានផងដែរនូវឧបសម្ព័ន្ធទី១: វាក្យស័ព្ទ និង ស្តង់ដា១-២ នៃការចូលរួមចំនែករបស់សហគមន៍នៅលើទំព័រទី ១៧-២១។

៨. **ធនធាន:** ម្ចាស់ជំនួយគួរប្រកាន់ភាពបត់បែន និង ជួយគាំទ្រយុទ្ធសាស្ត្រមួយចំនួនដើម្បីធានាឱ្យមាននិរន្តភាពនៃការផ្តួចផ្តើមការអប់រំតាំងពីដំនាក់កាលដំបូងនៃគ្រាអាសន្នរហូតដល់ដំណាក់កាលស្តាបនាឡើងវិញ។ រដ្ឋាភិបាលជាតិមានការទទួលខុសត្រូវខ្ពស់ក្នុងការធានាឱ្យមានការអប់រំ ហើយរដ្ឋាភិបាលអាចទទួលបាននូវជំនួយមូលនិធិពីប្រភពផ្សេងៗគ្នាជាច្រើន។ ម្ចាស់ជំនួយផ្សេងៗទៀតរួមមាន សហគមន៍ អន្តរជាតិ (ទ្វេភាគី ឬ ពហុភាគី) NGOs អន្តរជាតិ និង NGOs ជនជាតិដើម, អជ្ញាធរមូលដ្ឋាន, អង្គការសាសនា ក្រុមសង្គម ស៊ីវិល និងដៃគូអភិវឌ្ឍន៍ ផ្សេងៗទៀត (សូមអានផងដែរនូវ ស្តង់ដាការវិភាគទី2, កំណត់សំគាល់ណែនាំទី៤ នៅទំព័រទី២៨)។

ការរៀបចំផែនការធនធាន គួរតែផ្តោតទៅលើការពង្រីកឱកាសទទួលការអប់រំ។ ក៏ប៉ុន្តែ គេក៏គួធ្វើការពិចារណាផងដែរ ទៅលើចីរភាព ការរៀបចំផែនការរយៈពេលវែង (ដោយរួមបញ្ចូលផងដែរនូវករណី ដែលគ្រោះអាសន្នអាចអូសបន្លាយពេលវេលា) ព្រមទាំងសេណារីយ៉ូនៃការស្តាបនាឡើងវិញនៅពេលអនាគត។ ការសហការ និងសំរបសំរួលជាមួយអជ្ញាធរពាក់ព័ន្ធ អាចជួយធានាឱ្យមានស្ថិរភាព (សូមអានផងដែរនូវស្តង់ដាទី 3 នៃគោលនយោបាយ និងការសំរបសំរួលការអប់រំ នៅលើទំព័រទី១១០)។

ការផ្តល់ជំនួយបន្តបន្ទាប់ផ្នែកអប់រំ ទាមទារឱ្យមានការទទួលបានមូលនិធិយ៉ាងឆាប់រហ័ស (ឧ. តាមរយៈមូល

និធិបំរុងសំរាប់គ្រាអាសន្ន ឬ មូលនិធិចាប់ផ្តើមជាដើម) ។ ការផ្តល់មូលនិធិក្នុងកំឡុងពេលមានគ្រាអាសន្នដែលអូសបន្លាយ គួរតែឱ្យបានគ្រប់គ្រាន់ដើម្បីជួយផ្តល់ការអប់រំដល់កុមារ និងយុវជន ដើម្បីឱ្យពួកគេមានលទ្ធភាពបន្តការសិក្សាក្នុងកម្មវិធីសិក្សាធម្មតាបាន ។ ក្នុងដំនាក់កាលដំបូងនៃការស្ថាបនាឡើងវិញមូលនិធិ គួរត្រូវបានផ្តល់តាមតំរូវការ ដើម្បីពង្រឹងរដ្ឋបាល និង ផែនការអប់រំជាតិ ។ ធនធានម្ចាស់ជំនួយ គួរជួយឱ្យកម្មវិធីអប់រំមានលទ្ធភាពដំណើរការឡើងវិញក្នុងគ្រប់ទីតាំង តាមរយៈការប្រើប្រាស់ជំរកបណ្តោះអាសន្ន និង ការឧបត្ថម្ភនូវសម្ភារៈបង្រៀន និង សម្ភារៈសិក្សា ។

# ស្តង់ដាទី២ ការទទួលយក និង បរិស្ថានសិក្សាៈ ការការពារ និង សុខមាលភាព

បរិស្ថានសិក្សាត្រូវបានធានា និងលើកកំពស់ការការពារ និងសុខមាលភាពផ្លូវចិត្ត និងអារម្មណ៍របស់អ្នកសិក្សា

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- សាលារៀន និង បរិស្ថានសិក្សាផ្សេងៗ មានទីតាំងនៅជិតក្រុមមនុស្សដែលត្រូវសិក្សា (សូមអានកំណត់សំគាល់ណែនាំទី ១-២)
- ផ្លូវឆ្ពោះទៅកាន់បរិស្ថានសិក្សា មានសុវត្ថិភាព និងធានាសំរាប់បុគ្គលគ្រប់រូប (សូមអានកំណត់សំគាល់ណែនាំទី៣)
- បរិស្ថានសិក្សា ពុំមានគ្រោះថ្នាក់អ្វីដល់អ្នកសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី ៤-៥)
- មានកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន កូនសិស្ស និង សហគមន៍ ដើម្បីបង្កើតឱ្យមានសុវត្ថិភាព សន្តិសុខ និង ការការពារ ។
- គ្រូបង្រៀន និង បុគ្គលិកអប់រំផ្សេងៗទៀត ត្រូវបានបំពាក់នូវជំនាញក្នុងការផ្តល់ការគាំទ្រចិត្តសាស្រ្តសង្គម ដើម្បីបង្កើត សុខមាលភាពផ្នែកស្មារតីដល់អ្នកសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី ៦)
- សហគមន៍ មានការចូលរួមសំរេចចិត្តទៅលើទីតាំងនៃបរិស្ថានសិក្សា និងក្នុងការបង្កើតប្រព័ន្ធ និង គោលនយោបាយធានាពីសុវត្ថិភាព និង សន្តិសុខរបស់អ្នកសិក្សា។
- អាហាររូបត្ថម្ភ និង អាហារសម្រន់ការស្រេកឃ្លានរយៈពេលខ្លី ត្រូវបានដោះស្រាយ ដើម្បីឱ្យមានការរៀនសូត្រដ៏មានប្រសិទ្ធភាពក្នុងទីតាំងដែលត្រូវសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី ៧)

## កំណត់សំគាល់ណែនាំ

១. **ការនៅជិតៈ** គួរត្រូវបានឱ្យនិយមន័យយោលទៅតាមស្តង់ដាមូលដ្ឋាន ឬ ស្តង់ដាជាតិដោយគិតពិចារណាទៅលើបញ្ហា សន្តិសុខ ឬ បញ្ហាផ្សេងៗដែលទាក់ទងនឹងសុវត្ថិភាព ។ នៅពេលដែលទីតាំងត្រូវរៀននៅឆ្ងាយ

ពិសិស្ស គេគួរជំរុញឱ្យមានថ្នាក់ពិសេសមួយដែលមានទីតាំងជិតផ្ទះអ្នកដែលពុំអាចធ្វើដំណើរឆ្ងាយបាន ដូចជា កុមារតូចៗ ឬ ក្មេងស្រីជំទង់ ជាដើម ។

២. **សន្តិសុខ:** ប្រសិនបើពុំមានទីធ្លាសិក្សាធម្មតា ឬមានដែរតែពុំមានសន្តិសុខល្អទេនោះ គេគួរជ្រើសរើសទីតាំងផ្សេងទៀតដែលមានសុវត្ថិភាព និង សន្តិសុខ ។ សាលារៀនមិនគួរត្រូវបានប្រើប្រាស់ជាជំរកបណ្តោះអាសន្នរបស់កងកំលាំងសន្តិសុខឡើយ ។

៣. **ផ្លូវឆ្ពោះទៅកាន់ទីតាំងសិក្សា:** រដ្ឋមានកាតព្វកិច្ចធានាសន្តិសុខ ហើយសន្តិសុខនេះអាចទាក់ទងដល់ការរាយបណ្តាក់កំលាំងប៉ូលីស និង យោធាឱ្យជួយការពារតាមការដែលចាំបាច់ ។ ដើម្បីពង្រឹងការការពារ និងដើម្បីធានាថាផ្លូវឆ្ពោះទៅកាន់ទីតាំងសិក្សាមានសុវត្ថិភាព និង មានសន្តិសុខសំរាប់អ្នកសិក្សានិងបុគ្គលិកអប់រំទាំងអស់គ្នា (ដោយមិនគិតពី យេនឌ័រ, អាយុ, សញ្ជាតិ, ពូជសាសន៍, ជនជាតិ ឬសមត្ថភាពរាងកាយ) សហគមន៍ គួរពិភាក្សា និង យល់ព្រមទៅលើវិធានការណ៍ការពារទុកជាមុនមួយចំនួន ដូចជា ឱ្យមានមនុស្សពេញវ័យជូនដំណើរជាដើម ។ ប្រការនេះ ក៏អាចជាផ្នែកមួយនៃរបៀបវារៈរបស់គណកម្មការអប់រំសហគមន៍ផងដែរ ។

៤. **ការការពារ:** កូនសិស្ស គួរទទួលបានការការពារពីគ្រោះថ្នាក់នានា ដែលអាចប៉ះពាល់ដល់ពួកគេដូចជា (ប៉ុន្តែមិនមែនកំណត់តែ) គ្រោះថ្នាក់ធម្មជាតិ គ្រឿងសព្វាវុធ គ្រាប់រំសេវ គ្រាប់មីន គ្រាប់ដែលមិនទាន់ផ្ទុះ បុគ្គលមានអាវុធ ទីតាំងដែលមានការបាញ់ប្រហារគ្នា ការគំរាមកំហែងនយោបាយ និងយោធា ព្រមទាំងការជ្រើសរើសទ័ពផ្សេងៗ ។ កូនសិស្ស ជាពិសេសអ្នកដែលមកពីក្រុមជនភាគតិច និង កុមារីច្រើនតែជាមុខសញ្ញានៃការរំលោភបំពាន ហឹង្សា ជ្រើសរើសឱ្យធ្វើទ័ព និងការចាប់ពង្រត់នៅពេលដែលគេធ្វើដំណើរទៅ និង មកពីសាលារៀន ។ ក្នុងករណីទាំងនេះ សន្តិសុខកូនសិស្សអាចត្រូវបានពង្រឹងតាមរយៈការប្រមូលផ្តុំនូវយុទ្ធនាការពតិមានសហគមន៍ និង ការឱ្យមនុស្សពេញវ័យក្នុងសហគមន៍ជូនដំណើរពួកគេ ។ ក្នុងតំបន់ដែលកូនសិស្សត្រូវតែដើរត្រលប់មកផ្ទះវិញនាពេលយប់ តាម ផ្លូវដែលគ្មានពន្លឺគ្រប់គ្រាន ខោអាវ ឬសំពៀតរបស់គេគួរតែមានភ្ជាប់ដោយរបស់ ឬក្រណាត់ដែលអាចចាំងពន្លឺផ្លាតមកវិញ ឬ គួរតែមានការជូនដំណើរដោយពន្លឺភ្លើងពិល ។ ប្រសិនបើអាចធ្វើទៅបាន វាគួរតែមានវត្តមានស្ត្រីៗនៅកន្លែងសិក្សាដើម្បី បង្កើតទំនុកចិត្តដល់សិស្សដែលជានារីភេទ ។ បន្ថែមពីលើនេះ កម្មវិធីអប់រំ គួរបញ្ចូលនូវការតាមដានពីកិរិតនៃការបំពារបំពានដែលកុមារី និងស្ត្រីទាំងឡាយបានជួបប្រទះ ។

៥. **ការគ្រប់គ្រងថ្នាក់រៀន ដែលមានលក្ខណៈអហិង្សា:** ក្នុងចំណោមកត្តាផ្សេងៗ ការគំរាមកំហែងរួមបញ្ចូលនូវភាពតានតឹងផ្លូវចិត្ត អំពើហិង្សា ការរំលោភបំពាន និង ភាពរើសអើង ។ គ្រូៗត្រូវទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រគ្រប់គ្រងថ្នាក់រៀនដែលមានលក្ខណៈវិជ្ជមាន ដើម្បីធានាថាពុំមានការកើតមាននូវអំពើហឹង្សាទេ ។ ការធ្វើទណ្ឌកម្មលើរាងកាយសិស្សពុំគួរឱ្យកើតមាន ឬ ពង្រឹងបន្ថែមទេ ។

**៦. សុខមាលភាព៖** សុខមាលភាពផ្លូវអារម្មណ៍ និងផ្លូវចិត្ត គួរត្រូវបានយល់ដឹងយ៉ាងពេញលេញ អំពីអ្វីទៅដែលជាការប្រសើរសំរាប់បុគ្គលម្នាក់ៗ វាមានដូចជា សន្តិសុខ ការការពារ គុណភាពសេវា សុភមង្គល និង ភាពកក់ក្តៅក្នុងទំនាក់ទំនងរវាងអ្នកសិក្សា និងអ្នកអប់រំ ។ សកម្មភាព ដែលប្រើប្រាស់ដើម្បីធានាឱ្យមាននូវសុខមាលភាពកូនសិស្ស នោះគួរតែផ្តោតទៅលើការពង្រឹងការអភិវឌ្ឍន៍ផ្លូវបញ្ញា ទំនាក់ទំនងរឹងមាំក្នុងសង្គម ព្រមទាំងទៅលើសុខភាពល្អ ។ ការធានានូវសុខមាលភាពនោះ ជាចំណែកមួយ ដែលធ្វើឱ្យសិស្សអាចបញ្ចប់យ៉ាងជោគជ័យនូវកម្មវិធីអប់រំទោះក្នុងប្រព័ន្ធ ឬ ក្រៅប្រព័ន្ធក្តី (សូមអានឧបសម្ព័ន្ធទី១ លើទំព័រទី៦៦ដែលស្តីពីតារាងពិនិត្យផ្នែកចិត្តសង្គម) ។

**៧. អាហាររូបត្ថម្ភ៖** តំរូវការអាហាររូបត្ថម្ភ និង ដើម្បីបំបាត់ការស្រេកឃ្លានមួយរយៈខ្លីគួរត្រូវបានដោះស្រាយតាមរយៈ ការផ្តល់អាហារនៅតាមសាលារៀន និងកម្មវិធីសន្តិសុខស្បៀងផ្សេងៗទៀតនៅក្រៅបរិស្ថានសិក្សា។ ប្រសិនបើកម្មវិធីផ្តល់អាហារតាមសាលារៀនត្រូវបានអនុវត្ត គេគួរអនុវត្តតាមសេចក្តីណែនាំនានាដែលទទួលស្គាល់ និងប្រើប្រាស់ដោយភ្នាក់ងារដទៃទៀត ដូចជាកម្មវិធី ស្បៀងអាហារពិភពលោកជាដើម (សូមអានឧបសម្ព័ន្ធទី២ លើទំព័រទី៦៨ ដែលស្តីពីតារាងពិនិត្យកម្មវិធីផ្តល់ស្បៀងតាមសាលារៀន ។)

## ស្តង់ដាទី៣ នៃការទទួលយក និង បរិស្ថានសិក្សា៖ អគារ/បរិស្ថានសិក្សា

អគារ/បរិស្ថានសិក្សាមានលក្ខណៈអំណោយផលដល់សុខមាលភាពរាងកាយនៃអ្នកសិក្សា

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយនឹង កំណត់សំគាល់ណែនាំ)

- រចនាសម្ព័ន្ធ និង ទីតាំងសិក្សា អាចឱ្យអ្នកសិក្សាទៅបាន ដោយមិនគិតពីសមត្ថភាពរាងកាយទេ។
- អគារ/បរិស្ថានសិក្សាត្រូវបានដាក់សំគាល់ព្រំប្រទល់ ឬដាក់សញ្ញាច្បាស់លាស់ បើអាចធ្វើទៅបាន។
- រចនាសម្ព័ន្ធអគារ ដែលប្រើសំរាប់ជាទីតាំងសិក្សា មានលក្ខណៈសមរម្យតាមស្ថានការណ៍ ហើយមានកន្លែងគ្រប់គ្រាន់សំរាប់ថ្នាក់រៀន និង រដ្ឋបាល ទីធ្លាលេងកំសាន្ត និង បន្ទប់អនាម័យ (សូមអាន កំណត់សំគាល់ ណែនាំ ទី១)។
- បន្ទប់រៀន និង ការរៀបចំកន្លែងអង្គុយត្រូវរៀបទៅតាមអ្វីដែលបានយល់ព្រមរួចហើយ រវាងចន្លោះពីសិស្សម្នាក់ទៅសិស្សម្នាក់ និង ពីសិស្សទៅគ្រូបង្រៀន ហើយវាក៏ត្រូវស៊ីគ្នាទៅតាមកំរិតថ្នាក់ ដើម្បីជំរុញឱ្យគេអាចអនុវត្តវិធីសាស្ត្រចូលរួម និង សិស្សមជ្ឈមណ្ឌលបាន (សូមអាន កំណត់សំគាល់ ណែនាំទី១)។
- សហគមន៍ចូលរួមក្នុងការសាងសង់ និង ថែរក្សាអគារ/បរិស្ថានសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី២)។
- សុខភាព និង អនាម័យមូលដ្ឋានត្រូវបានបង្កើតឱ្យមានក្នុងបរិស្ថានសិក្សា។
- បន្ទប់អនាម័យត្រូវបានផ្តល់យ៉ាងគ្រប់គ្រាន់ ដោយគិតពិចារណាទៅលើអាយុ ភេទ ព្រមទាំងតំរូវការអប់រំពិសេសនានា ដោយគិតបញ្ចូលតាំងពីលទ្ធភាពប្រើប្រាស់វាដោយមនុស្សពិការផងដែរ (សូមអាន កំណត់សំគាល់ ណែនាំទី៣)។
- បរិមាណនៃទឹកស្អាត ព្រមទាំងទឹកសំរាប់សំអាតអនាម័យផ្ទាល់ខ្លួនត្រូវមានគ្រប់គ្រាន់ក្នុងទីតាំងសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី៤)។

**គំណត់សំគាល់ណែនាំ**

**១. អគារៈ** គេគួរគិតពីភាពសមរម្យនៃអគារសិក្សាដោយពិចារណាទៅលើការប្រើប្រាស់វាជាយូរអង្វែង (ក្រោយគ្រាអាសន្ន) ពីថវិកាដែលមានពីការចូលរួមពីសហគមន៍ ហើយថាតើវាអាចថែរក្សាដោយអជ្ញា ធរមូលដ្ឋាន និង, ឬ សហគមន៍មូលដ្ឋានក្នុងចំនាយដ៏សមរម្យណាមួយដែរ ឬទេ។ គេគួរគិតពិចារណាទៅលើសមាសភាគខាងក្រោមនេះ

- ប្រើប្រាស់សម្ភារៈផលិតក្នុងស្រុកដើម្បីសាងសង់អគារសិក្សា ប្រសិនបើមាន។ គេគួរចាត់វិធានការណ៍នានាដើម្បីធានាថាការសាងសង់អស់សោហ៊ុយតិច ហើយលក្ខណៈអគារ (ឧទាហរណ៍ៈ ដំបូល, កំរាល) មានភាពធន់មាំល្អ។
- គេគួមានពន្លឺគ្រប់គ្រាន់ ខ្យល់ និងកំដៅអាចចេញចូលបានគ្រប់គ្រាន់ (ប្រសិនបើចាំបាច់) ដើម្បីបង្កើននូវគុណភាពរបស់បរិស្ថាននៃការបង្រៀន និង ការរៀន។
- គេគួរដាក់ចុះនូវស្តង់ដាមូលដ្ឋានកំណត់ពីចំនួនអតិបរមានៃកូនសិស្សក្នុងថ្នាក់និមួយៗ ហើយគេគួរប្រឹងប្រែងផ្តល់នូវទីតាំងថ្នាក់បន្ថែមប្រសិនបើចំនួនសិស្សចូលរៀនមានការកើនឡើង ដើម្បីអាចកាត់បន្ថយនូវការប្តូរវេនសិក្សាច្រើនពេល។
- កម្មវិធីសិក្សា មិនចាំបាច់រង់ចាំទាល់តែសមាសភាគហេដ្ឋារចនាសម្ព័ន្ធ និងអ្វីដែលបានលើកឡើងខាងលើមានរួចរាល់នោះទេ។ ក៏ប៉ុន្តែ សមាសភាគទាំងនោះ គួរត្រូវបានផ្តល់ឱ្យយ៉ាងប្រញាប់តាមការដែលអាចធ្វើ ទៅបាន (សូមអាន ទំនាក់ទំនងទៅនឹងឧបសម្ព័ន្ធស្តង់ដា Sphere ស្តីអំពី CD-ROM ស្តង់ដាអប្បបរមានៃការផ្តល់ការអប់រំក្នុងគ្រាមានអាសន្ន សំរាប់ស្តង់ដាជំរក Sphere ដែលពាក់ព័ន្ធ)។

**២. ការថែទាំបរិស្ថានសិក្សា** គួររួមបញ្ចូលនូវការថែទាំបរិក្ខា (ឧទាហរណ៍ បង្គន់ បំពង់ទឹក...។ល។) និង គ្រឿងសង្ហារឹមនានា (ឧទាហរណ៍ៈ តុ កៅអី ក្តាខៀន ទូសៀវភៅ...។ល។)។

**៣. បង្គន់អនាម័យ** គួររួមបញ្ចូលតាំងពីកន្លែងដាក់សំរាម (ធុង ឬ រណ្តៅសំរាម) លូបង្ហូរ (រណ្តៅ បំពង់ លូបង្ហូរ) និងទឹកគ្រប់គ្រាន់សំរាប់អនាម័យផ្ទាល់ខ្លួន និងដើម្បីសំអាតបង្គន់។ បរិស្ថានសិក្សា គួរតែមានបង្គន់ដោយឡែកៗសំរាប់មនុស្សប្រុស និង ស្រី ហើយដែលបិទបាំងជិត។ សម្ភារៈអនាម័យ គួរតែមានសំរាប់នារីភេទ (សូមអាន ទំនាក់ទំនងទៅនឹង ឧបសម្ព័ន្ធស្តង់ដា Sphere ស្តីអំពី CD-ROM ស្តង់ដាអប្បបរមានៃការផ្តល់ការអប់រំក្នុងគ្រាមានអាសន្ន សំរាប់ស្តង់ដា Sphere ដែលមានការពាក់ព័ន្ធ និងកាកសំណល់សរីរាង្គ និងសំល្បែកបំពាក់ដែលមានការពាក់ព័ន្ធ)។

**៤. ទឹក** គួរតែមាននៅក្នុង ឬទីកន្លែងជិតនឹងបរិស្ថានសិក្សាដែលស្របនឹងស្តង់ដាជាតិនិងអន្តរជាតិ ( សូមអាន ទំនាក់ទំនងទៅនឹង ឧបសម្ព័ន្ធស្តង់ដា Sphere ស្តីពី CD-ROM ស្តង់ដា អប្បបរមានៃការផ្តល់ការអប់រំក្នុងគ្រាមានអាសន្ន សំរាប់ស្តង់ដា Sphere អំពីទឹកដែលពាក់ព័ន្ធ)។

# ការទទួលយក និង បរិស្ថានសិក្សាៈ ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ៈ តារាងពិនិត្យចិត្តសាស្ត្រសង្គម

វិធីសាស្ត្រស្ទង់មតិជាក់លាក់ ត្រូវពឹងផ្អែកទៅលើស្ថានការណ៍ និង វប្បធម៌មូលដ្ឋាន។ ចំណុចខាងក្រោមនេះ តាងឱ្យប្រភេទពត៌មានដែលមានអត្ថប្រយោជន៍ក្នុងការលើកឡើងនូវបញ្ហានានា ដែលពាក់ព័ន្ធនឹងសុខមាលភាពចិត្តសាស្ត្រ និងការស្តារឡើងវិញ។

### ស្ថានភាពទូទៅ

- តើស្ថានការណ៍រំលោភសិទ្ធិកុមារ គឺជាមូលហេតុធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តឬ?
- តើស្ថានការណ៍រំលោភបំពាននេះឈប់មានហើយ ឬក៏នៅតែបន្តបង្កើតនូវបរិយាកាសអសន្តិសុខដល់កុមារ និងគ្រួសាររបស់គេ?
- តើគ្រួសាររស់នៅជាមួយគ្នាឬ?
- តើគេមានភាពជាឯកជនគ្រប់គ្រាន់ ឬទេ?
- តើគេកំពុងធ្វើអ្វីខ្លះដើម្បីឱ្យគ្រួសារនិមួយៗមានលទ្ធភាពរស់នៅក្នុងភាពថ្លៃថ្នូរ និងផ្តល់នូវការថែរក្សា និងការពារដល់កូនៗរបស់គេ? តើអ្វីខ្លះទៀត ដែលគួរធ្វើ?
- តើអ្វីទៅជាសកម្មភាពធម្មតាក្នុងសហគមន៍ដើម្បីជួយដល់កុមារដែលស្ថិតក្នុងស្ថានការណ៍លំបាក?
- តើអ្វីទៅជាយន្តការធម្មតារបស់សហគមន៍ដើម្បីឆ្លើយតប និង ដោះស្រាយនូវវិបត្តិចិត្តសាស្ត្រ? តើគេត្រូវពង្រឹងវាយ៉ាងដូចម្តេច?
- តើការរៀបចំការរស់នៅទូទៅ និង ការរៀបចំសង្គមមនុស្សមានជះឥទ្ធិពលយ៉ាងណាខ្លះដល់ការការពារ និងថែរក្សាកុមារ?
- តើគេគួរអនុវត្តន៏វិធានការណ៍ណាខ្លះ ដើម្បីលើកស្ទួយស្ថានភាពរស់នៅរបស់កុមារ និងគ្រួសាររបស់គេ?
- តើមានបុគ្គលណាខ្លះក្នុងសហគមន៍ ដែលអាចផ្តល់នូវសកម្មភាពជាប្រចាំដល់កុមារ ដូចជាការអប់រំក្រៅប្រព័ន្ធ ល្បែងនិងការលេងកំសាន្ត?

### ឪពុកម្តាយ

- តើអ្វីទៅជាលក្ខណៈពិបាក និងការតានតឹងផ្លូវចិត្ត ដែលជួបប្រទះដោយឪពុកម្តាយ ហើយដែលកំពុងជះឥទ្ធិពលដល់សុខមាលភាពពួកគាត់ ក៏ដូចជារបៀបដែលគាត់ថែរក្សាកូនចៅ?
- តើគេគួរអនុវត្តវិធានការណ៍ណាខ្លះដើម្បីកាត់បន្ថយការពិបាកនេះ?

- តើគេឃើញឪពុកម្តាយវាយដំកូនគាត់ លើសហួសពីអ្វីដែលបានអនុញ្ញាតិក្នុងក្របខ័ណ្ឌវប្បធម៌ដែលគាត់កំពុងរស់នៅដែរ ឬទេ?
- តើមានឱកាសណាដែលឪពុកម្តាយអាចពិភាក្សា និងស្វែងរកការជួយដល់ការពិបាកផ្លូវចិត្តនានាដែលពួកគាត់ និងកូនៗគាត់ត្រូវតែប្រឈមមុខជាមួយ?

## កុមារ

- តើកុមារៗកំពុងបានផ្តល់នូវការថែទាំ និងថែរក្សា ដែលមិនគ្រប់គ្រាន់ ឬទេ?
- តើមានវិធានការណ៍ណាខ្លះ ដែលអាចធ្វើឡើងដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែរក្សា ដែលកុមារទាំងនោះទទួលបាន?
- តើមានកុមារដែលរស់នៅម្នាក់ឯងឬទេ?
- តើមានកុមារ ដែលមានអកប្បកិរិយាកោងកាចនិងហឹង្សាដែរឬទេ?
- តើកុមារត្រូវបានផ្តល់នូវឱកាសសមរម្យដើម្បីនិយាយអំពីកង្វល់ គំនិត និងសំនួរ ដែលគេមានដែរឬទេ?
- តើកុមារមានឱកាសលេងកំសាន្តដែរឬទេ?
- តើមានការដោះស្រាយដែរ ឬទេ ចំពោះតំរូវការពិសេសនៃកុមារ ដូចជាពុំមានអ្នកជូនដំណើរទៅរៀន ឬស្នាក់នៅយូរអង្វែងក្នុងជំរុំ និងកុមារដែលស្ថិតក្នុងការឃុំមិនឱ្យចេញទៅណា?

## សេវាកម្ម

- តើមានការផ្តល់សកម្មភាពអប់រំ ឬ សកម្មភាពផ្សេងៗទៀតដែរ ឬទេ ដើម្បីឱ្យកុមារមានលទ្ធភាពចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ជាប្រចាំ និងដើម្បីបង្កើតឡើងវិញនូវភាពដែលធ្វើអ្វីជាប្រចាំនោះ?
- តើជនភៀសខ្លួនពេញវ័យ និង កុមារទទួលបាននូវសេវាកម្មសង្គមនានា ដើម្បីជួយឱ្យគេដោះស្រាយការលំបាក ដែរឬទេ?
- តើមានប្រព័ន្ធណាមួយ ដែលធ្វើការកត់សំគាល់ និងជួយដល់កុមារ ដែលកំពុងមានភាពតានតឹងផ្នែកចិត្តសាស្ត្រដែរឬទេ?
- តើការបណ្តុះបណ្តាល និង ការជ្រោមជ្រែងកំពុងតែផ្តល់ដល់គ្រូបង្រៀន្ត ដែរឬទេ? តើមានបុគ្គលិកថែរក្សាសុខភាព និង បុគ្គលិកសេវាកម្មផ្សេងៗទៀត សំរាប់ជួយពួកគាត់ឱ្យកាន់តែប្រសើរឡើងដល់កុមារដែរ ឬទេ?
- តើមានសេវាកម្មសុខភាពផ្លូវចិត្តជំនាញណា ដែលគេអាចបញ្ជូនកុមារដែលកំពុងមានភាពតានតឹងផ្លូវចិត្តធ្ងន់ធ្ងរទៅកាន់កន្លែងនោះដែរ ឬទេ?

**ប្រភព:** UNICEF, កែសំរួលចេញពី *កុមារភៀសខ្លួន : សេចក្តីណែនាំស្តីពីការការពារ និង ការថែទាំ* UNHCR, 1994

# ឧបសម្ព័ន្ធទី២: តារាងពិនិត្យកម្មវិធីផ្តល់អាហារតាមសាលារៀន

សំនួរខាងក្រោមនេះ មានសារសំខាន់សំរាប់សួរ ប្រសិនបើស្បៀងអាហារត្រូវបានកំពុងពិចារណាថាជាធនធានមួយសំរាប់អន្តរាគមន៍អប់រំ:

## គោលបំណងកម្មវិធី

- ប្រសិនបើស្បៀងអាហារត្រូវបានស្នើឡើង តើវានឹងត្រូវប្រើប្រាស់យ៉ាងដូចម្តេច? ការផ្តល់អាហារតាមសាលារៀន អាហារឧបត្ថម្ភដែលត្រូវយកទៅផ្ទះ អាហារសំរាប់ការងារ អាហារសំរាប់ការបណ្តុះបណ្តាល ឬក៏អាហារសំរាប់គ្រូបង្រៀន?
- តើហេតុអ្វីបានជាកម្មវិធីផ្តល់អាហារតាមសាលារៀន (ឬកម្មវិធីផ្សេងៗទៀត) ជាជំរើសសមរម្យក្នុងស្ថានភាពបច្ចុប្បន្ន នេះ?
- តើអ្វីទៅជាគោលបំនងនៃកម្មវិធីនេះ? តើការស្នើរឱ្យប្រើប្រាស់អាហារ, ស្បៀង ជាកត្តាមួយដែលឆ្លើយតបទៅនឹងតំរូវការអប់រំឬ? តើអាហារនេះនឹងជួយទាក់ទាញសិស្ស ឱ្យមករៀនកាន់តែច្រើនឬ?
- តើគោលបំនងណាមួយ ដែលមានភាពជាក់លាក់ក្នុងស្ថានភាពគ្រាអាសន្ននេះ?
- តើអ្នកមានទិន្នន័យចាំបាច់ ដើម្បីពន្យល់ពីតំរូវការក្នុងការដោះស្រាយគោលបំនងនេះដែរ ឬទេ (ស្ថានភាពអាហាររូបត្ថម្ភ ស្ថិតិសិស្សចុះឈ្មោះចូលរៀន និងវត្តមានក្នុងថ្នាក់... ។ល ។)?

## ប្រជាជនគោលដៅ

- តើអ្នកណាដែលជាអ្នកទទួលផលប្រយោជន៍ពីកម្មវិធី?
- តើអ្នកមានទិន្នន័យដើម្បីកំណត់សាលារៀន ឬតំបន់ដែលទទួលការរងគ្រោះខ្លាំង ឬដែលកំពុងត្រូវការជំនួយខ្លាំងជាងគេ (ស្ថានភាពសន្តិសុខស្បៀង ស្ថិតិអក្ខរកម្ម ការចុះឈ្មោះចូលរៀន... ។ល ។) ដែរឬទេ?
- តើក្រុមណាខ្លះដែលអាចទទួលប្រយោជន៍ពីអាហារឧបត្ថម្ភ ដែលអាចយកទៅផ្ទះបាន (ឧទាហរណ៍ កុមារី ក្រុមភាគតិច... ។ល ។)?

## ការពង្រឹងសមត្ថភាព និរន្តភាព និង ការសំរបសំរួល

- តើសកម្មភាពពង្រឹងសមត្ថភាពអ្វីខ្លះ ដែលចាំបាច់មុននឹងការចាប់ផ្តើមកម្មវិធី?
- តើសាលារៀនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ឬទេ ដើម្បីជួយដល់កម្មវិធីផ្តល់អាហារតាមសាលារៀននោះ (ឧ. ការមានទឹក បរិក្ខាចំអិនអាហារ ឧបករណ៍... ។ល ។)?
- តើអ្វីទៅជាតំរូវការបច្ចុប្បន្នសំរាប់ការអប់រំ ក្នុងចំណោមសហគមន៍ ឪពុកម្តាយ កុមារខ្លួនឯង? តើស្បៀងអាហារនឹងផ្លាស់ប្តូរតំរូវការនោះយ៉ាងណាដែរ?

- តើសហគមន៍ ឪពុកម្តាយ គ្រូបង្រៀន កូនសិស្ស មន្ត្រីអប់រំមើលឃើញយ៉ាងណា ពីការផ្តល់អាហារនេះ? តើការប្រើប្រាស់អាហារមានសក្តានុពលភាព បង្កើត ឬធ្វើឱ្យធ្ងន់ធ្ងរឡើងនូវស្ថានភាពតានតឹងរវាង និង នៅក្នុងសហគមន៍ដែរ ឬទេ?
- តើហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះដែលត្រូវមាន មុននឹងចាប់ផ្តើមធ្វើការចែកចាយអាហារ? តើប្រពន្ធ័ដេញថ្លៃផ្គត់ផ្គង់ និង កិច្ចសន្យាអ្វីខ្លះដែលត្រូវរៀបចំឡើង?
- តើហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះ ដែលត្រូវមានមុននឹងចាប់ផ្តើមចំអិនអាហារ និងផ្តល់អាហារដល់កុមារ?
- តើត្រូវរៀបចំអ្វីខ្លះដើម្បីបង្កើតការិយាល័យ ឃ្លាំងអាហារ និងមូលដ្ឋានដឹកជញ្ជូន? ទូរគមនាគមន៍? គ្រឿងដឹកជញ្ជូន និង ផ្លូវដឹកជញ្ជូន?
- តើមានគ្រូបង្រៀន និងសម្ភារៈគ្រប់គ្រាន់ដែរឬទេ ហើយតើមានអគារគ្រប់គ្រាន់ ដើម្បីទាញយក និងបំរើដល់សិស្សបន្ថែមឬទេ? តើការផ្តល់អាហារអាចនឹងគ្របដណ្តប់យ៉ាងណាខ្លះដល់ប្រព័ន្ធអប់រំ ដែលកំពុងតែមានភារកិច្ចធ្ងន់ធ្ងររួចទៅហើយនោះ?
- តើស្បៀងអាហារនឹងមាននិរន្តភាពឬទេ? ប្រសិនបើមាន តើយ៉ាងណា? តើយុទ្ធវិធីអ្វីដែលត្រូវធ្វើដើម្បីដកចេញនូវជំនួយស្បៀងអាហារនោះ? តើការដកចេញនេះមានការប៉ះពាល់យ៉ាងណាខ្លះដល់ការសិក្សារបស់កុមារ?
- តើមានភ្នាក់ងារមនុស្សធម៌ផ្សេងៗទៀតដែលកំពុងធ្វើការផ្នែកអប់រំក្នុងតំបន់ដូចគ្នា ឬជិតខាងគ្នាដែរឬទេ? តើគេមានផែនការប្រើប្រាស់ស្បៀងអាហារជាធនធានមួយនៃកម្មវិធីអប់រំគេដែរឬទេ? ប្រសិនបើមែន តាមរូបភាពអ្វី? តើគេមានសុឆន្ទៈ ដើម្បីសំរបសំរួល ឬទេ? តើអាហារនឹងប្រើយ៉ាងស្មើៗគ្នាដោយភ្នាក់ងារផ្សេងៗគ្នាដែរឬទេ? តើការផ្តល់អាហារមិនស្មើគ្នា អាចទាញយកចំនួនសិស្ស និងគ្រូបង្រៀនពីសាលា, តំបន់មួយទៅសាលា និង តំបន់មួយទៀតយ៉ាងណាខ្លះ?
- តើផ្នែកបុគ្គលិក មានការជាប់ទាក់ទងយ៉ាងណាខ្លះដល់យើង និង ដៃគូរការងារ? តើចំនួនបុគ្គលិកបច្ចុប្បន្ននេះមានលទ្ធភាពភាពគ្រប់គ្រាន់ក្នុងការទទួលភារកិច្ចគ្រប់គ្រងការជួយផ្តល់អាហារដល់កម្មវិធីអប់រំ ដោយពុំមានការបន្ថែបន្ទំ ខុសពីភារកិច្ចសព្វថ្ងៃនេះទេ? តើតំរូវឱ្យមានការបន្ថែមបុគ្គលិក ឬទេ?

## ការជ្រើសរើសស្បៀង និង អាហារូបត្ថម្ភ

- តើស្បៀងអាហារអ្វីខ្លះ ដែលអ្នកត្រូវផ្តល់?
- តើកម្មវិធីនេះនឹងរួមបញ្ចូលនូវរបបស្បៀង ដែលត្រូវយកទៅផ្ទះដែរ ឬអត់? តើកម្មវិធីនេះនឹងត្រូវពិនិត្យតាមដានយ៉ាងដូចម្តេច?
- តើមុខស្បៀងណាខ្លះដែលមាន?

- តើក្នុងចំណោមសិស្សសាលាមានបញ្ហាណាមួយដូចជាជំងឺ កង្វះអាហាររូបត្ថម្ភ ឬមានព្រូនពោះវៀន (infestation) ដែរ ឬទេ? ប្រសិនបើមានតើបញ្ហាកង្វះមីក្រូសារជាតិចាំបាច់មួយចំនួន អាចដោះស្រាយបានតាមរយៈ ការជ្រើសរើសមុខស្បៀង ឬក៏ត្រូវប្រើស្បៀងដែលមានបញ្ចូលសារជាតិទាំងនោះ?
- បើគិតពីវប្បធម៌ទីកន្លែង តើកូនសិស្សមានចំណង់ចំណូលចិត្តជាមួយប្រភេទអាហារណាខ្លះ ហើយរសជាតិអាហារបែបណាដែលគេចង់បាន?

## ការដោះស្រាយសុវត្ថិភាពស្បៀង សុខភាព និង អនាម័យ

- តើមានបង្គន់អនាម័យ និង ទឹកដែលអាចដងយកមកប្រើប្រាស់បាននៅសាលារៀនដែរ ឬទេ?
- តើការតាក់តែងកម្មវិធីអាចបញ្ចូលការបណ្តុះបណ្តាលតាមបែបណាដើម្បីអប់រំ និងពង្រឹងសមត្ថភាពអ្នកចែកចាយស្បៀងអាហារ?
- តើគ្រោះភ័យនៃការឆ្លងជម្ងឺ អាចត្រូវបានកាត់បន្ថយតាមបែបណា?
- តើក្នុងចំណោមសិស្សសាលា មានបញ្ហាព្រូនក្នុងពោះវៀនដែរ ឬទេ? បើមាន តើការផ្តល់ថ្នាំទំលាក់ដង្កូវពោះវៀន នោះជាការចាំបាច់មួយផ្នែក នៃកម្មវិធីផ្តល់អាហារតាមសាលារៀនដែរ ឬទេ?
- តើមានកម្មវិធីអប់រំបង្ការជំងឺ HIV/AIDS ដល់កូនសិស្សដែរ ឬអត់សព្វថ្ងៃនេះ?
- តើកម្មវិធីបង្ការជំងឺ HIV/AIDS អាចដាក់បញ្ចូលក្នុងការតាក់តែងកម្មវិធីបានយ៉ាងដូចម្តេច?
- តើមានផែនការបម្រុងអ្វីខ្លះ ប្រសិនបើគ្រូបង្រៀនមួយចំនួនបានឆ្លង ឬស្លាប់ដោយ HIV/AIDS?

## កំរិតពេលវេលា

- តើប្រតិបត្តការជំនួយនេះមានរយៈពេលប្រហែលប៉ុន្មាន?
- តើមានទិន្នន័យអ្វីខ្លះសំរាប់ដំណាក់កាលប្រតិបត្តការនិមួយៗ (ការវាយតម្លៃជំហានដំបូង ការសិក្សាជាមូលដ្ឋាន, ការពិនិត្យតាមដាន និងការវាយតម្លៃចុងក្រោយ)?
- តើស្បៀងអាហារនឹងមាននៅពេលណា?
- តើនឹងមានការសកម្មភាពពង្រឹងសមត្ថភាពអ្វីខ្លះមុននឹងចាប់ផ្តើមកម្មវិធី ហើយតើកាលបរិច្ឆេទចាប់ផ្តើមកម្មវិធី អាចធ្វើនៅថ្ងៃណា?
- តើជំនួយសង្គ្រោះ (ព្រមទាំងជំនួយស្តាបនាឡើងវិញ) អាចនឹងបញ្ឈប់យ៉ាងដូចម្តេចខ្លះ? ហើយប្រសិនបើអាចធ្វើទៅបាន តើការផ្លាស់ប្តូរទៅដំនាក់កាលអភិវឌ្ឍន៍ថ្មីមួយទៀតនឹងត្រូវបានសំរេចបានតាមបែបណាដែរ?

## ម្ចាស់ជំនួយ

- តើអ្នកណាដែលរំពឹងទុកថាជាម្ចាស់ជំនួយ? តើធនធានជំនួយនឹងមាននៅពេលណា?

- តើសំណើកម្មវិធីទូលំទូលាយ និងមានលក្ខណៈពិស្តារ ដែលស្តីពីសេណារីយ៉ូ (scenario) នៃកម្មវិធីត្រូវបានសរសេរឡើងសំរាប់ម្ចាស់ជំនួយដែរ ឬទេ?
- តើស្បៀងអាហារដែលទទួលពីម្ចាស់ជំនួយមានរយៈពេលប៉ុន្មាន? ច្រើនខែ មួយទៅពីរឆ្នាំ ប្រាំទៅដប់ឆ្នាំ? (ប្រសិនបើស្បៀងអាហារទទួលបានពីម្ចាស់ជំនួយ មានរយៈពេលតែប៉ុន្មានខែទេនោះ ជំនួយនេះអាចត្រូវប្រើប្រាស់ជាគ្រឿងលើកទឹកចិត្តគ្រូបង្រៀន ប្រសើរជាងប្រើវាក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន ពីព្រោះកម្មវិធីនេះអាចប្រើពេលយូរដើម្បីបង្កើតវា) ។

**ប្រភព:** កែសំរួលចេញពី: កម្មវិធីស្បៀងអាហារពិភពលោក, ការធ្វើផែនការផ្តល់អាហារតាមសាលា ក្នុងទីកន្លែងមានគ្រោះអាសន្ន — ការវិភាគស្ថានការណ៍, ការតាក់តែងកម្មវិធី, ការអនុវត្ត, 2004, http://www.wfp.org និង សេវាកម្មសង្គ្រោះកាតូលិក: ការកំណត់ថា តើត្រូវប្រើស្បៀងអាហារជាធនធានដែរ ឬអត់, www.crs.org

# ៣. ការបង្រៀន និង ការសិក្សា

**សេចក្តីផ្តើម**

**ការសំរេចយកនូវអ្វីដែលសំខាន់សំរាប់បង្រៀន គឺជាការពិបាកសំរាប់អ្នកអប់រំគ្រប់ៗរូប ។ ក្នុងគ្រាមានអាសន្ន គេត្រូវធ្វើការសំរេចចិត្តសំខាន់ៗ អំពីលក្ខណៈសេវាកម្មអប់រំដែលត្រូវផ្តល់ ទោះក្នុងរូបភាពអប់រំក្នុងឬក្រៅប្រព័ន្ធក្តី អំពីកម្មវិធី សិក្សាដែលត្រូវអនុវត្តតាម ទោះធ្វើតាមប្រទេសកំនើត ឬប្រទេសដែលកំពុងរស់នៅក្តី និងអំពីអាទិភាពនៃការសិក្សា ទោះផ្តោតទៅលើការរស់រាន ជំនាញវិជ្ជាជីវៈ ឬការសិក្សាចំនេះដឹងក្តី ។ វាអាចទាមទារឱ្យមានការកែសំរួល ឬ បង្កើតកម្មវិធីសិក្សាថ្មីមួយ ។**

វាជាប្រការសំខាន់ដែលការអប់រំត្រូវមានភាពទាក់ទងសំរាប់អ្នកសិក្សាទាំងអស់គ្នា ។ ប្រការនេះទាមទារឱ្យមានការធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ និងទទួលទិសដៅអប់រំពីសហគមន៍ ដើម្បីកំណត់នូវតំរូវការនៃការអប់រំ ។ ជាធម្មតា វាមានន័យថាជាការធ្វើការជាមួយប្រព័ន្ធអប់រំដែលមានស្រាប់ (ប្រសិនបើអាចធ្វើទៅបាន) ជាជាងការបង្កើតឡើងនូវរចនាសម្ព័ន្ធដោយឡែកមួយទៀត ។ វាមានន័យថា ការផ្តោតទៅលើការចូលរួមយ៉ាងសកម្មពីសហគមន៍ក្នុងគ្រប់កិច្ច ប្រឹងប្រែងអប់រំ ដោយរួមបញ្ចូលទាំងការសំរេចចិត្ត ដែលទាក់ទងទៅនឹងខ្លឹមសារមេរៀនផងដែរ ។ កម្មវិធីសិក្សាដែលប្រកាន់យក គួរមានភាពទាក់ទងទៅនឹងតំរូវការបច្ចុប្បន្ន និងក្នុងពេលអនាគតរបស់អ្នកសិក្សា ហើយនឹងមានភាពស៊ីគ្នាទៅនឹងពត៌មានដែលសហគមន៍ត្រូវការ ដោយអាស្រ័យទៅនឹងកាលៈទេសៈដែលបានផ្លាស់ប្តូរដោយវិបត្តិ ដូចជាបំណិនជីវិត ការអប់រំពីសន្តិភាព ការអប់រំពីពលរដ្ឋ ការឱ្យយល់ដឹងពីគ្រាប់មីន ពីសុខភាព អាហាររូបត្ថម្ភ HIV/AIDS សិទ្ធិមនុស្ស និងបរិស្ថានជាដើម ។ ការអប់រំបន្ថែមទៀតពីបំណិនជីវិត គួរត្រូវបានផ្តល់ឱ្យដល់កុមារ ដែលមិនបានចូលសាលា ឪពុកម្តាយគេ មនុស្សចាស់ និងក្រុមដែលបាត់បង់ផលប្រយោជន៍ ។

កម្មវិធីអប់រំក្នុងពេលមានគ្រាអាសន្ន គឺជាបែបបទមួយនៃអន្តរាគមន៍ចិត្តសាស្ត្រ ព្រោះកម្មវិធីទាំងនោះបង្កើតឡើងនូវបរិស្ថានអប់រំដ៏ជិតស្និទ្ធ ផ្តល់នូវកម្មវិធីអប់រំទៀងទាត់ ព្រមទាំងបណ្តុះនូវអារម្មណ៍នៃក្តីសង្ឃឹមនៅពេលអនាគតផងដែរ ។ បុគ្គលគ្រប់រូបដែលពាក់ព័ន្ធទៅនឹងការផ្តល់ការអប់រំ ជាពិសេសគ្រូបង្រៀន និងបុគ្គលិករដ្ឋបាលសាលារៀន

គួរទទួលបាននូវការពន្យល់ណែនាំពីតួនាទីរបស់គេក្នុងការកាត់បន្ថយនូវការប៉ះពាល់ចិត្តសាស្ត្រ និងសង្គមទៅលើអ្នកសិក្សា។

សេវាកម្មអប់រំគួរទទួលស្គាល់ថា មនុស្សយើងរៀនសូត្រតាមវិធី និងល្បឿនផ្សេងៗគ្នា ហើយពួកគេត្រូវតែចូលរួមយ៉ាងសកម្មទៅក្នុងដំណើរការសិក្សា។ ដើម្បីឱ្យមនុស្សយើងរៀនសូត្រយ៉ាងមានប្រសិទ្ធភាពនោះ វាជាប្រការសំខាន់ដែលត្រូវឱ្យមានវិធីសាស្ត្របង្រៀន និងរៀនសូត្រដែលមានលក្ខណៈចូលរួម ដោយរួមបញ្ចូលតាំងពីវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលផងដែរ។ វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលនេះ គួរឆ្លើយតបទៅនឹងតំរូវការបុគ្គលទាំងមូលជំនាញបង្រៀនដែលចាំបាច់ សំរាប់ការរស់រានមានជីវិត ការអភិវឌ្ឍន៍ជាបុគ្គល ការទាក់ទងក្នុងសង្គម និងការសិក្សាចំនេះដឹងផងដែរ។ ការសិក្សា របស់ពួកគេនឹងត្រូវបានពង្រឹងនៅពេលដែលគេអាចមើលឃើញពីបំណង តម្លៃ និងភាពទាក់ទងនៃអ្វីដែលគេសិក្សា ព្រមទាំងនៅពេលដែលគេបានទទួលនូវឱកាសមួយដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការសិក្សារបស់គេ។

ប្រសិនបើវិធីសាស្ត្របង្រៀនទាំងនោះពុំបានបណ្តុះបណ្តាលទេ វាជាប្រការសំខាន់ ដែលគេត្រូវទទួលការបណ្តុះបណ្តាលដ៏ សមរម្យមួយ គឺមិនត្រឹមតែក្នុងមុខវិជ្ជាជាមូលដ្ឋានតែប៉ុណ្ណោះទេតែក្នុងមុខវិជ្ជាដែលមានភាពទាក់ទងយ៉ាងពិសេសក្នុង ស្ថានការណ៍មានគ្រោះអាសន្នផងដែរ។ វាក៏ជាតំរូវការផងដែរក្នុងការឱ្យមានការបណ្តុះបណ្តាលបន្តទៀត ដើម្បីប្រឈមមុខទៅនឹងតំរូវការចិត្តសាស្ត្ររបស់ក្រុមមនុស្សដែលជាគោលដៅ។

សហគមន៍ចង់ដឹងថា តើរដ្ឋាភិបាលនឹងទទួលស្គាល់ការអប់រំរបស់កូនចៅគេដែរឬអត់? ហើយថាតើកូនគាត់នឹងអាចប្រើប្រាស់ការអប់រំនេះដើម្បីចូលរៀនក្នុងថ្នាក់ឧត្តមសិក្សា ឬរកការងារបានធ្វើដែរ ឬអត់? ការបារម្ភជាចំបងគឺថាតើរដ្ឋាភិបាល ស្ថាប័នអប់រំ និងនិយោជកទទួលស្គាល់កម្មវិធីសិក្សាព្រមទាំងសញ្ញាប័ត្រដែលទទួលបានដែរឬអត់។ ក្រៅពីធ្វើឱ្យមានភាពស្របច្បាប់ទៅលើលទ្ធផលតេស្តរបស់កូនសិស្ស សញ្ញាប័ត្របញ្ចប់ការសិក្សាទទួលស្គាល់ស្នាដៃរបស់កូនសិស្ស ជួយជំរុញទឹកចិត្តពួកគេឱ្យចូលរៀនក្នុងសាលា។ ក្នុងស្ថានការណ៍ភៀសខ្លួន ការបញ្ជាក់ការសិក្សាមានការពាក់ព័ន្ធទៅនឹងការចរចារ គ្រប់ជ្រុងជ្រោយជាមួយប្រទេសដែលគេកំពុងរស់នៅ និងប្រទេសដែលជាដើមកំណើតរបស់គេ។ គេចង់បានថា បើសិនជាក្នុងស្ថានការណ៍ភៀសខ្លួនយូរអង្វែង កម្មវិធីសិក្សាត្រូវតែសំរបទៅតាមវិធីអប់រំទាំងពីរប្រទេស ហើយតូវតែទទួលស្គាល់ដោយប្រទេសកំណើតនិងប្រទេសដែលកំពុងផ្តល់ការអប់រំនោះ។ ទង្វើនេះទាមទារឱ្យមានការសំរបសំរួលក្នុងតំបន់និងអន្តរភ្នាក់ងារជាពិសេសណាមួយ ដើម្បីធ្វើសុខដុមនីយកម្មដល់សកម្មភាពអប់រំ និងសំណុំរឿងជនភៀសខ្លួនក្នុងប្រទេសផ្សេងៗគ្នា។

## ទំនាក់ទំនងជាមួយនឹងស្តង់ដាទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់

ដំណើរការនៃការបង្កើត និងអនុវត្តកម្មវិធីអប់រំ គឺជាកត្តាសំខាន់មួយដើម្បីកំណត់នូវប្រសិទ្ធភាពនៃជំនួយផ្នែកអប់រំនោះ។ អត្ថបទក្នុងជំពូកនេះ គួរត្រូវបានប្រើប្រាស់ស្របជាមួយនឹងស្តង់ដារួម ដោយរួមបញ្ចូលនូវការចូលរួមចំណែករបស់សហគមន៏ ធនធានមូលដ្ឋាន ការប៉ាន់ស្មានដំបូង ការឆ្លើយតប ការពិនិត្យតាមដាន និងការវាយតម្លៃ។ ជាពិសេសគេគួរតែជំរុញឱ្យមានការចូលរួមជាអតិបរមាពីសំណាក់ក្រុមជនរងគ្រោះដោយមហន្តរាយ ដោយរាប់បញ្ចូលតាំងពីក្រុមជនងាយទទួលការរងគ្រោះទៀតផងដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ និង គុណភាពនៃការជួយ។

**ស្តង់ដាអប្បបរមា:** ស្តង់ដាទាំងនេះមានលក្ខណៈបែបគុណភាព ហើយបញ្ជាក់កំរិតអប្បបរមាដែលនឹងសំរេចក្នុងការផ្តល់ជំនួយអប់រំ។

**សូចនាករសំខាន់ៗ:** គឺជា "សញ្ញា" ដែលបង្ហាញថាតើស្តង់ដាត្រូវបានសំរេចឬទេ។ សូចនាករទាំងនេះ ផ្តល់នូវវិធីមួយសំរាប់វាស់ និងបង្ហាញផលប៉ះពាល់ឬលទ្ធផលនៃកម្មវិធីព្រមទាំងដំណើរការឬវិធីសាស្ត្រដែលប្រើ។ សូចនាករទាំងនេះ អាចមានលក្ខណៈបែបគុណភាព ឬបរិមាណ។

**កំណត់សំគាល់ណែនាំ:** រួមមានចំណុចជាក់លាក់ដើម្បីពិចារណានៅពេលអនុវត្តស្តង់ដា និងសូចនាករក្នុងស្ថានភាពផ្សេងៗគ្នា ការណែនាំអំពីការដោះស្រាយការលំបាកជាក់ស្តែង និងដំបូន្មានអំពីបញ្ហាអាទិភាព។ កំណត់សំគាល់ណែនាំអាចរួមបញ្ចូលផងដែរនូវបញ្ហាសំខាន់ៗដែលទាក់ទងនឹងស្តង់ដា និងសូចនាករ និងរៀបរាប់អំពីជំរើស ដែលពិបាកសំរេច ភាពចំរូងចំរាស់ ឬចន្លោះប្រហោងនៅក្នុងចំណេះដឹងបច្ចុប្បន្ន។ ឧបសម្ព័ន្ធ២ រួមមាន តារាងជ្រើសរើសឯកសារយោង ដែលបង្ហាញប្រភពពត៌មានអំពីបញ្ហាទូទៅ និង បញ្ហាបច្ចេកទេសជាក់លាក់ ដែលទាក់ទងនឹងផ្នែកនេះ។

# ការបង្រៀន និង ការសិក្សា

**ស្តង់ដាទី១**
**កម្មវិធីសិក្សា**

កម្មវិធីសិក្សា ដែលមានភាពទាក់ទងទៅនឹងវប្បធម៌ សង្គម និង ភាសា ត្រូវបានប្រើប្រាស់ដើម្បីផ្តល់នូវការអប់រំក្នុង និងក្រៅប្រព័ន្ធ ដែលមានលក្ខណៈសមស្របទៅនឹងស្ថានភាពគ្រោះអាសន្នជាក់លាក់ណាមួយ

**ស្តង់ដាទី២**
**ការបណ្តុះបណ្តាល**

គ្រូបង្រៀន និង បុគ្គលិកអប់រំផ្សេងទៀតទទួលបាននូវការបណ្តុះបណ្តាលតាមកំលុងពេលជាក់លាក់ មានភាពទាក់ទង និងមានការតាក់តែងត្រឹមត្រូវទៅតាមតំរូវការ និង កាលៈទេសៈ

**ស្តង់ដាទី៣**
**ការបង្រៀន**

ការបង្រៀន គឺមានលក្ខណៈសិស្សមជ្ឈមណ្ឌល មានលក្ខណៈចូលរួម និងមានលក្ខណៈបញ្ចូលគ្នា

**ស្តង់ដាទី៤**
**ការវាយតម្លៃ**

វិធីសាស្រ្តសមរម្យត្រូវបានប្រើដើម្បីវាយតម្លៃ និងផ្តល់តម្លៃដល់លទ្ធផលសិក្សា

## ឧបសម្ព័ន្ធ ទី២: ឯកសារយោង និង សេចក្តីណែនាំធនធាន

ផ្នែកការបង្រៀន និងការសិក្សា

## ស្តង់ដាទី១នៃការបង្រៀន និងការសិក្សា: កម្មវិធីសិក្សា
## កម្មវិធីសិក្សាដែលមានភាពទាក់ទងទៅនឹងវប្បធម៌ សង្គម និង ភាសា ត្រូវបានប្រើប្រាស់ដើម្បីផ្តល់នូវការអប់រំក្នុង និងក្រៅប្រព័ន្ធ ដែលមានលក្ខណៈសមស្របទៅនឹងស្ថានភាពគ្រោះអាសន្នជាក់លាក់ណាមួយ

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយនឹង កំណត់សំគាល់ណែនាំ)

- កម្មវិធីដែលមានស្រាប់ត្រូវបានពិនិត្យឡើងវិញ ដើម្បីឱ្យមានភាពសមស្របទៅនឹងអាយុ ឬកំរិតវឌ្ឍនាការ ភាសា វប្បធម៌ សមត្ថភាព និងតំរូវការរបស់អ្នកសិក្សា ដែលបានរងគ្រោះដោយគ្រោះអាសន្ន។ កម្មវិធីត្រូវបានប្រើប្រាស់ កែ សំរួល ឬធ្វើឱ្យកាន់តែល្អតាមការដែលចាំបាច់ (សូមអាន កំណត់សំគាល់ណែនាំទី ១-៣)។

- នៅពេលដែលទាមទារឱ្យមានការបង្កើត ឬកែសំរួលមកប្រើនូវកម្មវិធីសិក្សា ទង្វើទាំងនោះត្រូវបានធ្វើដោយមានការចូលរួមដ៏មានប្រសិទ្ធភាពពីសំណាក់ភាគីពាក់ព័ន្ធ ហើយគេត្រូវគិតពិចារណាទៅលើប្រយោជន៍ និងតំរូវការខ្ពស់បំផុតរបស់អ្នកសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី ១-៣)។

- កម្មវិធីសិក្សា លើកឡើងពីបំណិនជីវិត អក្ខរកម្ម លេខនព្វន្ធ ព្រមទាំងសមត្ថភាពសំខាន់ៗនៃការអប់រំជា មូលដ្ឋាន ដែលទាក់ទងទៅនឹងដំនាក់កាលនិមួយៗនៃគ្រាមានអាសន្ន (សូមអាន កំណត់សំគាល់ណែនាំទី ៤-៥)។

- កម្មវិធីសិក្សាលើកឡើងនូវតំរូវការសុខមាលភាពចិត្តសង្គមរបស់គ្រូបង្រៀន និងអ្នកសិក្សាដើម្បីឱ្យគេអាចប្រឈមមុខទៅនឹងការរស់នៅក្នុងកំឡុងពេល និងក្រោយពេលមានគ្រោះអាសន្ន (សូមអាន កំណត់សំគាល់ណែនាំទី ៦)។

- ខ្លឹមសារមេរៀន សម្ភារៈ និងការបង្រៀនត្រូវបានផ្តល់តាមរយៈភាសារបស់អ្នកសិក្សា និង គ្រូបង្រៀនជាពិសេសក្នុងឆ្នាំដំបូងៗនៃការសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី ៧)។

- កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនឆ្លើយតបទៅនឹងតំរូវការបច្ចុប្បន្នរបស់អ្នកសិក្សា និងបង្កើតឱកាសសិក្សានាពេលអនាគត (សូមអាន កំណត់សំគាល់ណែនាំទី ៨)។

- កម្មវិធីសិក្សា និងសម្ភារៈបង្រៀនមានភាពគិតគូពីយេនឌ័រ ទទួលស្គាល់ភាពដោយឡែកៗពីគ្នារបស់អ្នកសិក្សា និងលើកកំពស់ឱកាសសិក្សានាពេលអនាគត (សូមអាន កំណត់សំគាល់ណែនាំទី ៩)។

- សម្ភារៈបង្រៀន និង សិក្សាគ្រប់គ្រាន់ត្រូវបានផ្តល់តាមតំរូវការ ឱ្យទាន់ពេល ដើម្បីគាំទ្រដល់សកម្មភាពអប់រំ ដែលពាក់ព័ន្ធ។ គេគួរជ្រើសរើសយកសម្ភារៈដែលមានក្នុងមូលដ្ឋានដើម្បីធានានូវនិរន្តភាព ( សូមអាន កំណត់សំគាល់ណែនាំទី ១០) ។

## កំណត់សំគាល់ណែនាំ

**១.** **កម្មវិធីសិក្សា** អាចត្រូវបានកំណត់ថាជាផែនការសកម្មភាពមួយ ដើម្បីជួយឱ្យអ្នកសិក្សាពង្រីកមូលដ្ឋានចំណេះដឹង និងជំនាញរបស់គេ។ សំរាប់បំណងនៃស្តង់ដាអប្បបរមា "កម្មវិធីសិក្សា" ត្រូវបានប្រើជាឆ័ត្រមួយដែលគ្របដណ្តប់ តាំងពីកម្មវិធីអប់រំក្នុង និង ក្រៅប្រព័ន្ធ។ វារួមបញ្ចូលតាំងពីគោលបំនងនៃការសិក្សា ខ្លឹមសារមេរៀនវិធីសាស្ត្រ បង្រៀន និងវិធីសាស្ត្រ សម្ភារៈបង្រៀន និងវិធីសាស្ត្រវាយតម្លៃ។ កម្មវិធីអប់រំក្នុង និង ក្រៅប្រព័ន្ធគួរតែ អនុលោម ទៅតាមកម្មវិធីសិក្សា ដែលបង្កើតឡើងដោយយោងទៅតាមចំនេះដឹង និងបទពិសោធន៍របស់ អ្នកសិក្សា ហើយ ដែលមានភាពទាក់ទងទៅនឹងបរិស្ថានជិត១ខ្លួន។ សំរាប់ស្តង់ដាអប្បបរមា និយមន័យខាង ក្រោមនេះត្រូវបានប្រើៈ

- គោលបំណងការសិក្សា សំដៅទៅលើចំនេះដឹង ជំនាញ តម្លៃ និង ឥរិយាបថ ដែលនឹងត្រូវបង្កើតតាមរយៈ សកម្មភាពអប់រំ។
- ខ្លឹមសារមេរៀន គឺជាមេរៀនដែលត្រូវបានរៀន (ដូចជាចំនេះដឹង ជំនាញ តម្លៃ ឥរិយាបថ ជាដើម) ។
- វិធីសាស្ត្របង្រៀន សំដៅទៅលើវិធីសាស្ត្រដែលបានជ្រើសរើសសំរាប់ (ឬដែលប្រើប្រាស់ក្នុង) ការពន្យល់ បង្ហាញនូវខ្លឹមសារមេរៀន។
- វិធីសាស្ត្របង្រៀន គឺជាសមាសភាគមួយរបស់វិធីសាស្ត្របង្រៀន ហើយវាសំដៅទៅលើរបៀបអនុវត្ត វិធីសាស្ត្រទាំងមូល និង
- សម្ភារៈបង្រៀន សំដៅទៅលើសៀវភៅ ផ្ទាំងរូបភាព និង សម្ភារៈបង្រៀន និងសិក្សាផ្សេង១ទៀត។ កម្មវិធីសិក្សានៃការអប់រំក្នុងនិងក្រៅប្រព័ន្ធ គួរមានខ្លឹមសារមេរៀនមានគុណភាពដែលមានការគិតគូរ ពីយេនឌ័រ និងដែលសមស្របទៅនឹងកំរិតសិក្សា ហើយដែលប្រើប្រាស់ភាសាដែលគ្រូបង្រៀន និងអ្នកសិក្សា អាចយល់បាន។ វិធីសាស្ត្រចូលរួម គួរតែជាផ្នែកមួយនៃកម្មវិធីសិក្សាដើម្បីជំរុញឱ្យអ្នកសិក្សាប្រកាន់នូវ តួនាទីកាន់តែសកម្មក្នុងការសិក្សា (សូមអានឧបសម្ព័ន្ធទី១: ការប្រើប្រាស់ពាក្យ សំរាប់ការកំណត់និយមន័យ នៃ "ការអប់រំ ដែលមានគុណភាព" និង "ការអប់រំដែលមានភាពទាក់ទង") ។

**២. សមស្របតាមអាយុ និង កំរិតនៃការវិវឌ្ឍន៏:** កម្មវិធីសិក្សា គួរត្រូវបានត្រួតពិនិត្យ ដើម្បីធានាថាកម្មវិធីសិក្សានោះ មិនត្រឹមតែសមស្របតាមអាយុប៉ុណ្ណោះទេ តែថែមទាំងត្រឹមត្រូវតាមកំរិតវឌ្ឍនាការរបស់អ្នកសិក្សាទៀតផង។ អាយុ និង កំរិតវឌ្ឍនាការ អាចមានភាពខុសគ្នាច្រើននៅក្នុងកម្មវិធីអប់រំទាំងក្នុង និងក្រៅប្រព័ន្ធក្នុងពេលមាន គ្រោះអាសន្ន ដូចនេះវាទាមទារឱ្យមានការកែសំរួលនូវកម្មវិធីសិក្សានិងវិធីសាស្ត្រ។ ចំពោះពាក្យ "សម ស្របតាមអាយុ" នោះ គឺសំដៅទៅលើកំរិតនៃអាយុរបស់អ្នកសិក្សា ហើយពាក្យ "សមស្របតាមវឌ្ឍនាការ" នោះ គឺសំដៅទៅលើតំរូវការជាក់ស្តែង និង ការវិវត្តន៍ផ្នែកបញ្ញារបស់អ្នកសិក្សា។

**៣. ការបង្កើតកម្មវិធីសិក្សា** អាចជាដំណើរការវែងឆ្ងាយ និងមានការពិបាកក៏ប៉ុន្តែក្នុងពេលមានគ្រោះអាសន្ន កម្មវិធីសិក្សាច្រើនតែត្រូវបានកែសំរួលចេញពីកម្មវិធីសិក្សាក្នុងប្រទេសដែលផ្តល់ការអប់រំពីប្រទេសកំណើត ឬពីកន្លែងមានគ្រោះអាសន្នផ្សេងៗទៀត។ វាជាការសំខាន់ក្នុងការធានាឱ្យដឹងថាកម្មវិធីសិក្សាដែលបង្កើតសំរាប់ការអប់រំក្នុង និងក្រៅប្រព័ន្ធបានគិតគូរពីតំរូវការពិសេសៗរបស់អ្នកសិក្សាគ្រប់រូប ដោយរួមតាំងពីកុមារដែលមានការទាក់ទងទៅនឹងកងកំលាំងប្រដាប់អាវុធ (CAFF) កុមារី អ្នកសិក្សាលើសអាយុ អ្នកបោះបង់ចោលការសិក្សា និង អ្នកសិក្សាដែលជាមនុស្សពេញវ័យ។ វាក៏ជាប្រការសំខាន់ដូចគ្នាដែរ ដែលត្រូវធានាឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ភាគីពាក់ព័ន្ធទៅក្នុងការតាក់តែងកម្មវិធីសិក្សា ក៏ដូចជាការពិនិត្យឡើងវិញតាមកំឡុងពេល ទៅលើកម្មវិធីអប់រំ។ បុគ្គលច្រើនប្រភេទគួរត្រូវបានប្រឹក្សាយោបល់ដោយរួមតាំងពីអ្នកសិក្សា សមាជិកសហគមន៍ គ្រូបង្រៀន អ្នកសំរបសំរួល អាជ្ញាធរអប់រំ ព្រមទាំងអ្នកគ្រប់គ្រងកម្មវិធីជាដើម។ នៅពេលដែលកម្មវិធីអប់រំត្រូវបានបង្កើតឡើងក្នុងកំឡុងពេល ឬក្រោយពីពេលមានគ្រោះអាសន្ន គេត្រូវជ្រើសរើសប្រើប្រាស់(ឬកែសំរួល និងបន្ថែមបន្ថយប្រសិនបើចាំបាច់)នូវកម្មវិធីសិក្សាថ្នាក់បឋម និងថ្នាក់មធ្យមសិក្សាណាដែលត្រូវបានទទួលស្គាល់។ ចំពោះកម្មវិធីអប់រំក្នុងប្រព័ន្ធដែលត្រូវផ្តល់ឱ្យជនភៀសខ្លួន វាជាជំរើសប្រសើរក្នុងការអនុវត្តតាមកម្មវិធីសិក្សារបស់ប្រទេសកំណើត ដើម្បីសំរួលឱ្យមានត្រលប់ទៅប្រទេសនោះវិញតាមការស្ម័គ្រចិត្ត (ទោះជាទង្វើនេះពុំមែនសុទ្ធតែជាការដែលអាចធ្វើទៅបាន និងមានភាពសមរម្យក៏ដោយ)។ ទស្សនៈរបស់ជនភៀសខ្លួន និងរបស់ប្រទេសដែលផ្តល់ការអប់រំនោះគួរត្រូវបានគេគិតគូរពិចារណាយ៉ាងល្អិតល្អន់។

ជាការល្អ ក្នុងស្ថានភាពភៀសខ្លួនរយៈពេលវែងកម្មវិធីសិក្សាតំរូវឱ្យមានការទទួលស្គាល់ពីសំណាក់ប្រទេសកំណើត និងពីសំណាក់ប្រទេសដែលផ្តល់ការអប់រំ។ ទង្វើនេះទាមទារឱ្យមានការសំរបសំរួលថ្នាក់ តំបន់ និងពីអន្តរភ្នាក់ងារដើម្បីធ្វើសុខដុមនីយកម្មដល់សកម្មភាពអប់រំ និងលើសំនុំរឿងជនភៀសខ្លួន ក្នុងប្រទេសផ្សេងៗគ្នា។ បញ្ហាលំអិតដែលត្រូវធ្វើការសំរេចសំរាប់បញ្ជាក់ការសិក្សា រួមបញ្ចូលនូវសមត្ថភាពផ្នែកភាសាព្រមទាំងការទទួលស្គាល់លទ្ធផលការប្រលង។

៤. **វិធីសាស្ត្របង្រៀនសមរម្យ** គួរត្រូវបានបង្កើត និងប្រកាន់យកដើម្បីតំរូវទៅតាមបរិបទតំរូវការ អាយុ និងសមត្ថភាពរបស់អ្នកសិក្សា។ ការអនុវត្តវិធីសាស្ត្រថ្មីៗ ក្នុងដំណាក់កាលដំបូងនៃពេលមានគ្រោះអាសន្ន អាចមានភាពតានតឹងផ្លូវចិត្តដល់គ្រូដែលមានបទពិសោធន៏ ក៏ដូចជាអ្នកសិក្សា ឪពុកម្តាយ និងសមាជិកសហគមន៏ដែលអាចគិតថាការប្រើប្រាស់វិធីសាស្ត្រថ្មីៗនេះជាការផ្លាស់ប្តូរធំៗ និងឆាប់រហ័ស។ ការអប់រំក្នុងគ្រាមានអាសន្ន ឬក្នុងដំណាក់កាលដំបូងនៃការស្តាបនាឡើងវិញ គួរផ្តល់ឱ្យគ្រូបង្រៀនក្នុងកន្លែងអប់រំក្រៅប្រព័ន្ធមួយនូវឱកាសសំរាប់ផ្លាស់ប្តូរ ក៏ប៉ុន្តែ ការប្តូរទៅអនុវត្តវិធីសាស្ត្រមានការចូលរួម ឬដែលមានភាពស្និទ្ធស្នាលទៅនឹងអ្នកសិក្សានេះត្រូវតែធ្វើឡើងដោយយកចិត្តទុកដាក់ និងប្រកបដោយវិចារណញ្ញាណ។ សំរាប់ការធ្វើអន្តរាគមន៏ផ្នែកអប់រំក្រៅប្រព័ន្ធ វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលអាចត្រូវបានបញ្ចូលបានយ៉ាងរហ័សតាមរយៈការបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត អ្នកគូរគំនូរត្លុក និងអ្នកសំរបសំរួល។

៥. **សមត្ថភាពសំខាន់ៗ** គួរត្រូវបានកំណត់មុននឹងបង្កើត ឬកែសំរួលយកមកប្រើនូវខ្លឹមសារមេរៀន និងសម្ភារៈបង្រៀន។ ក្រៅអំពីអក្ខរកម្ម និង លេខនព្វន្ធធម្មតា "សមត្ថភាពសំខាន់ៗនៃការអប់រំជាមូលដ្ឋាន" សំដៅទៅលើចំណេះដឹង សំខាន់ៗ ជំនាញ ឥរិយាបថ ព្រមទាំងការអនុវត្តដែលជាតំរូវការរបស់អ្នកសិក្សា ដែលស្ថិតក្នុងចំណោមជនរងគ្រោះដោយគ្រោះអាសន្ន ដើម្បីឱ្យពួកគេចូលរួមយ៉ាងសកម្មនិងយ៉ាងមានអត្ថន័យក្នុងនាមជាសមាជិកសហគមន៏ ឬប្រទេសរបស់គេ។

៦. **តំរូវការចិត្តសាស្ត្រ និង វឌ្ឍនាការរបស់អ្នកសិក្សា** ក៏ដូចជារបស់បុគ្គលិកអប់រំដែរ ត្រូវតែទទួលបាននូវការ គិតគូរពិចារណា និងដោះស្រាយនៅគ្រប់ដំនាក់កាលនៃគ្រាមានអាសន្នដោយរួមបញ្ចូលតាំងពីពេលមានវិបត្តិ និងពេលងើបពីវិបត្តិផងដែរ។ បុគ្គលិកអប់រំទាំងអស់គ្នាទោះជាក្នុង ឬក្រៅប្រព័ន្ធក៏ដោយគួរទទួលបានការបណ្តុះបណ្តាលជំនាញក្នុងការកត់សំគាល់នូវសញ្ញាណនៃភាពតានតឹងផ្លូវចិត្តរបស់អ្នកសិក្សា និងអំពីជំហានដែលត្រូវដោះស្រាយ និង ឆ្លើយតបទៅនឹងអកប្បកិរិយានេះនៅក្នុងបរិស្ថានសិក្សា។ យន្តការបញ្ជូន គួរត្រូវបានដៅទុកយ៉ាងច្បាស់លាស់សំរាប់បុគ្គលិកអប់រំក្នុងការផ្តល់ការគាំទ្រដល់អ្នកសិក្សាណាដែលមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ។ វិធីសាស្ត្របង្រៀនដែលប្រើជាមួយក្រុមកុមារ និងយុវជនដែលមានភាពប៉ះទង្គិះផ្លូវចិត្តគួរបញ្ចូលនូវរចនាសម្ព័ន្ធ ដែលអាចស្មានជាមុនបាន នូវរយៈពេលសិក្សាខ្លីជាងដើម្បីឱ្យពួកគេអាចផ្តោតការយកចិត្តទុកដាក់ ព្រមទាំងបញ្ចូលនូវវិធីសាស្ត្រវិន័យវិជ្ជមាន ការចូលរួមរបស់សិស្សទាំងអស់ក្នុងគ្រប់សកម្មភាពសិក្សា ព្រមទាំងល្បែង ដែលមានការសហការគ្នាផងដែរ។

គេក៏ត្រូវគិតគូរពិចារណាផងដែរទៅលើតំរូវការចិត្តសាស្ត្ររបស់បុគ្គលិកអប់រំ ព្រោះពួកគេក៏មកពីក្នុងចំណោមក្រុមជនរងគ្រោះ ហើយពួកគេក៏ប្រឈមមុខទៅនឹងភាពតានតឹងផ្លូវចិត្តនិងការទង្គិះផ្លូវចិត្តដូចអ្នកសិក្សាផងដែរ។ ការបណ្តុះបណ្តាល ការពិនិត្យតាមដាន និងការជួយជាបន្តបន្ទាប់ គួរគិតគូរពិចារណាយ៉ាងច្បាស់លាស់

អំពីកត្តាទាំងនេះផងដែរ (សូមអានការទទួលយក និង បរិស្ថានសិក្សា, ស្តង់ដាទី១ នៅទំព័រទី៥៦ ដែលស្តីពីតារាងពិនិត្យចិត្តសាស្ត្រ។ ហើយសូមអានការទទួលយក និងបរិស្ថានសិក្សា, ស្តង់ដាទី២ នៅទំព័រទី៦0 និងគ្រូបង្រៀន និង បុគ្គលិកអប់រំដទៃទៀត ស្តង់ដាទី៣ នៅទំព័រទី៩៧)។

៧. ***ភាសា:*** វាជាការធម្មតា ដែលប្រទេសទទួលឱ្យស្នាក់នៅ ត្រូវជួយឱ្យកម្មវិធីអប់រំជនភៀសខ្លួនអនុលោមទៅតាមស្តង់ដារបស់គេ ដោយរួមបញ្ចូលតាំងពីការប្រើប្រាស់ភាសា និងកម្មវិធីសិក្សាផងដែរ។ ក៏ប៉ុន្តែវាជាការសំខាន់ក្នុងការគិតគូរពីអនាគតរបស់អ្នកសិក្សា ជាពិសេសចំពោះអ្នកដែលប្រាថ្នាចង់បន្តការសិក្សានៅក្រោយពេលមានគ្រោះអាសន្ន។ ភាគីជំនួយមនុស្សធម៌ គួរជំរុញឱ្យបានខ្លាំងក្លាដើម្បីឱ្យរដ្ឋាភិបាលម្ចាស់ផ្ទះអនុញ្ញាតឱ្យជនភៀសខ្លួនរៀនសូត្រជាភាសាកំនើតរបស់គេ។ ប្រសិនបើប្រការនេះត្រូវបានអនុញ្ញាត ខ្លឹមសារមេរៀនសំខាន់ៗ សៀវភៅណែនាំគ្រូបង្រៀន សៀវភៅពុម្ពសិស្ស ព្រមទាំងសម្ភារៈសំណេរ និងឧបទេសជំនួយក្នុងការមើល និងការស្តាប់ផ្សេងៗ ដែលមិនមែនសរសេរជាភាសាកំនើតរបស់អ្នកសិក្សាទេនោះ គួរតែទទួលការបកប្រែជាភាសាកំនើតរបស់អ្នកសិក្សា។ ប្រសិនបើប្រការនេះមិនត្រូវបានអនុញ្ញាតទេនោះ គេគួរបង្កើតឱ្យមានថ្នាក់រៀន និងសកម្មភាពបន្ថែមជាភាសាកំនើតរបស់អ្នកសិក្សា។

៨. **ខ្លឹមសារមេរៀន និង គោលគំនិតសំខាន់ៗ:** នៅពេលកំណត់ខ្លឹមសារមេរៀន គេគួរពិចារណាទៅលើចំនេះដឹងជំនាញ និងភាសា ដែលមានប្រយោជន៍ដល់អ្នកសិក្សាក្នុងដំនាក់កាលនិមួយៗនៃគ្រោះអាសន្ន ហើយដែលជួយពង្រឹងសមត្ថភាពអ្នកសិក្សាក្នុងការរស់នៅដោយឯករាជ្យ និងមានប្រយោជន៍ក្នុងកំឡុងពេល និងក្រោយមានគ្រោះអាសន្ន ហើយដើម្បីឱ្យគេមានលទ្ធភាពទទួលបាននូវឱកាសសិក្សាបន្តបន្ទាប់ទៀត។

ខ្លឹមសារមេរៀន សមស្របនឹងគោលគំនិតសំខាន់ៗគួររៀបចំឡើងតាមចំណុចដូចតទៅ:

- ការអប់រំសុខភាពផ្អែកលើជំនាញ (ដែលសមស្របទៅនឹងអាយុ និង ស្ថានការណ៍): ការសង្គ្រោះភ្លាមៗ (first aid) សុខភាពបន្តពូជ ការចំលងមេរោគផ្លូវភេទ, HIV/AIDS
- សិទ្ធិមនុស្ស និង ស្តង់ដាមនុស្សធម៌ ភាពជាពលរដ្ឋសកម្ម ការអប់រំ ការស្ថាបនាសន្តិភាព ភាពអហឹង្សា ការ បង្ការគ្រប់គ្រង ដោះស្រាយជម្លោះ ការការពារកុមារ សន្តិសុខ និងសុវត្ថិភាព
- សកម្មភាពវប្បធម៌ដូចជា ភ្លេង របាំ ល្ខោន កីឡា និង ល្បែង
- ពតិមាន ដែលចាំបាច់ក្នុងការរស់រានក្នុងបរិស្ថានថ្មី: ការយល់ដឹងពីគ្រាប់មីន និងគ្រឿងមិនទាន់ផ្ទុះ ការជន្លៀសភ្លាមៗ និង ការទទួលបាននូវសេវាកម្ម
- ភាពវឌ្ឍនាការនៃកុមារ និង ក្មេងជំទង់ និង
- ជំនាញចិញ្ចឹមជីវិត និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ

៩. **ភាពខុសគ្នា គួរត្រូវបានគិតគូរពិចារណាក្នុងការតាក់តែង** និងអនុវត្តសកម្មភាពអប់រំក្នុងគ្រប់ដំណាក់កាលនៃពេលមានគ្រោះអាសន្ន ជាពិសេស គឺការបញ្ចូលនូវអ្នកសិក្សាផ្សេងៗគ្នា ការបញ្ចូលនូវគ្រូបង្រៀន ឬអ្នកសំរបសំរួលដែលមកពីប្រភពខុសៗគ្នា និងការជំរុញបង្កើតនូវភាពអត់ធ្មត់ និងការគោរពរវាងគ្នា និង គ្នា ។ ចំណុចដែលគួរពិចារណា ក្នុងការជំរុញឱ្យមានភាពខុសគ្នា អាចរួមមាន យេនឌ័រ វប្បធម៌ សញ្ជាតិ ជនជាតិ សាសនា សមត្ថភាពរៀន សូត្រ អ្នកសិក្សាដែលមានតំរូវការអប់រំពិសេស ព្រមទាំងការបង្រៀនសិស្សដែលមានកំរិតនិងអាយុច្រើនខុសៗគ្នា ។

១០. **សម្ភារៈសិក្សាដែលមានក្នុងមូលដ្ឋានសំរាប់អ្នកសិក្សា** គួរត្រូវបានប៉ាន់ស្មានទុក នៅពេលមានកើតគ្រោះអាសន្នភ្លាមៗ ។ សំរាប់ជនភៀសខ្លួន វារួមមានសម្ភារៈដែលយកមកពីប្រទេស ឬកន្លែងកំនើត ។ សម្ភារៈគួរត្រូវបានកែសំរួល បង្កើត ឬបញ្ជាទិញ ហើយត្រូវឱ្យមានក្នុងបរិមាណគ្រប់គ្រាន់ ។ គេទាមទារឱ្យមានការពិនិត្យតាមដានការស្តុកទុក ការចែកចាយ និងការប្រើប្រាស់សម្ភារៈទាំងអស់នេះ ។ អ្នកសិក្សាគួរតែមានលទ្ធភាពប្រើប្រាស់នូវខ្លឹមសារមេរៀន ហើយសម្ភារៈបង្រៀនគួរតែឆ្លុះបញ្ចាំង និងមានភាពគោរពដល់វប្បធម៌របស់អ្នកសិក្សា ។

## ស្តង់ដាទី២នៃការបង្រៀន និងការសិក្សា: ការបណ្តុះបណ្តាល

**គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត ទទួលបាននូវការបណ្តុះបណ្តាលតាមកំឡុងពេលជាក់ លាក់ មានភាពទាក់ទង និងមានការតាក់តែងត្រឹមត្រូវទៅតាមតំរូវការ និង កាលៈទេសៈ**

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយនឹង កំណត់សំគាល់ណែនាំ)

- ការបណ្តុះបណ្តាលមានភាពទាក់ទងទៅនឹងតំរូវការជាអាទិភាព គោលបំនងនៃសកម្មភាពអប់រំ ព្រមទាំងខ្លឹមសារមេរៀន (សូមអាន កំណត់សំគាល់ណែនាំទី ១-២) ។
- តាមទីកន្លែងសមរម្យ ការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ និងឯកភាពដោយអជ្ញាធរអប់រំពាក់ព័ន្ធ (សូមអាន កំណត់សំគាល់ណែនាំទី៣-៤) ។

- គ្រូជំនាញជាអ្នកអនុវត្តកម្មវិធីបណ្តុះបណ្តាល ហើយត្រូវធ្វើក្នុងលក្ខណៈជាការជួយគាំទ្រ និងដឹកនាំជាបន្តបន្ទាប់ ការតាមដានបន្ត និង ការត្រួតពិនិត្យតាមកន្លែងធ្វើការ ព្រមទាំងការបណ្តុះបណ្តាលសារឡើងវិញ (សូមអាន កំណត់សំគាល់ណែនាំទី ៤) ។

- ការបណ្តុះបណ្តាលដែលរួមបញ្ចូលនូវការតាមដានបន្តផងដែរ ជំរុញលើកទឹកចិត្តគ្រូបង្រៀនឱ្យក្លាយជាអ្នកសំរបសំរួលក្នុងបរិស្ថានសិក្សា បង្កើតឱ្យមានវិធីសាស្ត្រចូលរួមក្នុងការបង្រៀន និងបកស្រាយបង្ហាញពីវិធីប្រើប្រាស់សម្ភារៈបង្រៀន ។

- ខ្លឹមសារមេរៀនត្រូវបានវាយតម្លៃជាប្រចាំ ដើម្បីកំណត់ថាតើវាឆ្លើយតបទៅនឹងតំរូវការគ្រូបង្រៀន សិស្ស និង សហគមន៍ដែរ ឬអត់ ហើយប្រសិនបើចាំបាច់ ខ្លឹមសារមេរៀននោះក៏ត្រូវធ្វើការកែសំរួលជាប្រចាំដែរ ។

- ការបណ្តុះបណ្តាលផ្តល់ឱ្យគ្រូបង្រៀននូវចំនាញសមរម្យដើម្បីឱ្យពួកគាត់មានលទ្ធភាពប្រកាន់តួនាទីជាអ្នកដឹកនាំ ប្រសិនបើវាជាតំរូវការរបស់សមាជិកសហគមន៍ ។

**កំណត់សំគាល់ណែនាំ**

១. **គ្រូបង្រៀន** សំដៅទៅលើគ្រូក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ និងអ្នកសំរបសំរួលក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ (សូមអាន ចំណុចគ្រូបង្រៀន និង បុគ្គលិកអប់រំដ៏ទៃទៀត ស្តង់ដាទី ១-៣ នៅទំព័រទី៩៣-៩៧ ដើម្បីយល់ដឹងពីពត៌មានស្តីពីការទទួលបុគ្គលិកឱ្យចូលធ្វើការ និងការជ្រើសរើសលក្ខ័ណ្ឌការងារ ព្រមទាំងការគាំទ្រនិងត្រួតពិនិត្យ) ។

២. **ការបង្កើតកម្មវិធី និង ខ្លឹមសារបណ្តុះបណ្តាល** គួរតែផ្អែកទៅលើតំរូវការជាក់លាក់ណាមួយរបស់បុគ្គលិកអប់រំ ក្នុងបរិបទនៃស្ថានការណ៍ និងដោយគិតពីភាពកំណត់នៃថវិកានិងពេលវេលា ។ កម្មវិធីបណ្តុះបណ្តាល គួរលើកឡើងពីបញ្ហាប្រឈមមុខនៃការអប់រំដោយវាយតម្លៃជាមូលដ្ឋាន ក្នុងកំឡុងពេលមានគ្រាអាសន្ន ហើយប្រសិនបើចាំបាច់វាគួរបញ្ចូលនូវបំណិនជីវិត និង ការអប់រំសន្តិភាពក្នុងការបណ្តុះបណ្តាលនោះ ។ កម្មវិធីបណ្តុះបណ្តាលអាចរួមមាន (ប៉ុន្តែមិនកំណត់តែ) ចំនេះដឹងមុខវិជ្ជាស្នូល វិធីសាស្ត្រគរុកោសល្យ និង បង្រៀន ការវិវត្តន៏របស់កុមារ ការបង្រៀនមនុស្សពេញវ័យ ការគោរពភាពផ្សេងៗគ្នា ការបង្រៀនអ្នកសិក្សាដែលមានតំរូវការពិសេសតំរូវការចិត្តសាស្ត្រ និងវិន្ឋនាការ ការបង្ការ, គ្រប់គ្រង, ដោះស្រាយជម្លោះ និង ការអប់រំសន្តិភាព សិទ្ធិមនុស្ស និងសិទ្ធិកុមារ ក្រមសីលធម៌ ជំនាញប្រចាំជីវិតរបស់គ្រូបង្រៀន (ដោយរួមទាំង HIV/AIDS) ភាព ទាក់ទងរវាងសាលារៀន និងសហគមន៍ ការប្រើប្រាស់ធនធានសហគមន៍ ព្រមទាំងការកំណត់ និងដោះស្រាយតំរូវ ការរបស់ក្រុមមនុស្សដែលឈប់សំចតរយៈពេលខ្លី និងអ្នកដែលធ្វើមាតុភូមិនិវត្តន៍ ដូចជាក្រុមមនុស្សដែលរើទីកន្លែងឬជនភៀសខ្លួនក្នុងស្រុកជាដើម ។

៣. **ការគាំទ្រ និងការសំរបសំរួលការបណ្តុះបណ្តាលៈ** នៅពេលដែលគ្រោះអាសន្នមានស្ថិរភាពឡើងវិញ ហើយអជ្ញាធរអប់រំជាតិនិងមូលដ្ឋាន ព្រមទាំងគណកម្មការអប់រំសហគមន៍ផងដែរគួរមានការចូលរួមក្នុងការតាក់តែង និងអនុវត្តសកម្មភាពបណ្តុះបណ្តាលគ្រូក្នុងនិងក្រៅប្រព័ន្ធនៅទីកន្លែងណាដែលអាចធ្វើទៅបាន។ វាជាជំហ៊ានមួយដែលត្រូវចាប់ផ្តើមពិភាក្សាគ្នាពីកម្មវិធីបណ្តុះបណ្តាលគ្រូដែលកំពុងបង្រៀនព្រមទាំងយន្តការ ទទួលស្គាល់ការបណ្តុះបណ្តាលដែលទទួលបានមុននឹងមានការឆ្លើយតបទៅនឹងគ្រោះអាសន្ន។ ក៏ប៉ុន្តែក្នុងស្ថានការណ៍ភៀសខ្លួនជាច្រើន វាពុំសូវមានទំនាក់ទំនងគ្នារវាងសហគមន៍ជនភៀសខ្លួនព្រមទាំងកម្មវិធីអប់រំរបស់គេ ជាមួយនឹងប្រព័ន្ធអប់រំមូលដ្ឋាននោះ។

នៅទីកន្លែងដែលអាចធ្វើទៅបានគ្រូបណ្តុះបណ្តាលក្នុងមូលដ្ឋានគួរត្រូវបានកំណត់ ដើម្បីឱ្យគាត់បង្កើត និងអនុវត្តការបណ្តុះបណ្តាលសមស្របសំរាប់គ្រូបង្រៀន ហើយគ្រូបណ្តុះបណ្តាលទាំងនោះទាមទារឱ្យមានសមត្ថភាពសំរបសំរួល និងជំនាញក្នុងការបណ្តុះបណ្តាលផងដែរ។ នៅទីណាដែលពុំមានគ្រូបណ្តុះបណ្តាលគ្រប់គ្រាន់ ឬពួកគាត់ ក៏ពុំទាន់បានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ទេនោះ ភ្នាក់ងារខាងក្រៅ (អង្គការសហប្រជាជាតិ NGO អន្តរ ជាតិ) និងស្ថាប័នមូលដ្ឋានជាតិ និងតំបន់គួរធ្វើការសំរបសំរួលជាមួយគ្នាជួយពង្រឹងដល់រចនាសម្ព័ន្ធ និងស្ថាប័នមានស្រាប់ ឬស្ថាប័នបណ្តោះអាសន្នណា ដែលកំពុងផ្តល់ការបណ្តុះបណ្តាលដល់គ្រូដែលកំពុងបង្រៀន ឬគ្រូដែលនឹងត្រូវបង្រៀននាពេលអនាគត។

៤. **ការទទួលស្គាល់ និង ការឱ្យតម្លៃៈ** ការឯកភាព និងការឱ្យតម្លៃពីសំណាក់អជ្ញាធរអប់រំមូលដ្ឋាន និងជាតិ ត្រូវបានស្វែងរក ដើម្បីមួយចំនែកធានាឱ្យមានគុណភាព និងការទទួលស្គាល់ក្នុងស្ថានភាពបច្ចុប្បន្ន និងមួយ ផ្នែកទៀតដើម្បីសំលឹងមើលទៅស្ថានការណ៍ ក្រោយពេលមានគ្រោះអាសន្ន។ ក្នុងករណីគ្រូបង្រៀនដែលជាជន ភៀសខ្លួនអជ្ញាធរអប់រំរបស់ប្រទេស ដែលជាម្ចាស់ផ្ទះ ឬប្រទេសកំនើត (យ៉ាងហោចណាស់ក៏បានមួយដែរក្នុងចំនោមប្រទេសទាំងពីរ) គួរតែទទួលស្គាល់ការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានរៀបចំ និងរក្សាឯកសារទុកយ៉ាង ល្អ ហើយដែលឆ្លើយតបទៅនឹងតំរូវការសមត្ថភាពគ្រូបង្រៀនរបស់អជ្ញាធរអប់រំ ក៏ដូចជាការរួមបញ្ចូលនូវសមាសភាគបន្ថែមដែលពាក់ពន្ធ័ទៅនឹងគ្រោះអាសន្ន។

# ស្តង់ដារទី៣នៃការបង្រៀន និងការសិក្សា: ការបង្រៀន

## ការបង្រៀន មានលក្ខណៈសិស្សមជ្ឈមណ្ឌល មានលក្ខណៈចូលរួម និងមានលក្ខណៈបញ្ចូលគ្នា

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់)

- អ្នកសិក្សា ត្រូវបានផ្តល់នូវឱកាសចូលរួមយ៉ាងសកម្មក្នុងការសិក្សារបស់ពួកគេ(សូមអាន កំណត់សំគាល់ណែនាំទី១)
- វិធីសាស្ត្រដែលមានលក្ខណៈចូលរួម ត្រូវបានប្រើដើម្បីសំរួលដល់ការចូលរួមរបស់អ្នកសិក្សាក្នុងការរៀនសូត្ររបស់គេ និងដើម្បីធ្វើឲ្យប្រសើរដល់បរិស្ថានសិក្សា។
- តាមរយៈលំហាត់អនុវត្ត និងទំនាក់ទំនងគ្នារវាងអ្នកសិក្សា គ្រូបង្រៀនបកស្រាយបង្ហាញពីការយល់ដឹងនូវខ្លឹមសារមេរៀន និងអំពីជំនាញបង្រៀន ដែលបានទទួលពីវគ្គបណ្តុះបណ្តាល។
- ការបង្រៀនឆ្លើយតបទៅនឹងតំរូវការរបស់អ្នកសិក្សាគ្រប់រូប(ដោយរួមបញ្ចូលទាំងពីអ្នកសិក្សា ដែលមានតំរូវការពិសេសផងដែរ) តាមរយៈការជំរុញបង្កើតភាពដែលអាចបញ្ចូលគ្នានិងការកាត់បន្ថយឧបសគ្គ ក្នុងការសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី២)
- ឪពុកម្តាយ និងអ្នកដឹកនាំសហគមន៍យល់ពី និងទទួលយកខ្លឹមសារមេរៀន និងវិធីសាស្ត្របង្រៀនដែលបានប្រើ (សូមអាន កំណត់សំគាល់ណែនាំទី៣)។

### កំណត់សំគាល់ណែនាំ

១. **ការចូលរួមយ៉ាងសកម្ម:** ការបង្រៀនគួរមានលក្ខណៈប្រាស្រ័យទាក់ទង និងមានការចូលរួមពីអ្នកសិក្សា។ ក្នុងចំណោមវិធីសាស្ត្រផ្សេងៗទៀតការបង្រៀនអាចធ្វើតាមរយៈ: ការងារជាក្រុម ការងារគំរោង (project work) មិត្តអប់រំមិត្ត ការសំដែងតួ ការនិទានរឿង ល្បែង វីដេអូ និងរឿងផ្សេងៗជាដើម។ ការសិក្សាដ៏សកម្មជួយបង្កើតទំនាក់ទំនងជិតស្និទ្ធរវាងគ្រូ និងអ្នកសិក្សា ហើយក៏ជួយផងដែរក្នុងការធានាឱ្យមានសុខមាលភាពចិត្តសាស្ត្រវិជ្ជមាន (សូមអានចំណុចការទទួលយក និងបរិស្ថានសិក្សា ស្តង់ដារទី ២, កំណត់សំគាល់ណែនាំទី ៦ នៅទំព័រទី៦២)។

២. **ឧបសគ្គនៃការសិក្សា:** គ្រូបង្រៀន គួរទទួលការបណ្តុះបណ្តាលឱ្យចេះនិយាយជាមួយឪពុកម្តាយ សមាជិកសហគមន៍ អ្នកដឹកនាំអប់រំ និងភាគីពាក់ព័ន្ធដទៃទៀតពីសារៈសំខាន់នៃសកម្មភាពអប់រំក្នុង និងក្រៅប្រព័ន្ធ ក្នុងទីកន្លែងដែលមានគ្រោះអាសន្នក៏ដូចជាពិភាក្សាពីភាពផ្សេងៗពីគ្នា ពីការបញ្ចូលក្នុងការសិក្សា និងពីការបង្រៀនដល់ទីកន្លែងទៀតផង។ ការសន្ទនាជាមួយអ្នកដឹកនាំ ការអប់រំឪពុកម្តាយ និងសមាជិកសហគមន៍ គឺជាតំរូវការមួយក្នុងការបញ្ចូលក៏ដូចជាការផ្តល់នូវសម្ភារៈធនធានសមស្របដល់ការសិក្សា។

៣. ជំរើស និងការប្រើប្រាស់វិធីសាស្រ្តបង្រៀននឹងទាមទារឱ្យមានការគិតគូរពិចារណាទៅលើការអប់រំ បទពិសោធន៍ការបណ្តុះបណ្តាល និងតំរូវការរបស់គ្រូបង្រៀន។ គ្រូបង្រៀន ក៏គួរតែមានការយល់ដឹងអំពីខ្លឹមសារ ដែលមានការផ្លាស់ប្តូរក៏ដូចជាពីការផ្លាស់ប្តូរនានាដែលរំពឹងទុកថានឹងកើតមានក្នុងការយល់ដឹង និងអកប្បកិរិយារបស់គ្រូបង្រៀន។ ការចូលរួម និងការទទួលយករបស់ឪពុកម្តាយ អ្នកដឹកនាំសហគមន៍ ប្រពៃណី និងសាសនាមានសារសំខាន់ក្នុងការកែទំរង់សកម្មភាព និងវិធីសាស្រ្តបង្រៀនដើម្បីឱ្យឆ្លើយតបទៅនឹងកង្វល់របស់សហគមន៍។

# ស្តង់ដារទី៤នៃការបង្រៀន និងការសិក្សា៖ ការវាយតម្លៃ

## វិធីសាស្ត្រសមរម្យត្រូវបានប្រើ ដើម្បីវាយតម្លៃ និងផ្តល់តម្លៃដល់លទ្ធផលសិក្សា

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយកំណត់សំគាល់ណែនាំ)

- មានវិធីសាស្ត្រវាយតម្លៃបន្តបន្ទាប់ខុសៗគ្នា ដើម្បីវាយតម្លៃលើការសិក្សាតាមកំឡុងពេលច្បាស់លាស់ និងមានភាពសមស្រប ។ មានទំរង់ការប្រើប្រាស់ពតិមានទនេះដើម្បីកែលំអគុណភាពបង្រៀន (សូមអានកំណត់សំគាល់ណែនាំទី១)
- លទ្ធផលអ្នកសិក្សាត្រូវបានទទួលស្គាល់ ហើយពិន្ទុ ឬឯកសារបញ្ចប់វគ្គសិក្សាត្រូវបានផ្តល់ឱ្យតាមហ្នឹងដែរ(សូមអាន កំណត់សំគាល់ណែនាំទី២)
- វិធីសាស្ត្រវាយតម្លៃត្រូវបានពិចារណាថាមានភាពយុត្តិធមិគួរឱ្យទុកចិត្តបាន និងពុំមានលក្ខណៈបំភ័យដល់អ្នកសិក្សា (សូមអាន កំណត់សំគាល់ណែនាំទី៣)

## កំណត់សំគាល់ណែនាំ

១. **វិធីសាស្ត្រ និងវិធានការវាយតម្លៃដ៏មានប្រសិទ្ធភាព** គួររៀបចំឡើងហើយឆ្លុះបញ្ចាំងនូវ៖

- ភាពទាក់ទង (ឧទាហរណ៍ តេស្ត និងការប្រលងមានភាពទាក់តង និងសមស្របទៅនឹងបរិបទសិក្សា)
- ភាពស៊ីគ្នា/សមស្របគ្នា (ឧទាហរណ៍ វិធីសាស្ត្រវាយតម្លៃត្រូវបានដឹងហើយអាចត្រូវបានអនុវត្តក្នុងវិធីស្រដៀងគ្នាក្នុង គ្រប់ទីកន្លែង ឬដោយគ្រប់គ្រូបង្រៀន)
- ការផ្តល់ឱកាស (អ្នកសិក្សាអវត្តមានត្រូវបានផ្តល់ឱកាសវាយតម្លៃមួយទៀត)
- ការកំណត់ពេល (ការវាយតម្លៃធ្វើឡើងកំឡុងពេល និងនៅពេលបញ្ចប់ការសិក្សា)
- ចំនួនដង (ដែលអាចទទួលឥទ្ធិពលពីគ្រោះអាសន្ន)
- ទីកន្លែងសមរម្យ (មានទីកន្លែង និងបរិក្ខាសមរម្យ ក្នុងពេលធ្វើការវាយតម្លៃជាផ្លូវការ និងដែលធ្វើឡើងដោយបុគ្គលិកអប់រំសមស្រប) និង
- ភាគីពាក់ព័ន្ធ និងតម្លាភាព (លទ្ធផលវាយតម្លៃត្រូវបានចែករំលែកជាមួយអ្នកសិក្សា និងឪពុកម្តាយគេ) ។

២. **លទ្ធផលវាយតម្លៃ:** ក្នុងករណីកម្មវិធីអប់រំក្នុងប្រព័ន្ធ ការវាយតម្លៃគួរត្រូវបានធ្វើឡើងក្នុងវិធីមួយដែលលទ្ធផលអ្នកសិក្សា និងលទ្ធផលនៃការប្រលងអាចត្រូវបានទទួលស្គាល់ដោយអជ្ញាធរអប់រំក្នុងប្រទេសម្ចាស់ផ្ទះ និង/ឬប្រទេសកំនើត។ ក្នុងករណីជនភៀសខ្លួន គេគួរប្រឹងប្រែងឱ្យមានការទទួលស្គាល់ពីអជ្ញាធរអប់រំក្នុងប្រទេស ឬទីកន្លែងកំនើត។ ឯកសារបញ្ចប់វគ្គសិក្សាអាចរួមបញ្ចូលនូវ (ប៉ុន្តែមិនកំណត់តែ) សាលាកប័ត្រ ឬសញ្ញាប័ត្របញ្ចប់ការសិក្សាជាដើម។

៣. **ក្រមសីលធម៌នៃការវាយតម្លៃ:** ការវាយតម្លៃគួរត្រូវបានបង្កើត និងអនុវត្តទៅតាម ក្រមសីលធម៌។ ការវាយតម្លៃគួរត្រូវបានគិតពិចារណាថាមានភាពយុត្តិធម៌ គួរឱ្យទុកចិត្ត ហើយគួរធ្វើឡើងតាមវិធីមួយដែលមិនបង្កើតបន្ថែមនូវការភ័យខ្លាច និងការប៉ះពាល់ផ្លូវចិត្ត។ គេគួរយកចិត្តទុកដាក់ថាវាគ្មានការបៀតបៀនផ្លូវភេទ ទៅលើអ្នកសិក្សាដើម្បីជាថ្នូរទៅនឹងពិន្ទុល្អ ឬការឡើងថ្នាក់ក្នុងសាលារៀន ឬកម្មវិធីណាមួយ។

# ៤. គ្រូបង្រៀន និង បុគ្គលិកអប់រំដទៃទៀត

**សេចក្តីផ្តើម**

**គ្រប់រូបភាពនៃជំនួយមនុស្សធម៌ គឺពឹងផ្អែកទៅលើជំនាញ ចំណេះដឹង និងការប្តេជ្ញាចិត្តរបស់បុគ្គលិក និងអ្នកស្ម័គ្រចិត្ត ដែលធ្វើការក្នុងស្ថានភាពលំបាក ឬពេលខ្លះពុំមានសន្តិសុខល្អ ។ ការទាមទារពីពួកគេ អាចធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ហើយដើម្បីសំរេចនូវស្តង់ដាអប្បបរមា វាជាការសំខាន់ដែលគេត្រូវទទួលបានការបណ្តុះបណ្តាល គ្រប់គ្រង និង ពិនិត្យតាមដានគ្រប់គ្រាន់ ។ ហើយពួកគេ ក៏គួរទទួលបាននូវសម្ភារៈចាំបាច់ ការគាំទ្រ និងការត្រួតពិនិត្យ យ៉ាង សមស្រប ។**

ក្នុងទីកន្លែងមានគ្រាអាសន្ន ការជ្រើសរើសគ្រូបង្រៀន និងបុគ្គលិកអប់រំត្រូវតែមានលក្ខណៈចូលរួម និងមានតម្លាភាព ហើយត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យដែលបានរៀបចំឡើង ។ គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀតគួរត្រូវបានជ្រើសរើសយកពីក្នុងចំណោមក្រុមមនុស្សដែលទទួលការរងគ្រោះ ។ ទង្វើនេះ ធ្វើឱ្យមានការច្របាច់បញ្ចូលក្នុងកម្មវិធីអប់រំនូវប្រពៃណី វប្បធម៌ ទំនៀមទំលាប់ និងបទពិសោធន៍ ដែលគោរពដល់ការអនុវត្តល្អៗ ប្រព័ន្ធជំនឿ និងតំរូវការរបស់ក្រុមមនុស្សដែលទទួលការរងគ្រោះ ។

នៅពេលទទួលឱ្យធ្វើការហើយ គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត គួរធ្វើការរួមគ្នាជាមួយសហគមន៍ ដើម្បីបង្កើតក្រមសីលធម៌ ព្រមទាំងធ្វើការកំណត់លក្ខខ័ណ្ឌការងារផងដែរ ។ គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត ត្រូវតែទទួលឱ្យធ្វើការដោយមានការរៀបចំកិច្ចសន្យាច្បាស់លាស់ ហើយដែលកិច្ចសន្យានោះចែងឡើងពីស្ថានភាពមុខងាររបស់គេ ( ប្រាក់ខែ ឬប្រាក់លើកទឹកចិត្ត ចំនួនថ្ងៃ និងម៉ោងធ្វើការ ស្ថានភាការងារ... ។ល ។) ព្រមទាំងអំពីភារកិច្ច និងមុខងាររបស់គេផងដែរ ។ ក្រមសីលធម៌គួរលើកឡើងពីស្តង់ដា អប្បកិរិយាច្បាស់លាស់សំរាប់គ្រូបង្រៀន និងបុគ្គលិកអប់រំ ហើយដែលបញ្ជាក់ពីលទ្ធផលសំរាប់បុគ្គលដែលមិនគោរពតាមស្តង់ដាទាំងនេះ ។ ការទទួលបាននូវការគាំទ្រផ្នែក

អប់រំពីសំណាក់ក្រុមមនុស្សដែលរងគ្រោះនឹងជួយដល់ដំណើរការជ្រើសរើស និងរក្សាគ្រូបង្រៀន និងបុគ្គលិកអប់រំ ហើយ វាជួយឱ្យឪពុកម្តាយមានសុឆន្ទៈក្នុងការបញ្ជូនកូនពួកគាត់ឱ្យទៅសាលាដែរ ។

ក្នុងកន្លែងមានវិបត្តិ គ្រូបង្រៀន និងបុគ្គលិកអប់រំ ក៏ដូចបុគ្គលផ្សេងៗទៀតក្នុងសហគមន៍ដែរ ត្រូវតែប្រឈមមុខទៅនឹងអ្វីដែលគេបានជួបប្រទះ ហើយត្រូវព្យាយាមស្តាបនាជីវិតពួកគេឡើងវិញ ។ បុគ្គលិកកម្មវិធីអប់រំក្នុង និងក្រៅប្រព័ន្ធ សុទ្ធតែត្រូវការការគាំទ្រដើម្បីតទល់នឹងគ្រោះអាសន្ន និងដើម្បីជួយឱ្យគេអាចដោះស្រាយភាពប៉ះទង្គិះ និងភាពតានតឹងផ្លូវចិត្តដែលកើតឡើងដោយសាគ្រោះមហន្តរាយ និងជម្លោះផ្សេងៗ ។

យន្តការគាំទ្រគួរត្រូវបានផ្តល់ឱ្យពួកគេមានលទ្ធភាពជួយគ្នាទៅវិញទៅមក ក៏ដូចជាបំពាក់ឱ្យពួកគេនូវឧបករណ៍ និងជំនាញចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពរបស់អ្នកសិក្សា ។

ការបណ្តុះបណ្តាលដ៏សមស្របទៅលើគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត សុទ្ធតែមានសារសំខាន់សំរាប់ជោគជ័យនៃការអប់រំក្នុងគ្រាមានអាសន្ន។ ស្តង់ដាបណ្តុះបណ្តាលត្រូវបានលើកឡើងក្នុងផ្នែកការបង្រៀន និងការសិក្សា។ គ្រូបង្រៀន និងបុគ្គលិកអប់រំ ក៏ត្រូវការផងដែរនូវការគាំទ្រក្នុងរូបភាពជាការត្រួតពិនិត្យ ។ ក្នុងថ្នាក់ សហគមន៍ ឪពុកម្តាយ ប្រធានភូមិ គណកម្មការអប់រំសហគមន៍ និងមន្ត្រីរដ្ឋាភិបាលក្នុងមូលដ្ឋាន សុទ្ធតែត្រូវការការបណ្តុះបណ្តាលពីរបៀបពិនិត្យតាមដាន និងគាំទ្រដល់កម្មវិធីអប់រំក្នុងទីកន្លែងរបស់ពួកគេ ។ នៅពេលដែលក្រុមមនុស្សរងគ្រោះត្រូវបានផ្តល់អំណាចឱ្យគ្រប់គ្រងទៅលើកម្មវិធីអប់រំនោះ ពួកគេអនុវត្តសិទ្ធិខ្លួនទីពឹងខ្លួន ហើយគេអាចរកឃើញដំណោះស្រាយសំរាប់បញ្ហារបស់ពួកគេបានទៀតផង ។ ការចូលរួមរបស់សហគមន៍ក្នុងការគាំទ្រ និងត្រួតពិនិត្យបុគ្គលិកអប់រំ វាជួយបង្កើតនូវទំនាក់ទំនងដ៏មានអត្ថប្រយោជន៍រវាងសហគមន៍ និង គ្រូបង្រៀននៅក្នុងបរិស្ថានសិក្សានោះ ។

គេគួរធ្វើការតាមដាន និងវាយតម្លៃជាប្រចាំទៅលើការអនុវត្តការងាររបស់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំផ្សេងៗទៀត ដើម្បីធានាឱ្យមានគុណភាព និងការគាំទ្រជាបន្តបន្ទាប់ពីសំនាក់ក្រុមមនុស្សដែលរងគ្រោះ ។ វាជាការសំខាន់ ដែលការតាមដាន និងវាយតម្លៃត្រូវមានលក្ខណៈជាការណែនាំ តែមិនត្រឹមតែជាការគ្រប់គ្រងតែប៉ុណ្ណោះទេ ។ ការតាមដាន និងការវាយតម្លៃដែលមានការចូលរួម គឺជាគន្លឹះនៃការកែលំអរការអនុវត្តការងាររបស់គ្រូបង្រៀន ។ ការវាយតម្លៃការងារគ្រូបង្រៀន (តាមការដែលអាចធ្វើទៅបាន) គួរតែជាបទពិសោធន៍រៀនសូត្រដែលមានលក្ខណៈវិជ្ជមានមួយសំរាប់គ្រូបង្រៀន ។

## ទំនាក់ទំនងជាមួយនឹងស្តង់ដាទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់

ដំណើរការនៃការបង្កើត និងអនុវត្តកម្មវិធីអប់រំ គឺជាកត្តាសំខាន់មួយដើម្បីកំណត់នូវប្រសិទ្ធភាពនៃជំនួយផ្នែកអប់រំនោះ ។ អត្ថបទក្នុងជំពូកនេះ គួរត្រូវបានប្រើប្រាស់ស្របជាមួយនឹងស្តង់ដាទូទៅ ដោយរួមបញ្ចូលនូវការ

ចូលរួមចំណែករបស់ សហគមន៍ ធនធាន មូលដ្ឋាន ការប៉ាន់ស្មានដំបូង ការឆ្លើយតប ការពិនិត្យតាមដាន និង ការវាយតម្លៃ ។ ជាពិសេស គេគួរតែជំរុញឱ្យមាន ការចូលរួមជាអតិបរិមាពីសំណាក់ក្រុមជនរងគ្រោះដោយមហន្តរាយ ដោយរាប់បញ្ចូលតាំងពី ក្រុមជនងាយទទួលការរងគ្រោះទៀតផង ដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ និង គុណភាពនៃការជួយ ។

**ស្តង់ដាអប្បបរមា:** ស្តង់ដាទាំងនេះមានលក្ខណៈបែបគុណភាព ហើយបញ្ជាក់កំរិតអប្បបរមាដែលនឹងសំរេចក្នុងការផ្តល់ជំនួយអប់រំ ។

**សូចនាករសំខាន់ៗ:** គឺជា "សញ្ញា" ដែលបង្ហាញថា តើស្តង់ដាត្រូវបានសំរេច ឬទេ ។ សូចនាករទាំងនេះ ផ្តល់ជាវិធីមួយសំរាប់វាស់ និងបង្ហាញផលប៉ះពាល់ ឬលទ្ធផលនៃកម្មវិធី ព្រមទាំងដំណើរការឬវិធីសាស្ត្រដែលប្រើ ។ សូចនាករទាំងនេះ អាចមានលក្ខណៈបែបគុណភាព ឬបរិមាណ ។

**កំណត់សំគាល់ណែនាំ:** រួមមានចំណុចជាក់លាក់ដើម្បីពិចារណានៅពេលអនុវត្តស្តង់ដា និងសូចនាករក្នុងស្ថានភាពផ្សេងគ្នា ការណែនាំអំពីការដោះស្រាយការលំបាកជាក់ស្តែង និងដំបូន្មានអំពីបញ្ហាអាទិភាព ។ កំណត់សំគាល់ណែនាំអាចរួមបញ្ចូលផងដែរនូវបញ្ហាសំខាន់ៗដែលទាក់ទងនឹងស្តង់ដា និងសូចនាករ និងរៀបរាប់អំពីជំរើស ដែលពិបាកសំរេច ភាពចំរូងចំរាស់ ឬចន្លោះប្រហោងនៅក្នុងចំណេះដឹងបច្ចុប្បន្ន ។ ឧបសម្ព័ន្ធ២ រួមមានតារាងជ្រើសរើសឯកសារយោង ដែលបង្ហាញប្រភពពត៌មានអំពីបញ្ហាទូទៅ និងបញ្ហាបច្ចេកទេសជាក់លាក់ដែលទាក់ទងនឹងផ្នែកនេះ ។

## គ្រូបង្រៀន និង បុគ្គលិកអប់រំដទៃទៀត

ស្តង់ដាទី១
ការទទួលយក និង ការជ្រើសរើសបុគ្គលិកឱ្យធ្វើការ

គ្រប់ចំនួននៃគ្រូបង្រៀន និង បុគ្គលិកអប់រំដទៃទៀតដែលមានសមត្ថភាពសមស្រប ត្រូវបានទទួលយកឱ្យធ្វើការដោយមានលក្ខណៈវិនិច្ឆ័យជ្រើសរើស ហើយដែលឆ្លុះបញ្ចាំងពីភាពខុសគ្នា និង សមធម៌។

ស្តង់ដាទី២
លក្ខ័ណ្ឌការងារ

គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត ទទួលបាននូវលក្ខ័ខ័ណ្ឌការងារដែលកំណត់យ៉ាងច្បាស់លាស់មួយ និងដែលអនុលោមទៅតាមក្រមសីលធម៌ ហើយពួកគេក៏ត្រូវទទួលបាននូវការតបស្នងប្រយោជន៍យ៉ាងសមរម្យដែរ

ស្តង់ដាទី៣
ការគាំទ្រ និង ការត្រួតពិនិត្យ

យន្តការត្រួតពិនិត្យ និងគាំទ្រត្រូវបានបង្កើតសំរាប់គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត ហើយយន្តការនេះនឹងត្រូវបានប្រើ ប្រាស់ជាប្រចាំ

**ឧបសម្ព័ន្ធ ទី១**
**ក្រមសីលធម៌**

**ឧបសម្ព័ន្ធ ទី២: ឯកសារយោង និង សេចក្តីណែនាំធនធាន ផ្នែកគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត**

## ស្តង់ដារទី១ គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀតៈការទទួលយក និងការជ្រើសរើសបុគ្គលិកឱ្យធ្វើការ

គ្រប់ចំនួននៃគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត ដែលមានសមត្ថភាពសមស្របត្រូវបានទទួលយកឱ្យធ្វើការដោយមានលក្ខណៈចូលរួម និងតម្លាភាព និងដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យជ្រើសរើស ហើយដែលឆ្លុះបញ្ចាំងពីភាពខុសគ្នា និងសមធម៌។

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- ការពណ៌នាពីការងារដ៏ច្បាស់លាស់ និងសមស្របត្រូវបានបង្កើតមុននឹងធ្វើការជ្រើសរើសបុគ្គលិកថ្មី (សូមអាន កំណត់សំគាល់ណែនាំទី១)។
- មានសេចក្តីណែនាំច្បាស់លាស់សំរាប់អនុវត្តការជ្រើសរើសបុគ្គលិកថ្មី។
- គណកម្មការជ្រើសរើសដោយរួមមានតំនាងសហគមន៍ ធ្វើការជ្រើសរើសគ្រូបង្រៀនដោយផ្អែកលើការវាយតម្លៃដែលមានតម្លាភាពទៅលើសមត្ថភាពបេក្ខជន និងដែលគិតពិចារណាទៅលើយេនឌ័រ ភាពខុសគ្នា និងការទទួលយកពីសមាគមន៍ (សូមអាន កំណត់សំគាល់ណែនាំទី ២-៥)។
- គ្រូបង្រៀនដែលទទួលឱ្យធ្វើការ និងចាត់តាំងតាមថ្នាក់មានចំនួនគ្រប់គ្រាន់ដើម្បីបង្ការកុំឱ្យមានថ្នាក់ដែលមានចំនួនសិស្សច្រើនពេក (សូមអាន កំណត់សំគាល់ណែនាំទី ៦)។

**កំណត់សំគាល់ណែនាំ**

១. **ការពណ៌នាពីការងារ** គួរបញ្ចូលនូវ (ក្នុងចំណោមសមាសភាគដទៃទៀត) តួនាទី និងការទទួលខុសត្រូវ និងមានបណ្តាញរាយការណ៍ច្បាស់លាស់ក៏ដូចជាក្រមសីលធម៌ផងដែរ។

២. **បទពិសោធន៍ និង សមត្ថភាពចំនេះដឹងៈ** ក្នុងគ្រាមានអាសន្ន គេគួរជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពចំនេះដឹង ដែលទទួលបានការទទួលស្គាល់ ក៏ប៉ុន្តែក្នុងស្ថានការណ៍ខ្លះគេក៏ត្រូវតែពិចារណាផងដែរទៅលើអ្នកដែលគ្មាន ឬមានបទពិសោធន៍តិចតួច។ ក្នុងករណីនេះ គេទាមទារឱ្យមានការបណ្តុះបណ្តាលបន្ថែមទៀត។ បើគ្រូមានសមត្ថភាព ក៏ប៉ុន្តែគ្មានឯកសារឬសញ្ញាប័ត្របញ្ជាក់ទេនោះ គេត្រូវជ្រើសរើសការធ្វើតេស្តជាវិធីបញ្ជាក់

សមត្ថភាពបេក្ខជន។ គ្រូបង្រៀន គួរតែមានអាយុទាបបំផុត១៨ឆ្នាំ ក៏ប៉ុន្តែប្រសិនបើចាំបាច់ គេអាចជ្រើសតាំងគ្រូបង្រៀនដែលមានអាយុតិចជាង១៨ឆ្នាំបាន។ ក្នុងស្ថានការណ៍ខ្លះ វាជាការចាំបាច់ក្នុងការទទួលយកគ្រូបង្រៀនជាស្ត្រីភេទឱ្យចូលបំរើការ និងកែសំរួលលក្ខណៈវិនិច្ឆ័យឬដំណើរការជ្រើសដើម្បីបង្កើតឱ្យមានសមភាពយេនឌ័រតាមការដែលអាចធ្វើទៅបាន។

វាជាការចាំបាច់ក្នុងការទទួលឱ្យបំរើការនូវគ្រូបង្រៀនដែលចេះនិយាយភាសាកំនើតរបស់អ្នកសិក្សាដែលមកពីក្រុមភាគតិច ដែលកំពុងរៀនជាភាសាជាតិ ប៉ុន្តែមិនមែនរៀនក្នុងភាសាកំនើតខ្លួនទេ។ តាមការដែលអាចធ្វើទៅបាន និងសមស្រប វគ្គសិក្សាបន្ទាន់មួយជាភាសាជាតិ និង/ឬជាភាសាប្រទេសម្ចាស់ផ្ទះ គួរត្រូវបានផ្តល់ដល់អ្នកសិក្សា (សូមអានផងដែរនូវការបង្រៀន និងការសិក្សា ស្តង់ដាទី១ កំណត់សំគាល់ណែនាំទី ៧ លើទំព័រ៨១)

៣. **លក្ខណៈវិនិច្ឆ័យ គួរបញ្ចូលនូវចំណុចខាងក្រោម**

- សមត្ថភាពចំនេះដឹងការងារ: បទពិសោធន៏អប់រំ បង្រៀន ឬចិត្តសាស្ត្រ, ជំនាញ, បទពិសោធន៏ផ្សេងៗទៀត សមត្ថភាពភាសាដែលទាក់ទង
- គុណសម្បត្តិផ្ទាល់ខ្លួន: អាយុ យេនឌ័រ (អ្នកជ្រើសរើសគួរផ្តោតទៅលើលំនឹងយេនឌ័រ ប្រសិនបើអាច ធ្វើទៅបាន) ប្រភពជនជាតិ និង សាសនា ភាពផ្សេងៗពីគ្នា (ដើម្បីធានាឱ្យមានគ្រប់តំនាងពី សហគមន៏)
- គុណសម្បត្តិផ្សេងៗទៀត: ការទទួលស្គាល់ និងការប្រាស្រ័យទាក់ទងជាមួយយសហគមន៏ជាជនដែលមកពីក្រុមមនុស្សរងគ្រោះ។

៤. **ការជ្រើសរើស:** គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត គួរត្រូវបានជ្រើសរើសយ៉ាងពិសេសចេញពីចំណោមក្រុមមនុស្សរងគ្រោះ ប៉ុន្តែប្រសិនបើចាំបាច់គេក៏អាចជ្រើសរើសពីមជ្ឈដ្ឋានខាងក្រៅផងដែរ។ ប្រសិនបើទីតាំងត្រូវបានបង្កើតសំរាប់ជនភៀសខ្លួន ឬក្រុមមនុស្សចាកចោលទីលំនៅក្នុងស្រុក គេក៏អាចទទួលយកនូវបេក្ខជនដែលនៅក្នុងមូលដ្ឋាននោះផងដែរ ប្រសិនបើការទទួលយកនេះនឹងជួយឱ្យមានទំនាក់ទំនងល្អរវាងគ្នា និងគ្នា។ ការជ្រើសរើសគួរត្រូវបានធ្វើដោយមានការប្រឹក្សាយោបល់ជាមួយសហគមន៏ សហគមន៏ម្ចាស់ផ្ទះ និងអជ្ញាធរមូលដ្ឋាន។

៥. **ការណែនាំបញ្ជូន:** ក្នុងកន្លែងមានវិបត្តិ គេគួរធ្វើការពិនិត្យលើឯកសារណែនាំបញ្ជូនគ្រូបង្រៀន និងបុគ្គលិកអប់រំ ដើម្បីជៀសវាងការផ្តល់ការងារដល់បុគ្គលិកដែលអាចធ្វើឱ្យប៉ះពាល់ដល់អ្នកសិក្សា ឬអ្នកដែលពុំគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់គេ។

៦. **ស្តង់ដាជាក់លាក់ក្នុងមូលដ្ឋាន** គួរត្រូវបានបង្កើតឡើងដែលស្តីពីចំនួនសិស្សអតិបរមាក្នុង១ថ្នាក់ ហើយត្រូវប្រឹងប្រែងជ្រើសយកគ្រូឱ្យគ្រប់ចំនួន ដើម្បីជៀសវាងកុំឱ្យចំនួនសិស្សមានគំលាតខ្លាំងពេកពីស្តង់ដានេះ។ របាយការណ៍តាមដានគួរលើកឡើងនូវចំនួនថ្នាក់ដែលមានសិស្សច្រើនក្នុងករីតសិក្សាផ្សេងៗគ្នាដែរ។

## ស្តង់ដាទី២នៃគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀតៈ លក្ខខ័ណ្ឌការងារ

គ្រូបង្រៀន និង បុគ្គលិកអប់រំដទៃទៀតទទួលបាននូវលក្ខខ័ណ្ឌការងារ ដែលកំណត់យ៉ាងច្បាស់លាស់មួយ និងដែលអនុលោមទៅតាមក្រមសីលធម៌ ហើយពួកគេក៏ត្រូវទទួលបាននូវការតបស្នងប្រយោជន៍យ៉ាងសមរម្យដែរ ។

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- ការតបស្នងប្រយោជន៍ និង លក្ខខ័ណ្ឌការងារត្រូវបានបញ្ជាក់ក្នុងកិច្ចសន្យាការងារ ហើយការតបស្នងប្រយោជន៍ត្រូវបានផ្តល់យ៉ាងទៀងទាត់ និងអាស្រ័យទៅលើកំរិត និងប្រសិទ្ធភាពការងារ (សូមអាន កំណត់សំគាល់ណែនាំ ទី ១-២)

- ភ្នាក់ងារអន្តរជាតិ ធ្វើការសំរបសំរួលជាមួយអជ្ញាធរអប់រំគណកម្មការអប់រំសហគមន៍ និង NGOs ដើម្បីបង្កើតនូវយុទ្ធសាស្ត្រសមស្រប និងដើម្បីយល់ព្រមប្រើប្រាស់កំរិតប្រាក់ខែដ៏យុត្តិធម៌មិនមាននិរន្តភាព និងដែលអាចទទួលយកបានសំរាប់ចំនាត់ប្រភេទផ្សេងៗ និងកំរិតផ្សេងៗនៃគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត (សូមអាន កំណត់សំគាល់ណែនាំទី ២)

- ក្រមសីលធម៌ និងលក្ខខ័ណ្ឌការងារ ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីសំនាក់បុគ្គលិកអប់រំ និងសមាជិកសហគមន៍ហើយមានសេចក្តីណែនាំអនុវត្តច្បាស់លាស់ (សូមអាន កំណត់សំគាល់ណែនាំទី ១ និងទី ៣) ។

- ក្រមសីលធម៌ត្រូវបានចុះហត្ថលេខា និងអនុវត្តតាមដោយបុគ្គលិកអប់រំ ហើយវិធានការណ៍សមស្របត្រូវបានសរសេរឡើង និងប្រើប្រាស់ក្នុងករណីមានការប្រព្រឹត្តផ្គង និង/ឬមានការរំលោភដល់ក្រមសីលធម៌នោះ (សូមអាន កំណត់សំគាល់ណែនាំទី ៣-៤) ។

### កំណត់សំគាល់ណែនាំ

១. **លក្ខខ័ណ្ឌការងារ** គួរបញ្ជាក់ពីការពណ៌នាការងារ ការតបស្នងប្រយោជន៍ វត្តមាន ចំនួនម៉ោង និងថ្ងៃធ្វើការ រយៈពេល កិច្ចសន្យាការគាំទ្រ និងការត្រួតពិនិត្យ ព្រមទាំងយន្តការដោះស្រាយជម្លោះ (សូមអានផងដែរនូវស្តង់ដាទី១ កំណត់សំគាល់ណែនាំទី១ ខាងលើ) ។

**២. ការតបស្នងប្រយោជន៍ អាចជារូបិយប័ណ្ណ ឬ អរូបិយប័ណ្ណ** ហើយត្រូវមានភាពសមស្របទៅលើអ្វីដែលបានព្រមព្រៀងគ្នាហើយត្រូវបានបើកឱ្យយ៉ាងទៀងទាត់ ។ ក៏រិតសមស្របនៃការតបស្នងប្រយោជន៍គួរត្រូវបានកំណត់តាមរយៈការប្រាស្រ័យចូលរួមមួយ ដើម្បីធានាឱ្យមានភាពសំរបសំរួលរវាងភ្នាក់ងារដែលពាក់ព័ន្ធ ។ វាគួរតែធ្វើក្នុងក៏រិតមួយដែលធានាឱ្យមានភាពគុណភាពវិជ្ជាជីវៈ និងការបន្តនូវសេវាកម្មព្រមទាំងនិរន្តភាព ។ ជាពិសេសវាគួរមានចំនួនគ្រប់គ្រាន់ដើម្បីឱ្យគ្រូបង្រៀនមានលទ្ធភាពផ្តោតទៅលើ ការងារអាជីពរបស់ខ្លួនជាជាងការដែលពួកគាត់ត្រូវស្វែងរកប្រភពចំណូលបន្ថែមទៀតដើម្បីបំពេញតំរូវការមូលដ្ឋានរបស់គាត់ ។ វាក៏គួរតែមានប្រាក់បំរុងអនុលោមទៅតាមលក្ខ័ណ្ឌការងារនិងក្រមសីលធមិ គេគួរយកចិត្តទុកដាក់ដើម្បីជៀសវាងស្ថានការណ៍មួយដែលគ្រូបង្រៀនមកពីប្រភពផ្សេងគ្នា (ឧទាហរណ៍ អ្នកក្នុងមូលដ្ឋាន និងជនភៀសខ្លួន) ទទួលបាននូវប្រាក់ឧបត្ថម្ភក្នុងក៏រិតខុសគ្នា ។ ភាគីសំខាន់ៗ គួរចូលរួមក្នុងការបង្កើតយុទ្ធសាស្ត្ររយៈពេលវែងសំរាប់ប្រព័ន្ធតបស្នងប្រយោជន៍ដែលមាននិរន្តភាព ។ វាក៏គួរតែមានការសំរបសំរួល រវាងភ្នាក់ងារអង្គការសហប្រជាជាតិ NGOs អជ្ញាធរអប់រំ និងអង្គការផ្សេងៗ ដើម្បីកំណត់នូវក៏រិតរួមគ្នាមួយនៃការតបស្នងប្រយោជន៍ ។

**៣. ក្រមសីលធមិៈ** គួរលើកឡើងនូវស្តង់ដាច្បាស់លាស់ដែលនិយាយពីអកប្បកិរិយានៃបុគ្គលិកអប់រំហើយបញ្ជាក់នូវលទ្ធផលសំរាប់បុគ្គលដែលមិនអនុវត្តតាមស្តង់ដានោះ ។ ក្រុមនេះគួរត្រូវបានប្រើប្រាស់ក្នុងបរិស្ថានសិក្សា និងសកម្មភាព ឬកម្មវិធីអប់រំផ្សេងៗ (សូមអានឧបសម្ព័ន្ធទី១ លើទំព័រទី៩៩ ដែលនិយាយពី គំរូនៃក្រមសីលធមិ) ។ ក្រមសីលធមិ គួរធានាថាគ្រូ និងបុគ្គលិកអប់រំជំរុញបង្កើតបរិស្ថានរៀនសូត្រវិជ្ជមាន ព្រមទាំងសុខមាលភាពរបស់អ្នកសិក្សាផងដែរ ។ ក្រមគួរគូសបញ្ជាក់ (ក្នុងចំណោមចំណុចផ្សេងៗទៀត) ថាបុគ្គលិកអប់រំត្រូវៈ

- បញ្ចេញអកប្បកិរិយាជាអាជីពដោយរក្សាស្តង់ដាសីលធមិខ្ពស់គ្រប់គ្រងខ្លួនឯង ព្រមទាំងមានឥរិយាបថមានសីលធមិ, ថ្លៃថ្នូរ
- ចូលរួមក្នុងការបង្កើតនូវបរិស្ថានមួយដែលទទួលស្គាល់សិស្សគ្រប់ៗគ្នា
- រក្សាបរិស្ថាន សុវត្ថិភាព និង មានសុខភាពល្អ មិនទទួលការរំលោភបៀតបៀន (ដោយរួមទាំងការ បៀតបៀនផ្លូវភេទ) ការគំរាមកំហែងការរំលោភបំពាន និងអំពើហឹង្សា ព្រមទាំងការប្រកាន់រើសអើង ។
- រក្សានូវវត្តមាន និង ការមករៀនទាន់ពេលវេលាទៀងទាត់
- បង្ហាញគុណភាព អាជីព ព្រមទាំងប្រសិទ្ធភាពនៃការងារ និង
- បញ្ចេញឥរិយាបថផ្សេងទៀតដែលទទួលស្គាល់ថាជាការសមរម្យដោយសហគមន៍ និងភាគីដែលពាក់ព័ន្ធដល់ការអប់រំ

៤. **សេចក្តីណែនាំការអនុវត្តក្រមសីលធម៌:** វាគួរតែមានការបណ្តុះបណ្តាលស្តីពីក្រមសីលធម៌ដល់បុគ្គលិកអប់រំ ឬមិនមែនបុគ្គលិកអប់រំគ្រប់រូបដែលធ្វើការក្នុងកន្លែងសិក្សា។ ការបណ្តុះបណ្តាល និងការគាំទ្រគួរបានផ្តល់ដល់សមាជិកនៃគណកម្មការអប់រំសហគមន៍ និង អ្នកត្រួតពិនិត្យអប់រំ និងអ្នកគ្រប់គ្រងស្តីពីតួនាទី និងភារកិច្ចក្នុងការតាមដានការអនុវត្តក្រមសីលធម៌នោះ។ ពួកគេក៏គួរត្រូវបានជួយផងដែរក្នុងការកំណត់ និងបញ្ចូលបញ្ហាសំខាន់ៗនៃក្រមសីលធម៌ទៅក្នុងផែនការសកម្មភាពរបស់សាលារៀន កម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងទៀត។ យន្តការត្រួតពិនិត្យគួរបង្កើតនូវទំរង់ការរាយការណ៍ និងតាមដាន ដែលការពារដល់ការសំងាត់របស់ភាគីដែលមានការពាក់ព័ន្ធ (សូមអានផងដែរនូវស្តង់ដាទី៣ ខាងក្រោម)។

## ស្តង់ដាទី៣នៃគ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត: ការគាំទ្រ និងការត្រួតពិនិត្យ

យន្តការត្រួតពិនិត្យ និង គាំទ្រត្រូវបានបង្កើតសំរាប់គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀតហើយយន្តការនេះ ត្រូវបានប្រើប្រាស់ជាប្រចាំដែរ។

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- យន្តការត្រួតពិនិត្យផ្តល់នូវការវាយតម្លៃតាមដាន និងគាំទ្រយ៉ាងទៀងទាត់ដល់គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត (សូមអាន កំណត់សំគាល់ណែនាំទី ១-២)
- ការវាយតម្លៃលទ្ធផលការងារបុគ្គលិកត្រូវបានធ្វើឡើង សរសេរឡើង និងពិភាក្សាយ៉ាងទៀងទាត់ជាមួយបុគ្គលដែលពាក់ព័ន្ធ (សូមអាន កំណត់សំគាល់ណែនាំទី៣)
- ការគាំទ្រ និងការប្រឹក្សាផ្នែកចិត្តសាស្ត្រដ៏សមស្របត្រូវបានផ្តល់ដល់គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀតតាមការចាំបាច់ (សូមអាន កំណត់សំគាល់ណែនាំទី ៤)។

### កំណត់សំគាល់ណែនាំ

១. **យន្តការត្រួតពិនិត្យ:** ប្រទេស ឬកន្លែងរងគ្រោះនិមួយៗ គួរកំណត់នូវស្តង់ដាសំរាប់គ្រូបង្រៀន និងបុគ្គលិកអប់រំ ហើយបង្កើត និងអនុវត្តយន្តការគាំទ្រ និងត្រួតពិនិត្យមួយ។ យន្តការនេះ អាចរួមមានតំនាងពីសហគមន៍(ដោយរួមទាំងពីអ្នកដឹកនាំប្រពៃណី និង សាសនា) អង្គការសាលារៀនមូលដ្ឋានដូចជា សមាគមមាតាបិតា គ្រូបង្រៀនអជ្ញាធរ មូលដ្ឋាន នាយកសាលា និងសហជីពគ្រូបង្រៀន។ យន្តការត្រួតពិនិត្យ គួរមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធ

ជាមួយគណកម្មការអប់រំសហគមន៍ ។ គណកម្មការគួរបញ្ចូលក្នុងសេចក្តីអធិប្បាយការងាររបស់ខ្លួននូវការតាមដានបុគ្គលិកអប់រំទៅលើផ្នែកក្រមសីលធម៌ ដោយផ្តោតទៅលើគុណភាពប្រសិទ្ធភាពការងារ និងការប្រព្រឹត្តដ៏សមរម្យ (សូមអានផងដែរនូវការចូលរួមសហគមន៍ស្តង់ដាទី១ នៅទំព័រទី១៧) ។

២. **ការបណ្តុះបណ្តាល:** សូមអានការបង្រៀន និងការសិក្សាស្តង់ដាទី២នៅទំព័រទី៨២នូវពត៌មាន ស្តីពីការបណ្តុះបណ្តាលបុគ្គលិក ។

៣. **ការវាយតម្លៃលទ្ធផលការងារបុគ្គលិក** គួរបញ្ចូលនូវការវាយតម្លៃទៅលើប្រសិទ្ធភាពគ្រូបង្រៀន ឬបុគ្គលិកអប់រំដទៃទៀត ហើយគួរផ្តល់នូវឱកាសប្រឹក្សាយោបល់ដល់គ្រូបង្រៀន នាយកសាលានិងបុគ្គលិកដែលមានការពាក់ព័ន្ធផ្សេងៗទៀត ដើម្បីកំណត់នូវបញ្ហានិងបង្កើតសកម្មភាពបន្តបន្ទាប់ទៀតដែលត្រូវយល់ព្រមជាមួយគ្នា ។ ក្នុងពេលសមស្រប ការវាយតម្លៃគួរទទួលស្គាល់ និងអបអរសាទរដល់ស្នាដៃល្អ ដើម្បីលើកទឹកចិត្តបុគ្គលិកអប់រំ ។ ការតាមដាន និងការវាយតម្លៃដែលមានលក្ខណៈចូលរួមអាចជំរុញទឹកចិត្តគ្រូបង្រៀន ហើយបង្កើននូវសមត្ថភាពរបស់ពួកគាត់ ។

៤. **ការគាំទ្រវិបត្តិ:** ទោះជាគ្រូបង្រៀន ឬបុគ្គលិកអប់រំដទៃទៀតដែលមានការបណ្តុះបណ្តាល និងបទពិសោធន៍ក៏ដោយ ក៏ពួកគេអាចទទួលការប៉ះពាល់ផ្លូវចិត្តដោយសារព្រឹត្តិការណ៍គ្រោះអាសន្ន ហើយអាចជួបបញ្ហាប្រឈម និង ការទទួលខុសត្រូវដូចអ្នកសិក្សាដែរ ហើយលទ្ធភាពដោះស្រាយវិបត្តិទាំងនោះ ក៏អាស្រ័យទៅនឹងការជួយគាំទ្រដែលមានដែរ ។ យន្តការគាំទ្រ គួរត្រូវបានបង្កើតក្នុងសហគមន៍ដើម្បីជួយដល់គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀតដោះស្រាយស្ថានភាពមានវិបត្តិ ។

# ការបង្រៀន និង ការសិក្សា: ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១: ក្រមសីលធម៌គ្រូបង្រៀន

**គ្រប់ពេលវេលា គ្រូបង្រៀនត្រូវ:**

- ប្រព្រឹត្តក្នុងឥរិយាបថមួយ ដែលរក្សាកិត្តិយស និងភាពថ្លៃថ្នូរនៃអាជីព
- ការពារការសំងាត់នូវអ្វីៗ ដែលប្រាប់ជាសំងាត់ដោយសិស្សណាម្នាក់
- ការពារសិស្សពីលក្ខណៈដែលរំខានដល់ការសិក្សា ឬដែលប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពសិស្ស
- មិនកេងចំណេញយកប្រយោជន៍លើតួនាទីរបស់ខ្លួន
- មិនបៀតបៀនផ្លូវភេទដល់សិស្សណាម្នាក់ ឬមានឥរិយាបថទំនាក់ទំនងផ្លូវភេទជាមួយសិស្ស
- ជាគំរូល្អ និង ស្មោះត្រង់

**ក្នុងថ្នាក់ គ្រូបង្រៀនត្រូវ:**

- បង្កើតបរិស្ថានសិក្សាវិជ្ជមាន និង មានសុវត្ថិភាព
- បង្រៀនក្នុងឥរិយាបថមួយដែលគោរពដល់ភាពថ្លៃថ្នូរ និង សិទ្ធិរបស់សិស្សគ្រប់ៗរូប ។
- បង្កើតឱ្យសិស្សជឿជាក់លើខ្លួនឯង មានទំនុកចិត្ត និង ឱ្យតម្លៃដល់ខ្លួនឯង ។
- ជំរុញបង្កើតនូវក្តីសង្ឃឹមខ្ពង់ខ្ពស់ដល់សិស្ស ហើយជួយសិស្សម្នាក់ៗឱ្យប្រើសមត្ថភាពខ្ពស់បំផុតរបស់គេ
- ជំរុញទឹកចិត្តសិស្សឱ្យក្លាយជាអ្នកសិក្សាសកម្ម មានការទទួលខុសត្រូវ និងមានប្រសិទ្ធភាព ។
- បង្កើតបរិយាកាសជឿជាក់

**ក្នុងជីវិតការងាររបស់គេ គ្រូបង្រៀនត្រូវ:**

- បង្ហាញនូវសមត្ថភាពជាមូលដ្ឋាននៃវិធីសាស្ត្រអប់រំ និង ក្នុងមុខវិជ្ជាដែលគេបង្រៀន
- បង្ហាញនូវការយល់ដឹង (តាមរយៈការបង្រៀន) ពីរបៀបដែលសិស្សរៀន
- មករៀនទាន់ពេលហើយមានការរៀបចំរួចស្រេចក្នុងការបង្រៀន
- មិនពាក់ព័ន្ធនឹងសកម្មភាពណាដែលប៉ះពាល់ដល់គុណភាពនៃការបង្រៀន ។
- ទាញប្រយោជន៍ពីគ្រប់ឱកាសអភិវឌ្ឍន៍ការងារ និងប្រើវិធីសាស្ត្របង្រៀនទំនើប និងមានការទទួលស្គាល់ ។
- បង្រៀនគោលការណ៍នៃពលរដ្ឋល្អ សន្តិភាព និងការទទួលខុសត្រូវក្នុងសង្គម ។
- កំណត់យ៉ាងទៀងត្រង់នូវលទ្ធផលការសិក្សា និងលទ្ធផលប្រលងរបស់សិស្សម្នាក់ៗ ។

**ចំពោះសហគមន៍ គ្រូបង្រៀនត្រូវ:**

- ជំរុញទឹកចិត្តឪពុកម្តាយឱ្យគាំទ្រ និងចូលរួមចំនែកក្នុងការសិក្សារបស់កូនៗពួកគាត់ ។

- ទទួលស្គាល់ពីសារសំខាន់នៃទំនាក់ទំនងរវាងគ្រួសារ សហគមន៍ និង សាលារៀន
- គាំទ្រ និង បង្កើតរូបភាពវិជ្ជមាននៃសាលារៀន ។

បន្ថែមទៅលើចំណុចលើកឡើងខាងលើ គ្រូបង្រៀនត្រូវគោរពច្បាប់វិន័យ និងគោលការណ៏របស់បរិស្ថានសិក្សាផ្សេងៗទៀត( ជំរុំ សាលារៀន... ។ល ។)

# ៥. គោលនយោបាយអប់រំ និង ការសំរបសំរួល

**សេចក្ដីផ្ដើម**

**ច្បាប់ និង សេចក្ដីប្រកាសអន្តរជាតិលើកឡើងពីសិទ្ធិរបស់បុគ្គលគ្រប់ៗរូប ក្នុងការទទួលការអប់រំ ដែលបង្កើតនូវគ្រឹះនៃការស្ថាបនាសិទ្ធិមនុស្សគ្រប់រូប ។ សិទ្ធិបញ្ចេញមតិដោយសេរី សិទ្ធិទទួលបានសមភាព ព្រមទាំងសិទ្ធិមានសំលេងក្នុងការសំរេចចិត្តទៅលើគោលនយោបាយសង្គម និង អប់រំ សុទ្ធតែផ្អែកដ៏សំខាន់នៃការអប់រំ**

ក្នុងទីកន្លែងមានគ្រោះអាសន្ន វាជាការសំខាន់ដែលសិទ្ធិទាំងនេះត្រូវបានគាំពារ ។ ជាផ្នែកមួយនៃការឆ្លើយតបទៅនឹងគ្រោះអាសន្ន អជ្ញាធរអប់រំ និងភាគីពាក់ព័ន្ធសំខាន់ៗគួរបង្កើត និងអនុវត្តផែនការអប់រំដែលគិតគូរពិចារណាទៅលើគោលនយោបាយអប់រំជាតិនិងអន្តរជាតិលើកកំពស់សិទ្ធិទទួលការអប់រំ ហើយឆ្លើយតបទៅនឹងតំរូវការសិក្សារបស់ក្រុមមនុស្សដែលរងគ្រោះ ។ ក្របខ័ណ្ឌនេះគួរតំរង់ទិសឆ្ពោះទៅរកការកែលំអគុណភាពអប់រំ និងការទទួលបានការអប់រំ ហើយវាគួរបង្ហាញយ៉ាងច្បាស់លាស់នូវការផ្លាស់ប្ដូរពីជំនួយគ្រោះអាសន្នទៅរកការអភិវឌ្ឍន៍ ។ ការចូលរួមចំណែករបស់សហគមន៍ក្នុងការរៀបចំផែនការ និងអនុវត្តអន្តរាគមន៍កម្មវិធី និងគោលនយោបាយ គឺមានសារសំខាន់ដល់ជោគ ជ័យនៃការឆ្លើយតបទៅនឹងគ្រោះអាសន្ននោះ ។

ក្នុងស្ថានការណ៍គ្រោះអាសន្ន វាច្រើនតែមានកង្វះខាតនូវការសំរបសំរួលហើយកម្មវិធីអប់រំត្រូវបានអនុវត្តដោយឯកឯងពីភាគីពាក់ព័ន្ធផ្សេងៗទៀត ។ យន្តការសំរបសំរួលអន្តរក្រសួងជាការចាំបាច់ក្នុងកន្លែងតាំងទីលំនៅសហគមន៍ស្រុក ថ្នាក់ជាតិ និងថ្នាក់តំបន់ ហើយយន្តការនេះត្រូវមានភាពទូលំទូលាយ និងមានតម្លាភាព ។ យន្តការទាំងនេះមានសារសំខាន់ក្នុងការវាយតម្លៃតំរូវការបង្កើតវិធីសាស្ដ្រដែលមានស្តង់ដា និងចែករំលែកនូវធនធាន និង ពតិមានរវាងគ្រប់ភ្នាក់ងារ និងភាគីពាក់ព័ន្ធទាំងអស់ ។ ការអប់រំគួរត្រូវបានសំរបសំរួលនៅក្នុងជំនួយមនុស្សធមិដែលផ្ដល់ស្បៀងអាហារសុខភាព និងអន្តរាគមន៍លើទឹក និង អនាម័យ ។

ការផ្តល់ជំនួយផ្នែកអប់រំដោយផ្នែកទៅលើការអនុវត្តល្អៗរួចមកហើយគួរតែត្រូវបានធ្វើឡើងតបទៅ នឹងតំរូវការរបស់សហគមន៍ក្នុងបរិបទជាក់លាក់នៃគ្រោះអាសន្ន។ ជំនាញដើម្បីភាពរស់រាន់នានាដូចជាយុទ្ធនាការស្វែងយល់ពី គ្រាប់មីន អនាម័យ និង HIV/ AIDs គួរត្រូវបានផ្តល់ដល់គ្រប់ក្រុមអាយុ។

## ទំនាក់ទំនងជាមួយនឹងស្តង់ដារទូទៅសំរាប់គ្រប់ចំណាត់ថ្នាក់

ដំណើរការនៃការបង្កើត និងអនុវត្តកម្មវិធីអប់រំគឺជាកត្តាសំខាន់មួយដើម្បីកំណត់នូវប្រសិទ្ធភាពនៃជំនួយផ្នែកអប់រំនោះ។ អត្ថបទក្នុងជំពូកនេះ គួរត្រូវបានប្រើប្រាស់ស្របជាមួយនឹងស្តង់ដារទូទៅដោយរួមបញ្ចូលនូវការចូលរួមចំណែករបស់ សហគមន៍ ធនធានមូលដ្ឋាន ការប៉ាន់ស្មានដំបូង ការឆ្លើយតប ការពិនិត្យតាមដាន និងការវាយតម្លៃ។ ជាពិសេសគេគួរតែជំរុញឱ្យមានការចូលរួមជាអតិបរិមាពីសំនាក់ក្រុមជនរងគ្រោះដោយមហន្តរាយ ដោយរាប់បញ្ចូលតាំងពីក្រុមជនងាយទទួលការរងគ្រោះទៀតផងដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ និង គុណភាពនៃការជួយ។

**ស្តង់ដាអប្បបរមា:** ស្តង់ដាទាំងនេះមានលក្ខណៈបែបគុណភាព ហើយបញ្ជាក់កំរិតអប្បបរមាដែលនឹងសំរេចក្នុងការផ្តល់ជំនួយអប់រំ។

**សូចនាករសំខាន់ៗ:** គឺជា "សញ្ញា" ដែលបង្ហាញថាតើស្តង់ដាត្រូវបានសំរេច ឬទេ។ សូចនាករទាំងនេះ ផ្តល់នូវវិធីមួយសំរាប់វាស់ និងបង្ហាញផលប៉ះពាល់ឬលទ្ធផលនៃកម្មវិធីព្រមទាំងដំណើរការឬវិធីសាស្ត្រដែលប្រើ។ សូចនាករទាំងនេះ អាចមានលក្ខណៈបែបគុណភាព ឬបរិមាណ។

**កំណត់សំគាល់ណែនាំ:** រួមមានចំណុចជាក់លាក់ដើម្បីពិចារណានៅពេលអនុវត្តស្តង់ដា និងសូចនាករក្នុងស្ថានភាពផ្សេងគ្នា ការណែនាំអំពីការដោះស្រាយការលំបាកជាក់ស្តែង និងដំបូន្មានអំពីបញ្ហាអាទិភាព។ កំណត់សំគាល់ណែនាំអាចរួមបញ្ចូលផងដែរនូវបញ្ហាសំខាន់ៗដែលទាក់ទងនឹងស្តង់ដា និងសូចនាករ និងរៀបរាប់អំពីជំរើសដែលពិបាកសំរេចភាពចំរូងចំរាស់ ឬចន្លោះប្រហោងនៅក្នុងចំណេះដឹងបច្ចុប្បន្ន។ ឧបសម្ព័ន្ធ២ រួមមានតារាងជ្រើសរើសឯកសារ យោងដែលបង្ហាញប្រភពពត៌មានអំពីបញ្ហាទូទៅ និងបញ្ហាបច្ចេកទេសជាក់លាក់ដែលទាក់ទងនឹងផ្នែកនេះ។

# គោលនយោបាយអប់រំ និង ការសំរបសំរួល

**ស្តង់ដាទី១**
**ការបង្កើតគោលនយោបាយ និង ការអនុម័ត**

អជ្ញាធរអប់រំ ផ្តល់អាទិភាពការចូលរៀន ដោយសេរីដល់បុគ្គលគ្រប់រូប ព្រមទាំង អនុម័ត គោលនយោបាយរស់រវើក ដើម្បី ជំរុញបង្កើតភាពបញ្ចូលគ្នា និងគុណភាព អប់រំ យោលទៅតាមបរិបទគ្រោះអាសន្ន

**ស្តង់ដាទី២**
**ការធ្វើផែនការ និង ការអនុវត្ត**

សកម្មភាបអប់រំក្នុងគ្រាមានអាសន្ន គិតគូរ ពិចារណាទៅលើគោលនយោបាយ និង ស្តង់ ដាអប់រំជាតិ និងអន្តរជាតិ ព្រមទាំងពីតំរូវ ការសិក្សារបស់ក្រុមមនុស្សរងគ្រោះ។

**ស្តង់ដាទី៣**
**ការសំរបសំរួល**

មានយន្តការសំរបសំរួលមានតម្លាភាព មួយ សំរាប់សកម្មភាពអប់រំក្នុងគ្រាមាន អាសន្ន ដោយរួមតាំងពីការចែករំលែកដ៏មានប្រសិទ្ធ ភាពនូវពតិមានរវាង ភាគីដែលពាក់ព័ន្ធ។

**ឧបសម្ព័ន្ធ:** ឯកសារយោង និង សេចក្តីណែនាំធនធានផ្នែកគោលនយោបាយអប់រំ និង ការសំរបសំរួល

## ស្តង់ដាទី១នៃ គោលនយោបាយអប់រំ និង ការសំរបសំរួល: ការបង្កើតគោលនយោបាយ និង ការអនុម័ត

អាជ្ញាធរអប់រំផ្តល់អាទិភាពការចូលរៀនដោយសេរីដល់បុគ្គលគ្រប់រូប ព្រមទាំងអនុម័តគោលនយោបាយរស់រវើកដើម្បីជំរុញបង្កើតភាពបញ្ចូលគ្នា និងគុណភាពអប់រំយោលទៅតាម បរិបទគ្រោះអាសន្ន

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- ទាំងក្នុងកំឡុងពេល និងក្រោយពេលមានគ្រោះអាសន្ន ច្បាប់ និងគោលនយោបាយអប់រំ ប្រកាន់យកសិទ្ធិទទួលការអប់រំដែលបានចែងក្នុងឧបករណ៍ផ្លូវច្បាប់ និងសេចក្តីប្រកាសសិទ្ធិមនុស្សអន្តរជាតិ (សូមអាន កំណត់សំគាល់ណែនាំ ទី១-២) ។
- ច្បាប់ បទបញ្ជា និងគោលនយោបាលការពារមិនឱ្យមានការប្រកាន់រើសអើងក្នុងវិស័យអប់រំចំពោះក្រុមដែលងាយរងគ្រោះ និងក្រុមដែលបាត់បង់ប្រយោជន៏ (សូមអាន កំណត់សំគាល់ណែនាំទី៣) ។
- ច្បាប់ បទបញ្ជា និងគោលនយោបាយត្រូវបានអនុវត្ត ដើម្បីធានាថាអ្នកសិក្សា មិនត្រូវរារាំងមិនឱ្យទទួលការ អប់រំ ព្រោះតែគេមានធនធានពុំគ្រប់គ្រាន់ ឬព្រោះតែគ្រួសារគេទេ (សូមអាន កំណត់សំគាល់ណែនាំទី៤)
- ច្បាប់ បទបញ្ជា និងគោលនយោបាយមិនឃាឃាំងដល់សាលាសំរាប់ជនភៀសខ្លួនប្រើប្រាស់កម្មវិធីសិក្សារបស់ប្រទេសកំនើត ។
- ច្បាប់ បទបញ្ជា និងគោលនយោបាយអនុញ្ញាត្តឱ្យមានការសាងសង់បង្កើតបរិក្ខាអប់រំដោយភ្នាក់ងារក្រៅរដ្ឋាភិបាលនៅពេលចាំបាច់ហើយដែលបរិក្ខាទាំងនោះត្រូវអនុវត្តមាន និងទទួលអធិការកិច្ចពីអជ្ញាធរអប់រំ
- ច្បាប់ បទបញ្ជា និងគោលនយោបាយត្រូវបានចែកចាយក្នុងលក្ខណ:មួយដែលយល់ដឹងដោយគ្រប់ភាគីពាក់ព័ន្ធ
- គោលនយោបាយជំរុញឱ្យមានការបង្កើត និងប្រើប្រាស់តារាងទិន្នន័យប្រព័ន្ធពតិមានគ្រប់គ្រងការអប់រំ (EMIS) ដែលត្រូវប្រើជាឧបករណ៍មួយសំរាប់វិភាគ និង ប្រតិកម្មទៅនឹងបំរែបំរួលនៃការទទួលបាន និង ការបញ្ចប់ការអប់រំ (សូមអាន កំណត់សំគាល់ណែនាំទី5) ។

- គោលនយោបាយអប់រំជាតិ ត្រូវបានគាំទ្រដោយក្របខ័ណ្ឌច្បាប់ និងថវិកា ដែលនាំឱ្យមានការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងស្ថានការណ៍គ្រោះអាសន្ន (សូមអាន កំណត់សំគាល់ណែនាំទី៦) ។

**កំណត់សំគាល់ណែនាំ**

១. **ច្បាប់ និង សេចក្តីប្រកាសសិទ្ធិមនុស្សអន្តរជាតិ** ដែលគួរតែប្រកាន់យក រួមមាន (ប៉ុន្តែមិនកំណត់តែ) សន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (១៩៨៩) សេចក្តីប្រកាសជាសាកលនៃសិទ្ធិមនុស្ស (១៩៤៨) កត្តិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌ (១៩៦៦) សន្ធិសញ្ញាស្តីពីការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងស្ត្រីភេទ (1979) និង ក្របខ័ណ្ឌសកម្មភាពក្រុង Dakar: ការអប់រំសំរាប់ទាំងអស់គ្នា (2000) ។

ច្បាប់ និង ក្របខ័ណ្ឌច្បាប់ ក៏បញ្ចូលផងដែរនូវច្បាប់អន្តរជាតិដែលទាក់ទងទៅនឹងការថែរក្សា ក្រុមមនុស្ស (ដោយ ផ្តោតទៅលើ កុមារ និង យុវជន) ក្នុងផ្នែកសុខភាពផ្លូវចិត្ត អាហាររូបត្ថម្ភ ការកំសាន្តសប្បាយ វប្បធម៌ ការបង្ការ ការរំលោភបំពាន និងការអប់រំជំហានដំបូងដល់កុមារអាយុក្រោម៦ឆ្នាំ... ។ល ។ (សូមអានផងដែរនូវការទទួលយក និងបរិស្ថានសិក្សា ស្តង់ដាទី១ កំណត់សំគាល់ណែនាំទី២ នៅទំព័រ៥៧) ។

២. **ជនភៀសខ្លួន ក្រុមមនុស្សរើទីលំនៅ និង អ្នកម្ចាស់ផ្ទះ:** គ្រប់ភាគីដែលពាក់ព័ន្ធ គួរសហការគ្នាដើម្បីតស៊ូមតិឱ្យការអប់រំបានទៅដល់ក្រុមមនុស្សទាំងអស់គ្នាក្នុងលក្ខណៈសមភាព ។ វារួមទាំងពីការប្រកាន់យកសន្ធិសញ្ញាឆ្នាំ១៩៥១ ដែលទាក់ទងទៅនឹងស្ថានភាពជនភៀសខ្លួនមាត្រាទី២២ (ការអប់រំសាធារណៈ) ដែលប្រកាសថាជនភៀសខ្លួនមាន សិទ្ធិទទួលការអប់រំដូចគ្នានឹងប្រជាជនធម្មតា ក្នុងកំរិតបឋមសិក្សា ។ ហើយក្នុងកំរិតសិក្សាខ្ពស់ទៀត គេគួរមានលទ្ធភាពសិក្សា មានការទទួលស្គាល់សញ្ញាប័ត្រផ្សេងៗ ការបន្ធូរបន្ថយ ថ្លៃឈ្នួលសាលា ហើយមានលទ្ធភាពទទួលអាហាររូបករណ៍ក្នុងលក្ខណៈមិនចាញ់អ្នកដែលមានងារជាជនបរទេស ទេ ។ ចំពោះការដែលមិនទទួលបាននូវការការពារជាពិសេសណាមួយនោះ ក្រុមមនុស្សរើទីលំនៅក្នុងស្រុក ក៏គួរទទួលបាននូវសិទ្ធិដូចគ្នាដែរ ។ ដូចគ្នាដែរ ភ្នាក់ងារគួរការពារដល់សិទ្ធិទទួលការអប់រំរបស់កូនសិស្សក្នុងប្រទេស ឬតំបន់ ដែលទទួលជនភៀសខ្លួន និងក្នុងប្រទេសដែលរងគ្រោះដោយសង្គ្រាម ។

៣. **ក្រុមបាត់បង់ផលប្រយោជន៍** គឺជាក្រុមមនុស្សក្នុងសង្គម ឬសហគមន៍មួយដែលផលប្រយោជន៍របស់ពួកគេពុំបានលើកឡើងដោយគោលនយោបាយស្នូលរបស់សង្គម ។ ក្រុមបាត់បង់ផលប្រយោជន៍ត្រូវបានកត់សំគាល់ដោយយោលទៅលើលក្ខណៈ សង្គមសេដ្ឋកិច្ច ឬវប្បធម៌ ដូចជាចំណូល និងទ្រព្យធន ជនជាតិ ឬពូជសាសន៍ យេនឌ័រ ទីតាំង ភូមិសាស្ត្រ សាសនា លក្ខណៈសញ្ជាតិ ការរើទីលំនៅក្នុងស្រុក ឬស្ថានភាពរាងកាយ និង ផ្លូវចិត្តរបស់បុគ្គលម្នាក់ ។ កុមារដែលស្វែងរកសិទ្ធិជ្រកកោន គួរត្រេកត្រអាលនឹងសិទ្ធិទទួលការអប់រំព្រោះសន្ធិសញ្ញាស្តីពី

សិទ្ធិកុមារអនុវត្ត ចំពោះកុមារនិងក្មេងជំទង់ក្រោមអាយុ ១៨ឆ្នាំគ្រប់រូបដែលមានវត្តមានក្នុងដែនដីរដ្ឋ (សូមអានផងដែរនូវការ ទៅកាន់ និងបរិស្ថានសិក្សាស្តង់ដាទី១ កំណត់សំគាល់ណែនាំទី១ នៅទំព័រទី៥៧) ។

**៤. ការចំណាយលើការអប់រំ:** គ្មានសិស្សណាម្នាក់ដែលត្រូវបដិសេធមិនឱ្យទទួលការអប់រំព្រោះតែគ្មានលទ្ធភាពបង់ថ្លៃចូលរៀន ទោះក្នុងរូបភាពជាប្រាក់ឈ្នួល ឬចំណាយផ្សេងៗ ដូចជា សម្ភារៈសិក្សា និង ឯកសណ្ឋានជាដើម ។ គេគួរប្រឹងប្រែងកាត់បន្ថយការចំនាយដោយប្រយោលក្នុងការសិក្សាដូចជា ថ្លៃដឹកជញ្ជូន និងការបាត់បង់ចំណូល ដើម្បី ឱ្យកុមារយុវជន និងមនុស្សពេញវ័យគ្រប់រូបអាចមករៀនបាន ។

**៥. ទិន្នន័យ EMIS** គួរត្រូវបានភ្ជាប់ទៅនឹងពតិមានស្តីពីតំបន់ និងក្រុមមនុស្សដែលប្រឈមនឹងប្រភេទគ្រោះអាសន្នជាក់លាក់ណាមួយ ។ នេះគឺជាយុទ្ធសាស្រ្តត្រៀមដែលគួរផ្តល់ទិន្នន័យទៅក្នុងការធ្វើផែនការអប់រំជាតិ និងមូលដ្ឋាន ។ ក្នុងកន្លែងដែលអាចធ្វើទៅបាន ទិន្នន័យអប់រំគួរត្រូវបានប្រមូលដោយសហគមន៏ហើយបញ្ជូនទៅប្រព័ន្ធ EMIS ជាតិ ។ អង្គការដែលគាំទ្រ គួរជួយដល់សហគមន៏ក្នុងការកំណត់មធ្យោបាយដែលអាចធ្វើឱ្យមានការកើតឡើង នូវចំនួនសិស្សចុះឈ្មោះចូលរៀន មករៀន និងបញ្ចប់ការសិក្សា និងដើម្បីដោះស្រាយផងដែរនូវតំរូវការរបស់យុវជនដែលមិនបានទៅសាលារៀន ។ (សូមអានផងដែរនូវស្តង់ដាវិភាគទី១ នៅទំព័រទី២៤ និងទី៣ នៅទំព័រទី៣០) ។

**៦. ក្របខ័ណ្ឌគ្រោះអាសន្នៈ** ការអប់រំ គួរត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌត្រៀមទប់ទល់នឹងមហន្តរាយជាតិ ហើយធនធាន គួរត្រូវបានត្រៀមទុក ដើម្បីផ្តល់នូវការឆ្លើយតបផ្នែកអប់រំទាន់ពេលវេលា ។ ភ្នាក់ងារអន្តរជាតិដែលគាំទ្រ កម្មវិធីអភិវឌ្ឍន៏ ការអប់រំថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន គួរជំរុញឱ្យមានការត្រៀមរៀបចំសំរាប់ឆ្លើយតបផ្នែក អប់រំ ក្នុងពេលមានគ្រាអាសន្ន ដែលជាសមាសភាគមួយនៃកម្មវិធីទាំងនេះ ។

## ស្តង់ដាទី២ ការធ្វើផែនការ និង ការអនុវត្ត

សកម្មភាពអប់រំក្នុងគ្រាមានអាសន្ន គិតគូរ ពិចារណាទៅលើគោលនយោបាយ និង ស្តង់ដា អប់រំជាតិ និង អន្តរជាតិ ព្រមទាំងពីតំរូវការសិក្សារបស់ក្រុមមនុស្សរងគ្រោះ ។

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយនឹង កំណត់សំគាល់ណែនាំ)

- ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ និងអន្តរជាតិត្រូវបានឆ្លុះបញ្ចាំងក្នុងកម្មវិធីអប់រំរបស់ភ្នាក់ងារផ្តល់ជំនួយសង្គ្រោះ និង អភិវឌ្ឍន៍ (សូមអាន កំណត់សំគាល់ណែនាំទី១)
- កម្មវិធីអប់រំក្នុងគ្រាមានអាសន្នត្រូវបានធ្វើផែនការ និងអនុវត្តក្នុងលក្ខណៈមួយដែលនាំឱ្យមានការបញ្ចូលកម្មវិធីទាំងនោះទៅក្នុងការអភិវឌ្ឍរយៈពេលវែងក្នុងវិស័យអប់រំ ។
- អជ្ញាធរអប់រំ និងភ្នាក់ងារសំខាន់ៗផ្សេងៗទៀតបង្កើតផែនការអប់រំថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានសំរាប់គ្រោះអាសន្ននាពេលបច្ចុប្បន្ន និងទៅអនាគតហើយបង្កើតប្រព័ន្ធមួយដើម្បីកែសំរួលជាប្រចាំទៅលើផែនការនោះ (សូមអាន កំណត់សំគាល់ណែនាំទី២) ។
- ក្នុងពេល និងក្រោយពេលមានគ្រោះអាសន្នគ្រប់ភាគីពាក់ព័ន្ធទាំងឱ្យធ្វើការរួមគ្នាដើម្បីអនុវត្តផែនការឆ្លើយតបផ្នែកអប់រំដែលត្រូវបានភ្ជាប់ទៅនឹងការវាយតម្លៃតំរូវការថ្មីៗបំផុតនិងដែលផ្អែកទៅលើបទពិសោធន៍គោលនយោបាយអប់រំមុនៗ និងការអនុវត្តរបស់ក្រុមមនុស្សរងគ្រោះ ។
- ការឆ្លើយតបផ្នែកអប់រំបញ្ជាក់ពីធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សដែលត្រូវការសំរាប់ការធ្វើផែនការ អនុវត្ត និងពិនិត្យតាមដានដ៏មានប្រសិទ្ធភាពមួយ ។ ភាគីពាក់ព័ន្ធត្រូវធានាឱ្យមាននូវធនធានដែលត្រូវការ (សូមអាន កំណត់សំគាល់ណែនាំទី៣) ។
- ការធ្វើផែនការ និងការអនុវត្តសកម្មភាពអប់រំត្រូវបានបញ្ចូលទៅក្នុងវិស័យជំនួយគ្រោះអាសន្នផ្សេងៗទៀត (សូមអាន កំណត់សំគាល់ណែនាំទី៤) ។

### កំណត់សំគាល់ណែនាំ

១. **ការសំរេចសិទ្ធិ និងគោលបំនងនៃការអប់រំ៖** កម្មវិធីអប់រំ គួរផ្តល់នូវសកម្មភាពអប់រំបញ្ចូលគ្នាដែលស្របទៅនឹងក្របខ័ណ្ឌអន្តរជាតិដូចជាសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ (1989) ការប្រកាសជាសាកលនៃសិទ្ធិមនុស្ស (1946) ក្រប

ខ័ណ្ឌការអប់រំសំរាប់ទាំងអស់គ្នា (2000) និងគោលដៅអភិវឌ្ឍន៍សហសវត្ស Millenium Development Goals (2000) បន្ថែមទៅលើក្របខ័ណ្ឌ និងគោលនយោបាយដែលមានស្រាប់របស់អជ្ញាធរអប់រំដែលពាក់ព័ន្ធ។

**២. ផែនការអប់រំជាតិ** គួរគូសបញ្ជាក់ពីសកម្មភាពដែលត្រូវធ្វើក្នុងគ្រាមានអាសន្នបច្ចុប្បន្ន និង នាអនាគតដែលសំដៅទៅលើកម្មវិធីភ្ជាក់ងារភាគីពាក់ព័ន្ធការសំរេចចិត្ត និងការសំរបសំរួលក៏ដូចជាកត្តាសន្តិសុខនិងការការពារ ព្រមទាំងយន្តការសំរបសំរួលអន្តរវិស័យផងដែរ។ ផែនការត្រូវបានគាំទ្រដោយគោលនយោបាយនិងក្របខ័ណ្ឌអប់រំសមស្រប។ ផែនការបំរុងគួរត្រូវបានរៀបចំឡើងសំរាប់វិស័យអប់រំដែលទាក់ទងទៅនឹងគ្រោះមហន្តរាយធម្មជាតិដែលអាចកើតមាន (ឧទាហរណ៏ ទឹកជំនន់ ការរញ្ជួយដី ខ្យល់ព្យុះកំបុតត្បូង) ហើយក៏សំរាប់ការហូរចូលនូវជន ភៀសខ្លួន ឬអ្នកធ្វើមាតុភូមិនិវត្តន៍ដែលអាចប៉ះពាល់ដល់ប្រព័ន្ធអប់រំថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ (សូមអានផងដែរ នូវការចូលរួមរបស់សហគមន៍ ស្តង់ដាទី១ កំណត់សំគាល់ណែនាំទី៥ នៅទំព័រទី១៩ និងស្តង់ដាទី៣ ខាងក្រោមនេះ)។

**៣. ធនធាន:** អជ្ញាធរម្ចាស់ជំនួយ NGOs និងភាគីពាក់ព័ន្ធផ្សេងៗទៀតគួរសហការគ្នាធានាឱ្យមានមូលនិធិគ្រប់គ្រាន់សំរាប់ជួយដល់កម្មវិធីអប់រំក្នុងគ្រាមានអាសន្ន ដែលផ្តោតលើសកម្មភាពសិក្សា លំហែកំសាន្ត និងសកម្មភាពផ្សេងៗទៀតដែលគាក់តែងឡើងដើម្បីបំរើតំរូវការចិត្តសាស្ត្រ។ នៅពេលគ្រាអាសន្នមានស្ថិរភាពហើយឱកាសនៃ ការធ្វើកម្មវិធីអប់រំអាចត្រូវបានពង្រីក ដើម្បីបញ្ចូលនូវការអភិវឌ្ឍន៍ក្មេងមិនទាន់គ្រប់ អាយុចូលសាលា ការរៀន ថ្នាក់បឋមសិក្សានិងមធ្យមសិក្សាក្នុងប្រព័ន្ធ ថ្នាក់អក្ខរកម្មសំរាប់មនុស្សពេញវ័យ និងកម្មវិធីវិជ្ជាជីវៈផ្សេងៗ ទៀត...។ល។ ការចាត់ចែងធនធានគួរធ្វើឱ្យមានលំនឹងរវាងបរិក្ខាសិក្សា (ដូចជាថ្នាក់រៀនបន្ថែម សៀវភៅពុម្ព និង សម្ភារៈសិក្សា និង បង្រៀន) និងសមាសភាគកំណត់គុណភាព (ដូចជាគ្រូបង្រៀននិងវគ្គបណ្តុះបណ្តាលគ្រូតពិនិត្យ។

**៤. ស្តង់ដាអប្បបរមា Sphere :** ការប្រឹងប្រែងជាពិសេសគួរត្រូវបានធ្វើដើម្បីភ្ជាប់ផែនការនិងការអនុវត្តសកម្មភាព អប់រំទៅនឹងស្តង់ដាអប្បបរមា Sphere ក្នុងផ្នែក:

- ទឹក ការបង្កើតឱ្យមានអានាម័យ និង ភាពស្អាត
- សន្តិសុខស្បៀង អាហាររូបត្ថម្ភ និងជំនួយស្បៀងអាហារ
- ជំរក ការតាំងទីលំនៅ និងគ្រឿងឧបភោគ និង
- សេវាកម្មសុខភាព (សូមអានការភ្ជាប់ទៅនឹង ឧបសម្ព័ន្ធ ស្តង់ដា Sphere នៅលើ MSEE CD-ROM

ដែលនិយាយពីស្តង់ដាដែលទាក់ទងទៅនឹង Sphere

## ស្តង់ដារទី៣ ការសំរបសំរួល

**មានយន្តការសំរបសំរួលមានតម្លាភាពមួយ សំរាប់សកម្មភាពអប់រំក្នុងគ្រាមានអាសន្នដោយរួមទាំងពីការចែករំលែកដ៏មានប្រសិទ្ធភាពនូវពត៌មានរវាងភាគីដែលពាក់ព័ន្ធ ។**

**សូចនាករសំខាន់ៗ** (សំរាប់អានជាមួយ កំណត់សំគាល់ណែនាំ)

- អាជ្ញាធរអប់រំបង្កើតគណកម្មការសំរបសំរួលអន្តរភ្នាក់ងារសំរាប់ការឆ្លើយតបទៅនឹងគ្រោះអាសន្ននាពេល បច្ចុប្បន្ន និងទៅអនាគត ហើយដែលគណកម្មការនោះមានតួនាទីសំខាន់ក្នុងការធ្វើផែនការ និងសំរបសំរួល សកម្មភាពអប់រំក្នុងគ្រាមានអាសន្ន (សូមអាន កំណត់សំគាល់ណែនាំទី១) ។
- នៅពេលដែលអាជ្ញាធរអប់រំពុំមានវត្តមាន ឬពុំអាចដឹកនាំការសំរបសំរួលបានគណកម្មការសំរបសំរួល អន្តរភ្នាក់ងារផ្តល់នូវការណែនាំ និង សំរបសំរួលដល់សកម្មភាព និងកម្មវិធីអប់រំ (សូមអាន កំណត់សំគាល់ណែនាំទី១) ។
- អាជ្ញាធរ ម្ចាស់ជំនួយ និងភ្នាក់ងារផ្សេងៗទៀតបង្កើតរចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានសំរបសំរួលហើយ ត្រូវគាំទ្រដល់សកម្មភាពអប់រំរបស់ភាគីពាក់ព័ន្ធ (សូមអាន កំណត់សំគាល់ណែនាំទី២)
- មានការថ្លែងការណ៍រួមនៃគោលបំណងសំរបសំរួល សូចនាករ និងទំរង់ការពិនិត្យតាមដាន ហើយភ្នាក់ងារ អប់រំទាំងអស់ត្រូវប្តេជ្ញាធ្វើការទៅតាមក្របខ័ណ្ឌនោះ ហើយត្រូវផ្តល់ពត៌មាន និងស្ថិតិសំខាន់ៗដល់ វិស័យសាធារណៈ (សូមអាន កំណត់សំគាល់ណែនាំទី៣)
- សហគមន៍រងគ្រោះត្រូវបានផ្តល់សិទ្ធិ និងមានលទ្ធភាពចូលរួមក្នុងការសំរេចចិត្តដែលប៉ះពាល់ដល់ពួកគេ ជាពិសេសក្នុងការបង្កើតអនុវត្ត និងតាមដានគោលនយោបាយឬកម្មវិធី ។
- មានយន្តការមានតម្លាភាព និងសកម្មសំរាប់ចែករំលែកពត៌មានក្នុងចំណោមវិស័យផ្សេងៗ និងរវាងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិសំខាន់ៗ (សូមអាន កំណត់សំគាល់ណែនាំទី៤) ។

**កំណត់សំគាល់ណែនាំ**

១. **គណកម្មការសំរបសំរួលអន្តរភ្នាក់ងារ:** តំណាងក្នុងគណកម្មការនេះគួររួមមានភាគីពាក់ព័ន្ធឱ្យបានច្រើនហើយបើអាចធ្វើទៅបានគណកម្មការនេះគួរស្ថិតនៅក្រោមការដឹកនាំរបស់អាជ្ញាធរជាតិ ។ គណកម្មការសំរបសំរួល

អាចជាតំរូវ ការក្នុងថ្នាក់តំបន់ ថ្នាក់ជាតិ ថ្នាក់ស្រុក ឬថ្នាក់មូលដ្ឋានអាស្រ័យទៅលើលក្ខណៈនៃគ្រោះអាសន្ន។ នៅពេលដែលអជ្ញា ធរអប់រំពុំមានសមត្ថភាពឬភាពស្របច្បាប់ទេនោះ គេអាចព្រមព្រៀងប្រគល់ការដឹកនាំឱ្យទៅភ្នាក់ងារឯទៀតក៏ប៉ុន្តែតំនាងមកពីអជ្ញាធរអប់រំ នៅតែជាសមាជិកមួយរបស់គណកម្មការនោះ។ តាមស្ថានការអនុញ្ញាត្ត ភារកិច្ចក្នុងការសំរបសំរួលគួរតែផ្ទេរភ្លាម១ទៅឱ្យអជ្ញាធរ សមស្រប។

**២. ហិរញ្ញកិច្ចៈ** មូលនិធិគ្រប់គ្រាន់ជាតំរូវការសំរាប់ការអនុវត្តមានជោគជ័យនិងទាន់ពេលវេលានូវកម្មវិធីអប់រំក្នុងគ្រាមានអាសន្ន។ គេគួរខំប្រឹងប្រែងធានាឱ្យមានវិធីសាស្ត្រចាត់ចែងមូលនិធិដែលមានតម្លាភាពនិងដែលមានការសំរបសំរួលជាពិសេសនៅកន្លែងដែលប្រាក់ខែគ្រូពុំមានគ្រប់គ្រាន់ ឬពុំមានការផ្តល់ប្រាក់ខែឱ្យគ្រូតែម្តង។ ការរៀបចំប្រមូលមូលនិធិក្នុងគ្រាមានអាសន្ន គួរគិតគូរពិចារណាទៅលើស្ថានភាពនិងប្រពៃណីទីផ្សារពលកម្មក្នុងមូលដ្ឋាន ហើយគួរជៀសវាងបង្កើតកម្មវិធីណាដែលពុំអាចធានានូវនិរន្តភាពបាន។

**៣. ការប្រទាញប្រទង់ការសំរបសំរួលសំខាន់១** គួរត្រូវបានកំណត់និងដោះស្រាយតាំងពីតំនាក់កាលដំបូងនៃគ្រោះអាសន្ន ដើម្បីទទួលបាននូវវិធីសាស្ត្រអស់ចំនាយតិច ដែលនាំទៅរកសេវាកម្មអប់រំដែលមាននិរន្តភាពនិងមានសុខដុមនិយកម្មក្នុងពេលអនាគត។ បញ្ហាអាចរួមមានការបណ្តុះបណ្តាលគ្រូបង្រៀន ការបញ្ចាក់និងការបង់ថ្លៃកម្មវិធីសិក្សា និងសមាសភាគទាក់ទងផ្សេង១ទៀត (សៀវភៅពុម្ពនិងសម្ភារៈជំនួយការបង្រៀន និងការសិក្សា) និង ការបង្កើតរចនាសម្ព័ន្ធនិងការទទួលស្គាល់ការសិក្សា និង ការប្រលង។

**៤. សិក្ខាសាលារួមគ្នាដើម្បីអភិវឌ្ឍន៍គោលនយោបាយ និងបណ្តុះបណ្តាល** គួរត្រូវបានបង្កើតដោយមានការសហការជាមួយអជ្ញាធរអប់រំ និងភ្នាក់ងារខាងក្រៅដើម្បីធានាឱ្យមានទំនាក់ទំនងល្អ បង្កើតការសហការនិងការតាំងចិត្តទៅលើទស្សនៈរួមគ្នានិងពង្រឹងការអភិវឌ្ឍទូទៅនៃប្រព័ន្ធអប់រំ។